រាជបណ្ឌិត្យសភាកម្ពុជា
វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

# កាលិកាបត្រស្រាវជ្រាវ
# មនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

កសមវស

លេខទី២
ច្បាប់លេខ១២
ខែធ្នូ
ឆ្នាំ២០២៣

# កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម

**លេខទី២ ច្បាប់លេខ២**

**រក្សាសិទ្ធិ**® វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា

មិនមានផ្នែកណាមួយនៃឯកសារនេះ ត្រូវបានផលិតឡើងវិញ រក្សាទុក ឬបម្លែងឱ្យខុសពីទ្រង់ទ្រាយដើមតាមវិធីណាមួយ ទោះបីជាក្នុងទម្រង់ឯកសារឌីជីថល ឬការថតចម្លង ដោយពុំមានការយល់ព្រមជាលាយលក្ខណ៍អក្សរជាមុនពីម្ចាស់កម្មសិទ្ធិនោះទេ។

បោះពុម្ពដោយ៖ វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម (វមវស)

ទំនាក់ទំនង៖

*វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*

មហាវិថីសហព័ន្ធរុស្ស៊ី ជាន់ទី២ នៃអគារខេមរវិទូ រាជបណ្ឌិត្យសភាកម្ពុជា

➩ ទូរសព្ទ/តេឡេក្រាម៖ (+855)12-250-887

➩ អ៊ីមែល៖: cjhsseditors@gmail.com

# គណៈកម្មការកាលិកបត្រ

## ក្រុមប្រឹក្សាភិបាល

| | |
|---|---|
| បណ្ឌិត ហ៊ាន សុខុម | ក្រុមប្រឹក្សាជាតិភាសាខ្មែរនៃរាជបណ្ឌិត្យសភាកម្ពុជា |
| បណ្ឌិត ឆេង គីមឡុង | វិទ្យាស្ថានចក្ខុវិស័យអាស៊ី |
| បណ្ឌិត លី វណ្ណា | គណៈកម្មការជាតិបេតិកភណ្ឌ |
| សាស្ត្រាចារ្យ Takuya Baba | Hiroshima University |
| បណ្ឌិត វង់ សំអូន | អគ្គលេខាធិការដ្ឋាននៃរាជបណ្ឌិត្យសភាកម្ពុជា |

## និពន្ធនាយក

| | |
|---|---|
| បណ្ឌិត ផុន កសិកា | វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា |

## និពន្ធនាយករង

| | |
|---|---|
| បណ្ឌិត តួច សុធារី | វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា |
| លោក លី តុង | វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា |
| បណ្ឌិត ឃិន យ៉ង់ | វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា |
| លោក សេង សុធា | លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា |
| លោក មឿង ចំរើន | លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា |
| លោក ឆោម ជុំរ៉ុង | លេខាធិការដ្ឋានក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា |

## អ្នកពិនិត្យវិនិច្ឆ័យ

| | |
|---|---|
| បណ្ឌិត ភោគ សុខី | វិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា |
| លោក មាឃ សារី | វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា |
| លោក ហ៊ុំ ចាន់ | សាកលវិទ្យាល័យបាត់ដំបង, សាកលវិទ្យាល័យអប់រំហុងកុង |
| លោក ធី សាវិន | វិទ្យាស្ថានជាតិអប់រំ |
| លោក ជា សុត | វិទ្យាស្ថានជាតិគរុកោសល្យរាជធានីភ្នំពេញ |

# អំពីកាលិកាបត្រ

**កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម (កសមវស)** បង្កើតឡើងដោយវិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនៃរាជបណ្ឌិត្យសភាកម្ពុជា ក្នុងគោលបំណងបោះពុម្ព និងផ្សព្វផ្សាយនូវរបកគំហើញវិទ្យាសាស្ត្រ និងអត្ថបទស្រាវជ្រាវនានាក្នុងវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ពីគ្រប់មជ្ឈដ្ឋានអ្នកស្រាវជ្រាវទាំងអស់។ កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមទទួលបោះពុម្ពអត្ថបទបីប្រភេទគឺ៖ អត្ថបទស្រាវជ្រាវ (Research Paper ឬ Research Article), អត្ថបទសំយោគ (Review Paper) និងអត្ថបទវិភាគគោលនយោបាយ (Policy Analysis/Policy Brief)។ សំណៅអត្ថបទ (Manuscript) ដែលទទួលបានទាំងអស់ត្រូវឆ្លងកាត់ការត្រួតពិនិត្យដោយគណៈកម្មការកាលិកបត្រជាមុន រួចបញ្ជូនបន្តទៅអ្នកជំនាញតាមឯកទេសពាក់ព័ន្ធដើម្បីវាយតម្លៃនិងផ្តល់អនុសាសន៍កែលម្អក្រោមទម្រង់ Double-blind Peer Review មុននឹងទទួលបោះពុម្ព។ កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមទទួលបោះពុម្ពអត្ថបទស្រាវជ្រាវនានាជាពីរភាសាគឺ ***ភាសាខ្មែរ និងភាសាអង់គ្លេស*** ដោយអ្នកស្រាវជ្រាវអាចបញ្ជូនអត្ថបទជាភាសាមួយណាក៏បានទៅតាមលទ្ធភាពរបស់ខ្លួន។ ការបោះពុម្ពកាលិកបត្រមានទាំងជាទម្រង់រឹង (Hard Copy) និងទម្រង់ឌីជីថល (Digital Copy) ដោយមានមួយលេខក្នុងមួយឆ្នាំ ដែលចែកចេញជាពីរច្បាប់ទៅតាមភាសាដូចការកំណត់ខាងក្រោម៖

- កាលិកបត្រជាភាសាអង់គ្លេស (ច្បាប់លេខ១)
- កាលិកបត្រជាភាសាខ្មែរ (ច្បាប់លេខ២)

***កសមវស*** ទទួលបោះពុម្ពអត្ថបទដែលស្ថិតក្រោមជំនាញខាងក្រោម៖

| | | | |
|---|---|---|---|
| វិទ្យាសាស្ត្រនយោបាយ | រដ្ឋបាលសាធារណៈ | ទស្សនវិជ្ជា | ភាសាវិទ្យា |
| ចរិយាសាស្ត្រនិងយេនឌ័រ | ការសិក្សាអភិវឌ្ឍន៍ | ពាណិជ្ជកម្ម | ភូមិវិទ្យា |
| នរវិទ្យានិងជាតិពន្ធុវិទ្យា | សេដ្ឋកិច្ចទីផ្សារ | សង្គមវិទ្យា | គ្រប់គ្រង |
| ទំនាក់ទំនងអន្តរជាតិ | បុរាណវត្ថុវិទ្យា | ប្រវត្តិវិទ្យា | ចិត្តវិទ្យា |
| វិទ្យាសាស្ត្រសេដ្ឋកិច្ច | វិទ្យាសាស្ត្រអប់រំ | អក្សរសិល្ប៍ | ច្បាប់ |
| ក្រៅពីជំនាញខាងលើ កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ក៏ទទួលសំណៅអត្ថបទពាក់ព័ន្ធដែលស្ថិតក្រោមវិសាលភាពនៃវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមផ្សេងទៀតផងដែរ។ | | | |

# សាររបស់និពន្ធនាយក

ខ្ញុំមានសេចក្តីរីករាយឥតឧបមា ដែលបានចូលរួមក្នុងការបង្កើតនិងបោះពុម្ពផ្សាយកាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមសម្រាប់ឆ្នាំទី២ (លេខទី២, ច្បាប់លេខ២) នេះឡើង។ ខ្ញុំពិតជាជឿជាក់យ៉ាងមុតមាំថា កាលិកបត្រស្រាវជ្រាវនេះនឹងដើរតួយ៉ាងសំខាន់ក្នុងការជួយជំរុញនូវវប្បធម៌ស្រាវជ្រាវបែបវិទ្យាសាស្ត្ររបស់កម្ពុជា ក៏ដូចជាចូលរួមក្នុងការចែករំលែកចំណេះដឹងផ្សេងៗប្រកបដោយលក្ខណៈវិទ្យាសាស្ត្រ ពីសំណាក់អ្នកស្រាវជ្រាវគ្រប់មជ្ឈដ្ឋាន។ ឆ្លៀតក្នុងឱកាសនេះដែរ  តាងនាមឱ្យគណៈកម្មការកាលិកបត្រទាំងមូល ខ្ញុំបាទសូមស្វាគមន៍អ្នកស្រាវជ្រាវ សិស្ស-និស្សិត សាស្ត្រាចារ្យ និងមិត្តអ្នកអានទាំងអស់ដែលគាំទ្រកាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គមនេះ។ ជាមួយគ្នានេះ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់សមាជិកគណៈកម្មការកាលិកបត្រទាំងអស់ ព្រមទាំងអ្នកស្រាវជ្រាវ ក្រុមប្រឹក្សាពិគ្រោះនិងផ្តល់យោបល់ គណៈកម្មការត្រួតពិនិត្យ និងអ្នកជំនាញទាំងអស់ដែលបានចូលរួមធ្វើឱ្យស្នាដៃមួយនេះលេចចេញជារូបរាងឡើង។ រូបខ្ញុំផ្ទាល់ក៏ដូចជាសមាជិកក្រុមការងារកាលិកបត្រទាំងអស់រង់ចាំទទួលនូវមតិរិះគន់ក្នុងន័យស្ថាបនាពីមិត្តអ្នកអាន សិស្សនិស្សិត សាស្ត្រាចារ្យ និងអ្នកស្រាវជ្រាវពីគ្រប់មជ្ឈដ្ឋានទាំងអស់ ដើម្បីឈានទៅធ្វើឱ្យស្នាដៃស្រាវជ្រាវបែបវិទ្យាសាស្ត្រមួយនេះកាន់តែមានគុណតម្លៃ និងគុណភាពប្រសើរឡើងជាលំដាប់។

**និពន្ធនាយក**



បណ្ឌិត **ផុន កសិកា**

# ប្រកាសរកអត្ថបទ

**កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម** រីករាយស្វាគមន៍រាល់សំណៅអត្ថបទ ពីគ្រប់មជ្ឈដ្ឋានអ្នកស្រាវជ្រាវ លើប្រធានបទនានាទាក់ទងនឹងវិស័យមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម ដើម្បីធ្វើការត្រួតពិនិត្យ និងបោះពុម្ពផ្សាយក្នុងលេខបន្តបន្ទាប់របស់កាលិកបត្រ។ អ្នកស្រាវជ្រាវទាំងឡាយដែលមានបំណងបោះពុម្ពលទ្ធផលស្រាវជ្រាវរបស់ខ្លួន សូមទំនាក់ទំនង ឬផ្ញើសំណៅអត្ថបទមកគណកម្មការនិពន្ធរបស់ **កសមវស** តាមលេខទូរសព្ទ/តេឡេក្រាម ឬសារអេឡិកត្រូនិកដូចខាងក្រោម៖

- ទូរសព្ទ/តេឡេក្រាម៖ (+855)-12-250-887
- អ៊ីមែល(Email)៖ cjhsseditors@gmail.com

អត្ថបទរបស់លោកអ្នក នឹងឆ្លងកាត់ការត្រួតពិនិត្យពីគណកម្មការនិពន្ធ (Editorial Team) និងបន្តឆ្លងកាត់ការពិនិត្យវិនិច្ឆ័យ និងផ្តល់អនុសាសន៍កែលម្អលើខ្លឹមសារ ដោយផ្អែកលើអ្នកជំនាញតាមឯកទេសនីមួយៗ។

សូមផ្ញើសំណៅអត្ថបទមក **កសមវស** ឱ្យបានយ៉ាងហោចណាស់ **០២ខែ** មុនកាលបរិច្ឆេទបោះពុម្ពដូចខាងក្រោម៖

- កាលិកបត្រជាភាសាអង់គ្លេស (ច្បាប់លេខ១)៖ ក្នុងខែមិថុនា
- កាលិកបត្រជាភាសាខ្មែរ (ច្បាប់លេខ២)៖ ក្នុងខែធ្នូ

# ចំណងជើងអត្ថបទ

ការប្រើប្រាស់ទឹកតាមផ្ទះរបស់ប្រជាពលរដ្ឋក្នុងឃុំឆែប២ ខេត្តព្រះវិហារៈ ប្រភព វិធានអនាម័យ និងឥរិយាបថ ១-២២

*ដោយៈ ហេង វិទ្ធិ, សេង សុជា, មឿង ចំរើន, ឆោម ជុំរ៉ុង*

ការបង្រៀននិងរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាក្នុងអំឡុងពេលបិទសាលារៀនៈ ការសិក្សាលើទស្សនៈរបស់គ្រូនិងសិស្ស ២៣-៤១

*ដោយៈ លី តុង, ជី សាវិន, អៀន សុគន្ធី*

មូលហេតុនៃការបែកបាក់គ្រួសារនៅកម្ពុជាៈ ការសិក្សានៅក្នុងសង្កាត់ស្ទឹងមានជ័យរាជធានីភ្នំពេញ ៤២-៥៥

*ដោយៈ ឈុន ផារ៉េង, ប៉ាន់ វុត្ថា, ហ៊ឹម ញាណារិទ្ធ, ក្លាន់ ធុល*

ការសិក្សាខ្នាតតូចអំពីទស្សនៈអតិថិជនកម្ពុជាទៅលើការទិញនិងសេវាកម្មទិញ-លក់ផលិតផលតាមអនឡាញ ៥៦-៧៤

*ដោយៈ មឿង ចំរើន, លី តុង*

កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Cambodian Journal of Humanities and Social Sciences

Website: https://cjhss-journal.com/

# ការប្រើប្រាស់ទឹកតាមផ្ទះរបស់ប្រជាពលរដ្ឋក្នុងឃុំឆែប២ ខេត្តព្រះវិហារ៖ ប្រភព វិធានអនាម័យ និងឥរិយាបថ

# Household Water Use of Cambodian Residents at Chhaeb 2 Commune, Preah Vihear Province: Sources, Hygienic Measures and Attitudes

ហេង វិរិទ្ធ[១], សេង សុធា[២], មឿង ចំរើន[៣], ឆោម ជុំរ៉ុង[៤]

[១] លេខាធិការដ្ឋានក្រុមបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ hvirith2003@gmail.com

[២] លេខាធិការដ្ឋានក្រុមបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ sotheatesl@gmail.com

[៣] លេខាធិការដ្ឋានក្រុមបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ chamroeun.rac@gmail.com

[៤] លេខាធិការដ្ឋានក្រុមបណ្ឌិតសភាចារ្យ នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ chhom.chumrong@gmail.com

បានទទួល៖ ១២កញ្ញា ២០២៣; ទទួលបោះពុម្ព៖ ១០ធ្នូ ២០២៣; បោះពុម្ព៖ ៣១ធ្នូ ២០២៣

**ទំនាក់ទំនង៖** hvirith2003@gmail.com

**អាគតដ្ឋាន៖** ហេង វិរិទ្ធ, សេង សុធា, មឿង ចំរើន និង ឆោម ជុំរ៉ុង. (២០២៣). ការប្រើប្រាស់ទឹកតាមផ្ទះរបស់ប្រជាពលរដ្ឋក្នុងឃុំឆែប២ ខេត្តព្រះវិហារ៖ ប្រភព វិធានអនាម័យ និងឥរិយាបថ. *កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*, *២*(២), ១-២២.

## សង្ខិត្តន័យ

ទឹកពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ជីវិតរស់នៅរបស់មនុស្ស។ ការសិក្សាស្រាវជ្រាវខ្នាតតូចនេះមានវត្ថុបំណងចំនួនបី៖ (១) សិក្សាអំពីប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ (២) សិក្សាអំពីវិធានអនាម័យទឹកមុនពេលប្រើប្រាស់របស់ប្រជាពលរដ្ឋ និង(៣) សិក្សាអំពីឥរិយាបថ/ទស្សនៈ

របស់ប្រជាពលរដ្ឋទាក់ទងនឹងទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារ។ អ្នកស្រាវជ្រាវបានប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ។ ទិន្នន័យក្នុងការសិក្សានេះទទួលបានពីការសម្ភាសដោយប្រើកម្រងសំណួរ semi-structured questionnaire និងការធ្វើក្រុមពិភាក្សា។ លទ្ធផលសំខាន់ៗបង្ហាញថាការទឹកយកចេញពីអណ្តូងដៃ គឺជាប្រភពទឹកដ៏សំខាន់ជាងគេសម្រាប់ទទួលទានប្រចាំថ្ងៃ ហើយប្រភពទឹកសម្រាប់ប្រើប្រាស់ទូទៅប្រចាំថ្ងៃដែលពេញនិយមជាងគេគឺអណ្តូងស្នប់ជីកដោយដៃ។ ការរកឃើញមួយទៀតបានបង្ហាញថាប្រជាពលរដ្ឋលើសពី 65% តែងតែទទួលទានទឹកដោយពុំបានប្រើប្រាស់វិធានអនាម័យទាល់តែសោះ។ លើសពីនេះ ប្រជាពលរដ្ឋរក្សាទឹកទុកប្រើប្រាស់ដោយពុំសូវគិតគូរអំពីអនាម័យនោះទេ ដោយឧបករណ៍រក្សាទឹកទុកភាគច្រើនពុំសូវមានអនាម័យឬពុំមានគម្របត្រឹមត្រូវ។ យ៉ាងណាមិញប្រជាជនភាគច្រើន(55.9%) យល់ឃើញថាគុណភាពទឹកផឹករបស់ពួកគេគឺមានសុវត្ថិភាពនិងស្អាត។ ការរកឃើញទាំងនេះបង្ហាញពីតម្រូវការចាំបាច់នៃវិធានការចាំបាច់ផ្សេងៗ ដូចជាការជម្រុញលើកកម្ពស់ការយល់ឃើញពីទឹកស្អាត និងការរៀបចំប្រព័ន្ធទឹកស្អាត។

**ពាក្យគន្លឹះ:** ទឹកប្រើប្រាស់តាមផ្ទះ, វិធានអនាម័យ, ប្រភពទឹក, ឥរិយាបថ, កម្ពុជា

**ABSTRACT**

Water is very important for human life. This small-scale study has three main objectives: (1) to study the daily water source of the people living in Chhaeb 2 commune, Chhaeb district, Preah Vihear province; (2) to study the water hygienic measures before use; and (3) to study the attitudes and perspectives of the people on the water for household use. The researchers employed a mixed-methods approach. The researchers drew the data for this study from the interviews using a semi-structured questionnaire and group discussion. The key findings revealed that the water from hand-dug water pounds is the main water source for daily drinking, and the most common source of water for everyday use is hand-dug pump wells. Another finding showed that more than 65% of the participants drink water without following any hygienic measures. In addition, people store the water without much consideration for hygiene, as most water storage containers are not clean or do not have any proper cover. However, most people (55.9%) think that the quality of drinking water is safe and clean. These findings suggest further needed measures, such as raising awareness about hygienic water and the adoption of the sanitation system.

**KEYWORDS:** household water, hygienic measures, sources of water, attitude, Cambodia

# ១. សេចក្តីផ្តើម

## ១.១. ទិដ្ឋភាពទូទៅ

ទឹកគឺជាប្រភពដែលគាំទ្រដល់ការរស់រាន មានជីវិតរបស់មនុស្ស សត្វ និងរុក្ខជាតិនានាដ៏មានសារៈសំខាន់ជាងគេបំផុតមួយនៅលើផែនដី។ បើតាមការស្រាវជ្រាវមួយបានគូសបញ្ជាក់ថា មនុស្សម្នាក់ត្រូវការទឹកយ៉ាងហោចណាស់ប្រមាណ 50 លីត្រក្នុងមួយថ្ងៃ (Gleick, 1996)។ ទឹកត្រូវបានប្រើប្រាស់ក្នុងជីវភាពរស់នៅប្រចាំថ្ងៃរបស់យើងដូចជាការដាំស្ល ផឹក ងូត លាងសម្អាត និងស្រោចស្រពដំណាំជាដើម។ អង្គការសហប្រជាជាតិបានបញ្ជាក់ផងដែរថាតម្រូវការទឹកគឺជាសិទ្ធិមូលដ្ឋានមួយរបស់មនុស្ស។ ក្នុងន័យនេះមនុស្សគ្រប់រូបត្រូវមានសិទ្ធិទទួលបានទឹកគ្រប់គ្រាន់និងមាន

សុវត្ថិភាពសម្រាប់ការប្រើប្រាស់ផ្ទាល់ខ្លួន និងសហគមន៍។ យ៉ាងណាមិញ បរិមាណទឹកនៅលើផ្ទៃផែនដីនៅមានកម្រិត ដោយក្នុងចំណោមបរិមាណទឹកសរុប 1.4 ពាន់លានគីឡូម៉ែត្រគូបក្នុងពិភពលោក មាន 97.5% ជាទឹកប្រៃ និង 2.5% ជាធនធានទឹកសាប (Sevimli, 2021, as cited in Ertop et al., 2023)។ ជាក់ស្តែងបច្ចុប្បន្នធនធានទឹកសាបនៅលើពិភពលោកកំពុងរងការប៉ះពាល់ពីបញ្ហាប្រឈមនានាដូចជាបម្រែបម្រួលអាកាសធាតុ ការបំពុលទឹក និងគ្រោះធម្មជាតិ ដែលនាំឱ្យបរិមាណទឹកពីប្រភពផ្សេងៗកាន់តែខ្សត់ និងត្រូវបានបំពុល។

ប្រទេសកម្ពុជាត្រូវបានគេចាត់ទុកថាជាប្រទេសមួយក្នុងចំណោមប្រទេសមានទឹកច្រើនជាងគេក្នុងតំបន់ និងមានសេដ្ឋកិច្ចពឹងផ្អែកខ្លាំងលើទឹក។ ទន្លេ ស្ទឹង បឹង អាងទឹក និងទឹកសមុទ្រ គឺជាប្រភពដ៏សំខាន់សម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចជាតិក្នុងវិស័យផ្សេងៗដូចជា កសិកម្ម ផលិតកម្ម និងឧស្សាហកម្មខ្នាតតូច វារីអគ្គិសនី នាវាចរណ៍ ទេសចរណ៍ ការការពារបរិស្ថាន ក៏ដូចជាក្នុងជីវភាពប្រចាំថ្ងៃ (UNDP, 2020)។ ប្រភពទឹកទាំងនេះរួមមាន ទឹកភ្លៀង ទឹកលើដី និងទឹកក្រោមដី។ គ្រួសារកម្ពុជាភាគច្រើនរស់នៅទីជនបទមិនទាន់អាចពឹងផ្អែកលើប្រព័ន្ធទឹកស្អាតបាននៅឡើយទេ ហេតុដូចច្នេះការផ្គត់ផ្គង់ទឹកនៅជនបទជាទូទៅពឹងលើប្រភពផ្សេងៗដូចជាស្រះ ទន្លេ បឹង អណ្តូងដៃ អណ្តូងស្នប់ និងទឹកភ្លៀង (WaterAid, n.d.)។

ការទទួលបានទឹកស្អាត និងអនាម័យនៅមិនទាន់គ្រប់គ្រាន់នៅបណ្តាប្រទេសមានចំណូលទាបនៅតែបន្តជាបញ្ហាប្រឈមផ្នែកសុខភាពសាធារណៈ និងការអភិវឌ្ឍ (Orgill et al., 2013)។ នៅក្នុងគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍ (MDGs) ទឹកនិងអនាម័យត្រូវបានកំណត់ក្នុងគោលដៅ 7C ដែលទាមទារយ៉ាងហោចណាស់ពាក់កណ្តាលនៃប្រជាជនក្នុងឆ្នាំ2000 ដែលគ្មានលទ្ធភាពទទួលបានទឹកផឹកអាចមានលទ្ធភាពប្រើប្រាស់ទឹកដែលមានសុវត្ថិភាព និងស្អាតប្រកបដោយនិរន្តរភាពនៅឆ្នាំ2015 (United Nations, 2017)។ ក្នុងចំណោមគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព (SDG) ទាំង17ចំណុច ក្នុងនោះ គោលដៅទី6 គឺផ្តោតលើទឹកស្អាតនិងអនាម័យ។ ក្នុងចំណោមចំណុចទាំង8 នៃគោលដៅទី6 ចំណុច6.1 និង 6.4 បានគាំទ្រទៅលទ្ធផលរំពឹងទុកជាសកលលើនិរន្តរភាពនៃការផ្គត់ផ្គង់ទឹក សមធម៌នៃទឹកស្អាត និងមានសុវត្ថិភាពដើម្បីឆ្លើយតបនឹងបញ្ហាកង្វះទឹកនៅឆ្នាំ2030 (United Nations Cambodia, n.d.)។ គោលដៅទី7 នៃការអភិវឌ្ឍសហសវត្សរ៍របស់ប្រទេសកម្ពុជា (CMDGs) បានកំណត់គោលដៅលើលទ្ធភាពទទួលបានប្រភពទឹកមានសុវត្ថិភាពត្រឹមឆ្នាំ2015 ចំនួន 50% នៅតំបន់ជនបទ និង80% នៅទីក្រុង (គោលដៅ7.10 និង 7.11) (Levisay & Sameth, 2006)។ ការសន្និដ្ឋានរបស់ធនាគារពិភពលោក (World Bank, n.d.) បង្ហាញថាកម្ពុជាបានសម្រេចផែនការ MDGs លើគោលដៅផ្គត់ផ្គង់ទឹក ហើយបានឈានឆ្ពោះទៅរកគោលដៅទឹកស្អាត។ ផែនការអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិ 2019-2023 បានបង្ហាញលទ្ធផលថាការផ្គត់ផ្គង់ទឹកក្នុងទីក្រុងមានចំនួន 88.01% ក្នុងឆ្នាំ2015 លើសពីគោលដៅ (លើស 80%) ខណៈការផ្គត់ផ្គង់ទឹកជនបទសម្រេចបាន50% ដូចគោលដៅ (Royal Government of Cambodia, 2019)។ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់យុទ្ធសាស្ត្រជាតិស្តីពីវិស័យផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យជនបទ 2011-2025។ គោលបំណងនៃយុទ្ធសាស្ត្រនេះស្ថិតត្រង់ការកំណត់ឱ្យបាននូវសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទសម្រាប់ពលរដ្ឋរស់នៅតាមជនបទនិងកំណត់ឱ្យមានរៀបចំស្ថាប័នធនធានហិរញ្ញវត្ថុ ធនធានមនុស្សព្រមទាំងធនធានដ៏ទៃទៀតដែលចាំបាច់ដើម្បីផ្តល់សេវាកម្មទាំងនេះប្រកបដោយនិរន្តរភាព។ គោលបំណងសំខាន់នៃយុទ្ធសាស្ត្រគឺដើម្បីពន្លឿនដំណើរការនេះដើម្បីឆ្ពោះទៅសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កម្ពុជា ឆ្នាំ2015 និង

សម្រេចបាននូវទស្សនវិស័យរបស់វិស័យផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ ឆ្នាំ2025 (Ministry of Rural Development, 2011)។

ទោះបីជាប្រទេសកម្ពុជាមានសេដ្ឋកិច្ចរីកចម្រើនប្រចាំឆ្នាំក៏ដោយ ផលិតផលក្នុងស្រុកសរុបសម្រាប់ប្រជាជនម្នាក់នៅតែទាបបើធៀបនឹងប្រទេសជិតខាង ហើយលទ្ធភាពទទួលបានហិរញ្ញប្បទានសមរម្យសម្រាប់ទឹក និងទឹកស្អាតនៅតែជាឧបសគ្គសម្រាប់គ្រួសារដែលត្រូវការតភ្ជាប់ទឹក និងបង្គន់សម្រាប់ផ្ទះរបស់ពួកគេ (water.org, 2019)។ យោងតាមអង្គការយូនីសេហ្វ ការបង្កើនការប្តេជ្ញាចិត្ត និងការវិនិយោគក្នុងការលើកកម្ពស់គុណភាពទឹកនៅជនបទ មិនត្រឹមតែធានាថា មនុស្សគ្រប់រូបមានទឹក និងទឹកស្អាតប៉ុណ្ណោះទេ ថែមទាំងជួយពន្លឿនការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមរបស់កម្ពុជាផងដែរ (UNICEF, n.d.)។

## ១.២. ចំណោទបញ្ហាស្រាវជ្រាវ

ប្រទេសកម្ពុជាមានចំណាត់ថ្នាក់លេខ140 ជាប្រទេសងាយរងគ្រោះដោយការប្រែប្រួលអាកាសធាតុ (World Bank & Asian Development Bank, 2021)។ ហេតុនេះ កម្ពុជាងាយប្រឈមមុខនឹងគ្រោះធម្មជាតិដូចជាទឹកជំនន់ គ្រោះរាំងស្ងួត ខ្យល់ព្យុះ (Ministry of Environment, 2020)។ ទោះបីជាប្រទេសកម្ពុជាមានប្រភពទឹកច្រើនក៏ដោយ លទ្ធភាពទទួលបានទឹក និងគុណភាពទឹកគឺជាបញ្ហាប្រឈមដ៏សំខាន់ ជាពិសេសសម្រាប់ប្រជាជនក្រីក្រនៅតាមជនបទ (Pink, 2016)។ ប្រជាជនកម្ពុជាប្រមាណ4លាននាក់ ក្នុងចំណោមប្រជាជនសរុបនៅខ្វះទឹកស្អាតប្រើប្រាស់ ហើយប្រហែល6លាននាក់ទៀត នៅខ្វះលទ្ធភាពទទួលបានទឹកស្អាតមានលក្ខណៈប្រសើរ។ កម្ពុជាមានប្រជាជនប្រមាណ 80% រស់នៅក្នុងតំបន់ជនបទ ហេតុនេះកង្វះខាតលទ្ធភាពទទួលបានទឹកមានសុវត្ថិភាព និងអនាម័យបានបន្តប៉ះពាល់ដល់សហគមន៍ជនបទកម្ពុជា (Water.org, 2019)។ បើគ្មានទឹកស្អាតនិងអនាម័យគ្រប់គ្រាន់នោះទេ កុមារកម្ពុជា (ប្រមាណ41ភាគរយនៃចំនួនប្រជាជនសរុប) ងាយរងគ្រោះដោយជំងឺដែលបណ្តាលមកពីទឹក។ ឧទាហរណ៍ ជំងឺរាករូសគឺជាមូលហេតុចម្បងទីពីរនៃការស្លាប់របស់កុមារដែលមានអាយុក្រោម5ឆ្នាំ ខណៈដែលកង្វះវីតាមីន និងសារជាតុរ៉ែ ដោយសារជំងឺរាករូសនាំឱ្យខាតបង់ថវិកាប្រចាំឆ្នាំចំនួន146លានដុល្លារអាម៉េរិក ដល់ផលិតផលក្នុងស្រុកសរុបរបស់ប្រទេសកម្ពុជា (UNICEF, n.d, as cited in OpenDevelopment Cambodia, 2014)។ លើសពីនេះ វាបង្កផលប៉ះពាល់ដល់សុខភាព និងស្ថានភាពហិរញ្ញវត្ថុរបស់គ្រួសារជនបទដែលរស់នៅជិត ឬក្រោមបន្ទាត់នៃភាពក្រីក្រ។ ភាពខុសគ្នានៃលទ្ធភាពទទួលបានទឹកស្អាត និងអនាម័យរវាងតំបន់ទីក្រុង និងទីជនបទក្នុងចំណោមក្រុមប្រជាជនមានកម្រិតជីវភាពខុសៗគ្នាត្រូវបានរកឃើញ។ ដោយយោងទៅលើបញ្ហានោះ ធនាគារអភិវឌ្ឍន៍អាស៊ី (Asian Development Bank, 2012) បានរាយការណ៍ថាប្រជាជនកម្ពុជារស់នៅក្នុងទីក្រុងមានលទ្ធភាពទទួលបានទឹកស្អាតច្រើនជាងប្រជាជនរស់នៅជនបទដល់ទៅបីដង។ ជាលទ្ធផលការផ្គត់ផ្គង់ទឹកស្អាតចាំបាច់ជាសេវាកម្មមានអាទិភាពខ្ពស់បំផុតមួយសម្រាប់ប្រជាជនគោលដៅរស់នៅតាមតំបន់ទីជនបទក្នុងប្រទេសកម្ពុជា។

នៅកម្ពុជាទោះបីជាការផ្គត់ផ្គង់ទឹកលើដី និងផ្ទៃទឹកមានច្រើននៅតំបន់ជាច្រើន គេបានរកឃើញបញ្ហានៃភាពកង្វក់ និងបំពុលដោយសារជាតុអាសេនិក ដែក និងនីត្រាតនៃទឹកក្រោមដី ឬដោយបាក់តេរី និងថ្នាំសម្លាប់សត្វល្អិត

ដែលមានន័យថាគុណភាពទឹកអាចមានបញ្ហា ហើយមានន័យប្រហែលពាក់កណ្ដាលនៃប្រជាជននៅតាមជនបទនៅតែខ្វះលទ្ធភាពទទួលការផ្គត់ផ្គង់ទឹកមានសុវត្ថិភាពត្រឹមត្រូវ (Lo & Gould, 2015)។

### ១.៣. វត្ថុបំណងស្រាវជ្រាវ

ការសិក្សានេះផ្ដោតទៅលើការប្រើប្រាស់ទឹក (ទឹកសម្រាប់ទទួលទាន និងទឹកសម្រាប់ប្រើប្រាស់ទូទៅ) នៅក្នុងគ្រួសាររបស់ប្រជាពលរដ្ឋកម្ពុជានៅក្នុងតំបន់ដាច់ស្រយាលមួយនៃខេត្តព្រះវិហារ ប្រទេសកម្ពុជា។ ជាមួយនឹងគោលបំណងនេះ ការសិក្សាផ្ដោតទៅលើវត្ថុបំណងចំនួនបីដូចខាងក្រោម៖

- សិក្សាអំពីប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ
- សិក្សាអំពីវិធានអនាម័យទឹកមុនពេលប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ
- សិក្សាអំពីឥរិយាបថ/ទស្សនៈរបស់ប្រជាពលរដ្ឋទាក់ទងនឹងទឹកសម្រាប់ប្រើប្រាស់ក្នុងគ្រួសារប្រចាំថ្ងៃ

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាខ្នាតតូចនេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះ រួមបញ្ចូលនូវវិធីសាស្ត្របរិមាណវិស័យនិងវិធីសាស្ត្រគុណវិស័យ ដោយទិន្នន័យដែលទទួលបានពីក្រុមគោលដៅស្រាវជ្រាវមានប្រភពមកពីការសម្ភាសប្រើកម្រងសំណួរ semi-structured questionnaire[១] និងការធ្វើក្រុមពិភាក្សា (focus group discussion)។ ការសិក្សានេះធ្វើឡើងនៅក្នុងឃុំឆែប២ស្ថិតនៅភាគឦសាននៃស្រុកឆែប ខេត្តព្រះវិហារ និងមានចម្ងាយប្រមាណ75គីឡូម៉ែត្រពីទីរួមខេត្តព្រះវិហារ។ ឃុំឆែប២ ជាតំបន់ជនបទដាច់ស្រយាលមួយនៃប្រទេសកម្ពុជាដែលមានបួនភូមិគឺ ភូមិជងផ្លឹត, ភូមិណារ៉ុង, ភូមិគុណភាព១ និង ភូមិគុណភាព២[២]។

### ២.១. សំណាកស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានការចូលរួមពីបុគ្គលគោលដៅស្រាវជ្រាវចំនួន61នាក់ ដែលជ្រើសរើសតាមវិធីងាយស្រួល (convenient sampling technique)។ សមាសភាពបុគ្គលគោលដៅស្រាវជ្រាវត្រូវបានបែងចែកជាពីរក្រុមផ្អែកទៅលើវិធីប្រមូលទិន្នន័យដូចតារាងខាងក្រោម៖

---

[១] គួរបញ្ជាក់ថា ពាក្យ "semi-structured questionnaire" ពុំទាន់មានការបង្កើតមេពាក្យឱ្យត្រូវនឹងពាក្យនេះ ហើយការប្រើប្រាស់ក៏មិនទាន់មានការឯកភាព ដូចនេះ អ្នកស្រាវជ្រាវជ្រើសរើសការរក្សាសំនួរដើមជាភាសាអង់គ្លេសដើម្បីជៀសវាងការយល់ច្រឡំនានា។

[២] អ្នកស្រុកជនជាតិដើមភាគតិចនៅក្នុងភូមិស្គាល់ភូមិនេះច្បាស់ក្នុងឈ្មោះ "ភូមិប្រា" ប៉ុន្តែក្រោយមកត្រូវបានរាជរដ្ឋាភិបាលសម្រេចដាក់ឈ្មោះជាផ្លូវការថា "ភូមិគុណភាព២" វិញ។

តារាងទី1

*សមាសភាពក្រុមគោលដៅស្រាវជ្រាវដែលបានចូលរួមក្នុងការសិក្សា*

| ល.រ | ក្រុមគោលដៅ(ក្រុមពិភាក្សា) | ចំនួន |
|---|---|---|
| 1 | មេឃុំ អនុឃុំ និងស្មៀនឃុំ | 3 |
| 2 | មេភូមិ ឬអនុភូមិ | 4 |
| 3 | ថ្នាក់ដឹកនាំសាលា | 2 |
| 4 | គ្រូបង្រៀន | 2 |
| 5 | ប្រជាពលរដ្ឋមេគ្រួសារ | 5 |
| | សរុប | 16 |

| ល.រ | ក្រុមគោលដៅ (ការសម្ភាស) | ចំនួន |
|---|---|---|
| 1 | ប្រជាពលរដ្ឋរស់នៅក្នុងសហគមន៍ និងសមាជិកផ្សេងទៀតក្នុងគ្រួសារ | 45 |

### ២.២. ការប្រមូលនិងវិភាគទិន្នន័យ

ទិន្នន័យសម្រាប់ការស្រាវជ្រាវនេះទទួលបានពីវិធីប្រមូលទិន្នន័យពីរយ៉ាងគឺ ការសម្ភាសនិងការធ្វើក្រុមពិភាក្សា និងប្រើប្រាស់ឧបករណ៍ស្រាវជ្រាវពីរប្រភេទគឺ កម្រងសំណួរ semi-structured questionnaire សម្រាប់ប្រមូលទិន្នន័យតាមការសម្ភាស និងបញ្ជីសំណួរគន្លឹះ (guiding questions) សម្រាប់ប្រមូលទិន្នន័យតាមក្រុមពិភាក្សា។ ទិន្នន័យដែលទទួលបានពីកម្រងសំណួរត្រូវបានបញ្ចូលនិងវិភាគដោយប្រើប្រាស់កម្មវិធីវិភាគស្ថិតិ SPSS និង វិធីវិភាគទិន្នន័យបែបពណ៌នាត្រូវបានប្រើប្រាស់ដើម្បីបង្ហាញលទ្ធផលជាទម្រង់តារាងស្ថិតិ និងក្រាហ្វិកស្ថិតិនានា។ ដោយឡែកទិន្នន័យដែលទទួលបានពីការធ្វើក្រុមពិភាក្សាត្រូវបានវិភាគដោយប្រើវិធីវិភាគកំណត់ទីសេចក្ដី (content analysis[៣]) ដើម្បីយកជាលទ្ធផលបន្ថែមសម្រាប់គាំទ្រ ឬបដិសេធលទ្ធផលដែលទទួលបានពីវិធីសាស្ត្របរិមាណវិស័យ។

## ៣. លទ្ធផលស្រាវជ្រាវ

### ៣.១. ព័ត៌មានអំពីក្រុមគោលដៅ

ការសិក្សានេះមានការចូលរួមពីក្រុមគោលដៅស្រាវជ្រាវចំនួន61នាក់ ដែលក្នុងនោះ ប្រជាពលរដ្ឋចំនួន45នាក់បានចូលរួមក្នុងការសម្ភាស។ ទិន្នន័យក្នុងតារាងទី2ខាងក្រោមបានបង្ហាញថា 82.8% នៃប្រជាពលរដ្ឋនៃក្រុមគោលដៅដែលបានចូលរួមសម្ភាស ទទួលបានការសិក្សាត្រឹមកម្រិតបឋមសិក្សានិងមិនបានចូលសិក្សាទាល់តែសោះ ដោយឡែកភរិយាឬស្វាមីរបស់គាត់ ដែលទទួលបានការសិក្សាក្នុងកម្រិតដូចគ្នានេះមានរហូតដល់ 90%។ បន្ថែមពីលើនេះ កូនៗរបស់គាត់ដែលមានការសិក្សាខ្ពស់បំផុតត្រឹមកម្រិតបឋមសិក្សាមានរហូតដល់ 79.1% ស្របពេលដែលអ្នកដែលទទួលបានការសិក្សាដល់កម្រិតវិទ្យាល័យមានត្រឹមតែ 8.3% ប៉ុណ្ណោះ។

[៣] ចំពោះបច្ចេកសព្ទ content analysis ដែលមានន័យជាភាសាខ្មែរថា ការវិភាគកំណត់ទីសេចក្ដី មិនទាន់ត្រូវបានអនុម័តប្រើប្រាស់ជាផ្លូវការ ឬមានការឯកភាពក្នុងចំណោមអ្នកស្រាវជ្រាវនៅឡើយទេ ដោយឡែក ក្នុងការសិក្សានេះ អ្នកស្រាវជ្រាវជ្រើសរើសប្រើប្រាស់បែបនេះ ហើយមេពាក្យនេះអាចនឹងមានការប្រែប្រួលនៅពេលក្រោយ។

តារាងទី2

*កម្រិតសិក្សារបស់ប្រជាពលរដ្ឋដែលបានចូលរួមក្នុងការសម្ភាស និងសមាជិកផ្សេងទៀត*

| | អ្នកចូលរួម | ប្ដី/ប្រពន្ធ | កូន[៤] |
|---|---|---|---|
| មិនបានសិក្សា | 25.7 | 20.0 | 20.8 |
| បឋមសិក្សា | 57.1 | 70.0 | 58.3 |
| អនុវិទ្យាល័យ | 8.6 | 6.7 | 12.5 |
| វិទ្យាល័យ | 8.6 | 3.3 | 8.3 |
| សរុប | 100.0 | 100.0 | 100.0 |

ពាក់ព័ន្ធនឹងការងារនិងមុខរបរចិញ្ចឹមជីវិត ទិន្នន័យក្នុងរូបភាពទី1បង្ហាញថា ប្រជាពលរដ្ឋប្រមាណ 67.6% ប្រកបមុខរបរជាកសិករ 14.7 ប្រកបមុខរបរលក់ដូរបន្តិចបន្តួចតាមផ្ទះ ស្របពេលដែលប្រជាពលរដ្ឋដែលជាមន្ត្រីរាជការមានតែ 11.8 % ប៉ុណ្ណោះ។ បើគិតទាំងមុខរបរបន្ទាប់បន្សំ (រូបភាពទី2) ប្រជាពលរដ្ឋប្រមាណជិត 96% ប្រកបមុខរបរជាកសិករ។ តាមទិន្នន័យពីផែនការបីឆ្នាំរំកិលរបស់ឃុំឆែប២ បានបញ្ជាក់ថា ប្រជាពលរដ្ឋនៅក្នុងឃុំឆែប២ប្រមាណ 95% ប្រកបមុខរបរជាកសិករដែលទិន្នន័យនេះមានចំនួនប្រហាក់ប្រហែលគ្នា។

រូបភាពទី1

*មុខរបរចម្បងរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ*




បើគិតទាំងមុខរបរចម្បងនិងមុខរបរបន្ទាប់បន្សំ មានប្រជាពលរដ្ឋប្រមាណ 41.9% ប្រកបមុខរបរជាអ្នកប្រមូលអនុផលពីព្រៃឈើនៅជុំវិញសហគមន៍របស់ពួកគាត់ ក្នុងនោះមានដូចជា ការរកជ័រឈើ និងជ័រទឹកជាដើម។ បន្ថែមពីលើនេះ ទិន្នន័យបានបង្ហាញថា ប្រជាពលរដ្ឋប្រមាណ 8 % ប្រកបមុខរបរដែលបង្កជាហានិភ័យដល់ធនធានធម្មជាតិដូចជាការបរបាញ់សត្វព្រៃ(4%) និងការកាប់/អារឈើខុសច្បាប់(4%)។

[៤] កូននៅក្នុងចំណុចនេះ សំដៅដល់កូនដែលទទួលបានការអប់រំខ្ពស់បំផុត

រូបភាពទី2

*មុខរបរបន្ទាប់បន្សំរបស់ប្រជាពលរដ្ឋរស់នៅក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ*




## ៣.២. ប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃ

តារាងទី3ខាងក្រោមបង្ហាញលទ្ធផលស្រាវជ្រាវអំពីប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋនៅក្នុងឃុំឆែប២ទាំងនៅក្នុងរដូវវស្សានិងរដូវប្រាំង។ លទ្ធផលបង្ហាញថា ទឹកដែលយកចេញពីអណ្តូងដៃ[៥] ដែលប្រជាពលរដ្ឋបានជីកនៅតាមមាត់អូរ ប្រឡាយ ឬតាមទីទំនាបនានានៅក្នុងភូមិឃុំ គឺជាប្រភពទឹកដ៏សំខាន់ជាងគេសម្រាប់ទទួលទានប្រចាំថ្ងៃ។ នៅក្នុងរដូវវស្សា ទិន្នន័យបង្ហាញថា 32.4% នៃទឹកដែលប្រជាពលរដ្ឋបរិភោគប្រចាំថ្ងៃ យកចេញពីអណ្តូងដៃ ដោយឡែកនៅរដូវប្រាំងវិញ ការបរិភោគទឹកចេញពីប្រភពមួយនេះមានការកើនឡើងរហូតដល់ 38.5%។

តារាងទី3

*របាយទិន្នន័យលទ្ធផលអំពីប្រភពទឹកប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងឃុំឆែប2 ខេត្តព្រះវិហារ*

| ទឹកសម្រាប់បរិភោគ | | | ទឹកសម្រាប់ប្រើប្រាស់ទូទៅ | | |
|---|---|---|---|---|---|
| ប្រភពទឹក | រដូវវស្សា | រដូវប្រាំង | ប្រភពទឹក | រដូវវស្សា | រដូវប្រាំង |
| ប្រភពធម្មជាតិ (អូរ បឹង...) | 1.5% | 1.9% | ប្រភពធម្មជាតិ (អូរ បឹង...) | 4.2% | 2.5% |
| អណ្តូងស្នប់(ជីកដោយដៃ) | 16.2% | 28.8% | អណ្តូងស្នប់(ជីកដោយដៃ) | 58.3% | 80.0% |
| អណ្តូងជីកមានគម្របបិទ | 2.9% | 3.8% | អណ្តូងជីក(ដៃ) មានគម្រប | 0.0% | 2.5% |
| ទឹកភ្លៀង | 27.9% | 0.0% | អណ្តូងជីក(ដៃ) គ្មានគម្រប | 2.1% | 2.5% |

---

[៥] គួរបញ្ជាក់ថា រូបភាពអណ្តូងដៃរបស់អ្នកស្រុកក្នុងឃុំឆែប២ អាចមានរូបសណ្ឋានខុសប្លែកពីអណ្តូងរបស់ប្រជាពលរដ្ឋនៅតាមតំបន់ជាច្រើនក្នុងប្រទេសកម្ពុជា ដោយអណ្តូងដៃសម្រាប់អ្នកស្រុកក្នុងឃុំឆែប២ អាចគ្រាន់តែជាថ្លុកទឹក ឬរណ្តៅទឹក សម្រាប់អ្នកស្រុកនៅតំបន់ផ្សេង។ សូមមើលរូបភាពទី3និងទី4 និងរូបក្នុងតារាងទី4 ខាងក្រោមសម្រាប់ទិដ្ឋភាពអណ្តូងដៃរបស់អ្នកស្រុកក្នុងឃុំឆែប២។

| | | |
|---|---|---|
| ទឹកប្រកធុងតូចៗ | 19.1% | 26.9% |
| អណ្តូងដៃ | 32.4% | 38.5% |
| *សរុប* | 100.0% | 100.0% |

| | | |
|---|---|---|
| ទឹកភ្លៀង | 27.1% | 0.0% |
| ទឹកប្រកធុងតូចៗ | 2.1% | 2.5% |
| អណ្តូងដៃ | 6.3% | 10.0% |
| *សរុប* | 100.0% | 100.0% |

ទឹកភ្លៀង ទឹកប្រកក្នុងជប/ធុងតូចៗ និងទឹកយកចេញពីអណ្តូងស្នប់ជីកដោយដៃ គឺជាប្រភពទឹកសម្រាប់ទទួលទានសំខាន់ផ្សេងទៀតនៅរដូវវស្សា ដែលក្នុងនោះ ទឹកភ្លៀងមាន 27.9% ទឹកប្រកធុង 19.1% និងទឹកដែលយកចេញពីអណ្តូងស្នប់មានប្រមាណ 16.2%។ ដោយឡែកក្នុងរដូវប្រាំង ក្រៅពីទឹកដែលយកចេញពីអណ្តូងដៃ លទ្ធផលបានបង្ហាញថា ប្រជាពលរដ្ឋទទួលទានទឹកដែលយកចេញពីអណ្តូងស្នប់ (28.8%) និងទឹកប្រកធុងតូចៗលក់តាមផ្សារ (26.9%)។

រូបភាពទី3និងទី4

*សកម្មភាពប្រជាពលរដ្ឋក្នុងឃុំឆែប២ ខេត្តព្រះវិហារដងទឹកចេញពីអណ្តូងដៃដើម្បីយកទៅប្រើប្រាស់*





ដោយឡែក ប្រភពទឹកសម្រាប់ប្រើប្រាស់ទូទៅប្រចាំថ្ងៃក្នុងគោលបំណងផ្សេងទៀតដូចជា បោកគក់ ងូត ដាំស្ល ជាដើម នៅក្នុងរដូវវស្សា ប្រជាពលរដ្ឋយកទឹកចេញពីប្រភពផ្សេងៗដូចជា អណ្តូងស្នប់(ជីកដោយដៃ) ប្រមាណ 58.3% និងទឹកភ្លៀង 27.1%។ ចំណែកក្នុងរដូវប្រាំងវិញ 80% នៃទឹកសម្រាប់ប្រើប្រាស់ទូទៅរបស់ប្រជាពលរដ្ឋមានប្រភពមកពីអណ្តូងស្នប់(ជីកដោយដៃ) និងអណ្តូងដៃ ប្រមាណ 10%។ ក្រៅពីនេះ ប្រជាពលរដ្ឋប្រមាណ 10% ក្នុងឃុំឆែប២ ក៏ស្វែងរកទឹកដើម្បីប្រើប្រាស់ទូទៅចេញពីកន្លែងផ្សេងទៀតដូចជាអូរក្បែរភូមិជាដើម[៦]។

[៦] គួរបញ្ជាក់ថា ស្ថានភាពទឹកក្នុងអូរក្បែរភូមិរបស់ប្រជាពលរដ្ឋមានការរីងស្ងួតដោយអន្លើៗ ដូចនេះ ក្នុងភូមិខ្លះប្រជាពលរដ្ឋពុំអាចទាញយកទឹកពីអូរមកប្រើប្រាស់បាននោះទេ។ ជាក់ស្តែង នៅក្នុងរដូវប្រាំង មានតែប្រជាពលរដ្ឋរស់នៅខ្សែទឹកខាងក្រោមដែលមានជម្រៅជ្រៅៗទើបមានទឹកអូរប្រើប្រាស់។

តារាងទី4

*រូបភាពបង្ហាញអំពីប្រភពទឹកសម្រាប់ប្រើប្រាស់ប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ*

| | | |
|---|---|---|
| អណ្ដូងដៃ | អណ្ដូងប្រភេទនេះ ប្រជាពលរដ្ឋនិយមជីកក្បែរៗមាត់អូរ ឬប្រឡាយដើម្បីយកទឹកពីក្នុងដី ឬទឹកដែលជ្រាបចេញពីអូរ ឬប្រឡាយ។ ពេលខ្លះវាត្រូវបានគេជីកនៅតាមទីទំនាបដែលមានទឹកដក់ផងដែរ។ មុខកាត់របស់វាអាចនៅចន្លោះ 0.5ម៉ែត្រ - 0.8ម៉ែត្រ និងមានជម្រៅអាចលើសពី1.5ម៉ែត្រ។ |    |
| អណ្ដូងស្នប់ (ជីកដោយដៃ) | អណ្ដូងប្រភេទនេះត្រូវបានជីកដោយដៃ និងមានមុខកាត់ចន្លោះពី 1ម៉ែត្រ-1.3ម៉ែត្រ។ ក្រោយពីជីកហើយប្រជាពលរដ្ឋបានដាក់ស្នប់ដៃមួយពីលើដើម្បីទាញយកទឹកពីក្នុងអណ្ដូងដើម្បីប្រើប្រាស់។ |  |
| អណ្ដូងជីកដោយដៃ | ជាប្រភេទអណ្ដូងដូចអណ្ដូងស្នប់ដែរ ប៉ុន្តែខុសគ្នាប្រជាពលរដ្ឋទាញយកទឹកពីអណ្ដូងនេះដោយប្រើយោងឬធុងតូចៗចងជាប់នឹងខ្សែវែងទម្លាក់ចុះក្នុងអណ្ដូង។ នៅតាមតំបន់ខ្លះ ប្រជាពលរដ្ឋដាក់លូតូចៗច្រើនកង់ទៅក្នុងអណ្ដូងដើម្បីការពារការបាក់ដីលុប និង អាចមានគម្របឬអត់មានគម្របការពារ។ |   |
| ទឹកប្រកក្នុងធុងតូចៗ | ជាប្រភេទទឹកដែលប្រកដាក់ធុងតូចៗមានចំណុះ20លីត្រដាក់លក់នៅតាមទីផ្សារឬតូបលក់ឥវ៉ាន់តាមភូមិ។ |  |
| អណ្ដូងស្នប់ (ម៉ាស៊ីន) | ជាប្រភេទអណ្ដូងដែលត្រូវបានជីកដោយប្រើម៉ាស៊ីនបុកនិងភ្ជាប់ស្នប់នៅខាងលើ (អាចជាស្នប់ដៃ ឬម៉ូទ័របូម) ដើម្បីទាញយកទឹកមកប្រើប្រាស់។ |  |

បន្ថែមពីលើការវិភាគទិន្នន័យបរិមាណវិស័យ លទ្ធផលចេញពីក្រុមពិភាក្សាបានបង្ហាញថា នៅក្នុងរដូវវស្សាឬដើមរដូវប្រាំងនៅពេលដែលទឹកសម្បូរ ប្រជាពលរដ្ឋនិយមប្រើប្រាស់ទឹកចេញពីអណ្តូងដៃច្រើនជាងគេ ដែលកត្តានេះអាចពាក់ព័ន្ធនឹងវប្បធម៌ និងទម្លាប់តៗគ្នារាប់ជំនាន់មកហើយរបស់អ្នកស្រុកនៅក្នុងតំបន់នេះ។ ពួកគាត់បានគូសបញ្ជាក់ថា ទឹកដែលយកចេញពីអណ្តូងដៃមានរសជាតិផ្អែម ឆ្ងាញ់ជាងទឹកអណ្តូងស្នប់ ឬទឹកច្រកធុងលក់តាមផ្សារ។ ទោះជាយ៉ាងណា ការទាញយកទឹកចេញពីប្រភពទាំងនេះក៏អាស្រ័យលើស្ថានភាពជាក់ស្តែងនៃបរិមាណទឹកតាមរដូវកាល ស្ថានភាពជីវភាពគ្រួសារ ទីតាំងរស់នៅ និងកម្រិតការយល់ដឹងពីជំងឺដែលអាចកើតមានចេញពីការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋផងដែរ។ ដោយសារតែកន្លងមក ធ្លាប់មានអង្គការ និងមន្ត្រីសុខាភិបាលចុះមកជួយណែនាំទាក់ទងនឹងជំងឺ ឬផលវិបាកនានាដែលកើតឡើងចេញពីការទទួលទានទឹក នោះទម្លាប់នៃការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋមានការប្រែប្រួលច្រើន ជាពិសេសទឹកសម្រាប់ទទួលទាន។

បើប្រៀបធៀបទៅលើពណ៌ទឹកដែលយកចេញពីអណ្តូងដៃ នោះមានសភាពពណ៌លឿងៗបន្តិច និងខ្លះទៀតឡើងសៗ (រូបភាពទី5)។ ជាក់ស្តែង នៅក្នុងវិសាលភាពនៃការសិក្សានេះ យើងពុំបានធ្វើពិសោធន៍ពិនិត្យមើលទៅលើសារធាតុដែលមាននៅក្នុងទឹកនេះនោះទេ។

រូបភាពទី5

*សំណាកគំរូទឹកដែលដងចេញពីរណ្តៅជីកដោយដៃតាមប្រឡាយដងផ្លូវនិងបាតអូរក្បែរភូមិ*





## ៣.៣. វិធានអនាម័យទឹក

លទ្ធផលនៅក្នុងផ្នែកនេះ បង្ហាញអំពីវិធានអនាម័យទឹកដែលប្រជាពលរដ្ឋអនុវត្តមុននឹងប្រើប្រាស់ទឹកជាក់ស្តែងទាំងក្នុងវត្ថុបំណងទទួលទាន និងប្រើប្រាស់ទូទៅ។ លទ្ធផលចេញពីការស្រាវជ្រាវបង្ហាញថា មានប្រជាពលរដ្ឋលើសពី 65% ទទួលទានទឹកដោយពុំបានប្រើប្រាស់វិធានអនាម័យទាល់តែសោះ នេះមានន័យថា ពួកគាត់ទទួលទានទឹកដោយផ្ទាល់តែម្តងនៅពេលដែលយកវាចេញពីប្រភពផ្សេងៗ ដូចបានបង្ហាញខាងលើ។ ក្នុងករណីនេះ ទិន្នន័យបង្ហាញថា មានប្រជាពលរដ្ឋតែ 25.6% ប៉ុណ្ណោះដែលបានដាំទឹកឱ្យពុះមុននឹងទទួលទាន ដោយឡែក 9.3% ទៀតប្រើប្រាស់វិធីចម្រោះទឹកមុននឹងទទួលទាន។ ជាមួយនឹងវិធីអនាម័យទឹកនេះ លទ្ធផលចេញពីទិន្នន័យក្រុមពិភាក្សាបានបង្ហាញថា មូលហេតុដែលប្រជាពលរដ្ឋមិននិយមដាំ ឬចម្រោះទឹកមុនទទួលទានព្រោះវាបានធ្វើឱ្យបាត់បង់នូវរសជាតិផ្អែម ឆ្ងាញ់របស់ទឹកធម្មជាតិដែលគាត់និយមទទួលទាន។ ទោះជាយ៉ាងណា ប្រជាពលរដ្ឋមួយចំនួនដែលមានការបារម្ភពីបញ្ហាសុខភាព បានដាំ ឬចម្រោះវាមុននឹងទទួលទាន។

រូបភាពទី6

*វិធានអនាម័យគុណភាពទឹកមុនពេលប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងឃុំធែប2*




បញ្ហាចម្បងមួយទៀត គឺការរក្សាទឹកទុកប្រើប្រាស់ ដោយប្រជាពលរដ្ឋនៅក្នុងឃុំធែប២ រក្សាទឹកទុកប្រើប្រាស់ដោយពុំសូវគិតគូរអំពីអនាម័យនោះទេ ដោយឧបករណ៍រក្សាទឹកទុកភាគច្រើនពុំសូវមានអនាម័យ ឬពុំមានគម្របត្រឹមត្រូវ ដែលអាចនឹងងាយឆ្លងរោគនានាចូលទៅក្នុងទឹកបាន។

តារាងទី5

*ឧបករណ៍រក្សាទឹកទុកប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងឃុំធែប២*

| ប្រភេទឧបករណ៍រក្សាទឹក | ទឹកសម្រាប់ទទួលទាន | ទឹកប្រើប្រាស់ទូទៅ |
|---|---|---|
| ពាងទឹកមានគម្របគ្រប | 12.2% | 18.4% |
| ពាងទឹកគ្មានគម្របគ្រប | 16.3% | 39.5% |
| ប៊ីដុងទឹក | 51.0% | 31.6% |
| សំណង់លូឬលូស៊ីម៉ង់ត៍ | 0.0% | 2.6% |
| ធុងទឹកជ័រ | 20.4% | 7.9% |
| *សរុប* | 100.0% | 100.0% |

លទ្ធផលបានបង្ហាញថា មានប្រជាពលរដ្ឋប្រមាណជា 16.3% អនុវត្តការរក្សាទឹកទទួលទានក្នុងពាងដែលពុំមានគម្របត្រឹមត្រូវ ហើយប្រជាពលរដ្ឋរហូតដល់ 39.5% រក្សាទឹកសម្រាប់ប្រើប្រាស់ទូទៅទុកក្នុងពាងដូចគ្នា។ ការរក្សាទឹកទុកទទួលទាន ភាគច្រើន (51%) ត្រូវបានរក្សាទុកក្នុងប៊ីដុងដែលមានចំណុះ20ទៅ30លីត្រ។ តារាងទី6 ខាងក្រោមបង្ហាញពីប្រភេទឧបករណ៍រក្សាទឹកទុកប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងឃុំធែប២។

តារាងទី6

*ឧបករណ៍រក្សាទឹកទុកប្រើប្រាស់របស់ប្រជាពលរដ្ឋក្នុងឃុំផែប២*

| | | |
|---|---|---|
| ពាងទឹកមាន គម្របគ្រប | ពាងប្រពៃណីដែលខ្មែរប្រើប្រាស់សម្រាប់ស្តុកទឹក ហើយវាត្រូវបានគ្របដើម្បីសុវត្ថិភាព។ |  |
| ពាងគ្មានគម្របការពារ | ពាងប្រពៃណីខ្មែរប្រើសម្រាប់ស្តុកទឹក មិនមានគម្របបាំង និងងាយធ្វើឱ្យទឹកកខ្វក់។ |  |
| ប៊ីដុងទឹក | ឧបករណ៍ប្លាស្ទិកប្រភេទនេះមានទំហំមធ្យមនិងប្រើស្តុកទឹកពិសារដែលលក់ដូរនៅតាមតូបឬទីផ្សារក្នុងភូមិ។ |   |
| សំណង់លូ សម្រាប់រក្សាទឹក | កន្លែងស្តុកទឹកមានកម្ពស់ខ្ពស់និងត្រូវបានផលិតពីស៊ីម៉ងត៍។ |  |
| ធុងទឹកជ័រ | ក្នុងបរិបទនៅតំបន់សិក្សានេះ ធុងទឹកជ័រផ្លាស្ទិកត្រូវបានប្រើប្រាស់ដើម្បីដាក់ទឹកពីប្រភពនៅក្បែរៗ។ |   |

## ៣.៤. ឥរិយាបថប្រជាពលរដ្ឋចំពោះទឹកប្រើប្រាស់

តារាងទី7

*ទស្សនៈរបស់ប្រជាពលរដ្ឋក្នុងឃុំផែប២ទាក់ទងទៅនឹងគុណភាពនិងអនាម័យទឹកប្រើប្រាស់ប្រចាំថ្ងៃ*

| | កម្រិតអនាម័យនិងគុណភាពទឹក | | | | |
|---|---|---|---|---|---|
| | ទាបខ្លាំង | ទាប | មធ្យម | ល្អ | ល្អណាស់ |
| តើអ្នកគិតថាទឹកដែលអ្នកបរិភោគប្រចាំថ្ងៃមានគុណភាពនិងអនាម័យកម្រិតណាដែរ? | 2.9% | 2.9% | 35.3% | 55.9% | 2.9% |
| តើអ្នកគិតថាគុណភាពទឹកបរិភោគដែលច្រកធុងឬប៊ីដុងលក់តាមផ្សារមានគុណភាពកម្រិតណាដែរ? | 0.0% | 11.4% | 48.6% | 40.0% | 0.0% |

| | | | | | |
|---|---|---|---|---|---|
| តើអ្នកគិតថាគុណភាពទឹកភ្លៀងសម្រាប់បរិភោគមានគុណភាពនិងអនាម័យកម្រិតណាដែរ? | 5.7% | 8.6% | 17.1% | 60.0% | 8.6% |
| តើអ្នកគិតថាទឹកដែលទទួលបានពីធុង/ឧបករណ៍ចម្រោះមានគុណភាពនិងអនាម័យកម្រិតណា? | 0.0% | 13.8% | 41.4% | 37.9% | 6.9% |
| តើអ្នកគិតថាទឹកដែលញាតិជិតខាងរបស់អ្នកបរិភោគមានគុណភាពនិងអនាម័យកម្រិតណាដែរ? | 2.9% | 5.7% | 51.4% | 40.0% | 0.0% |

តារាងទី7ខាងលើបង្ហាញថា ប្រជាជនភាគច្រើន (55.9%) យល់ឃើញថាចំពោះគុណភាពនៃទឹកផឹកដែលខ្លួនប្រើប្រាស់ជារៀងរាល់ថ្ងៃគឺមានសុវត្ថិភាពនិងស្អាតល្អ។ មិនមានភាពខុសគ្នាច្រើនរវាងការយល់ឃើញរបស់ពួកគេអំពីគុណភាពនៃទឹកពីច្រកធុងលក់តាមផ្សារនិងទឹកដែលទទួលបានពីធុងឬឧបករណ៍ចម្រោះនោះទេ។ ទោះជាយ៉ាងណាលទ្ធផលគួរចាប់អារម្មណ៍ក៏បង្ហាញផងដែរថាពួកគេយល់ឃើញថាគុណភាពនិងអនាម័យទឹកភ្លៀងសម្រាប់បរិភោគ (60%) គឺល្អ និងខ្ពស់ជាងទឹកពីប្រភពផ្សេងទៀត។

## ៤. ការពិភាក្សា

យោងតាម Joint Monitoring Programme នៃអង្គការសុខភាពពិភពលោក និងយូនីសេហ្វ (WHO/UNICEF, 2012, as cited in Shaheed et al., 2013) សម្រាប់ការផ្គត់ផ្គង់ទឹកនិងទឹកអនាម័យបានបែងចែកប្រភេទប្រភពទឹកជា2គឺ៖ ទឹកមានលក្ខណៈប្រសើរ (improved water) ទឹកមិនមានលក្ខណៈប្រសើរ (unimproved water)។ ប្រភពទឹកមិនមានលក្ខណៈប្រសើរអាចមានលទ្ធភាពបង្កហានិភ័យសុខភាពអ្នកប្រើប្រាស់ (Shaheed et al., 2013)។ ក្នុងការសិក្សានេះគេឃើញថាប្រភពទឹកខ្លះដូចជា បឹង អូរ ទឹកច្រកធុងតូចៗ ដែលប្រជាពលរដ្ឋយកមកទទួលទាន និងប្រើប្រាស់ជាប្រចាំស្ថិតក្នុងប្រភេទដែលអាចបង្កការប៉ះពាល់ដល់សុខភាព ជាពិសេសអណ្ដូងដៃដែលជាប្រភពទឹកពេញនិយមជាងគេមួយក្នុងការទទួលទានដោយសារកត្តារស់ជាតិ និងទម្លាប់។ អណ្ដូងស្នប់ជីកដោយដៃក៏ជាប្រភពទឹកសម្រាប់ប្រើប្រាស់សំខាន់មួយផងដែរ ហើយវាអាចមានសុវត្ថិភាពជាងប្រភពដទៃ។ ទោះបីជាយ៉ាងណាដោយសារមិនទាន់មានទិន្នន័យលទ្ធផលពិសោធន៍ពីសារជាតុផ្ទុកផ្សេងៗដែលអាចមានក្នុងទឹកអណ្ដូងស្នប់ជីកដោយដៃដែលមានប្រភពពីទឹកក្រោមដី វាប្រហែលជាហានិភ័យមួយក្នុងចំណោមអ្នកប្រើប្រាស់។ កន្លងមកកម្មវិធីវាយតម្លៃមួយលើគុណភាពទឹកនៅតំបន់ជនបទកម្ពុជា ក៏ធ្លាប់បានបង្ហាញពីបញ្ហាសុខភាពច្រើនដោយសារទឹក (Pink, 2016) ដែលទាមទារការសិក្សាពិសោធន៍ពីទឹកឱ្យបានច្បាស់លាស់។ ក្រៅពីទម្លាប់ប្រពៃណីនៃការប្រើប្រាស់ប្រភពទឹកខាងលើ មូលហេតុចម្បងមួយទៀតគឺប្រហែលអាស្រ័យលើកម្រិតជីវភាពនៃប្រជាជនក្នុងឃុំធៃប២។ ដោយសារប្រជាជនជាង70%ប្រកបរបរកសិកម្ម និងអាស្រ័យផលព្រៃឈើ ហើយជីវភាពពលរដ្ឋភាគច្រើនគឺនៅមានកម្រិតទាប។ Pink (2016) ក៏បានបង្ហាញផងដែរថាភាពក្រីក្រអាចប៉ះពាល់ដល់សុខភាពរាងកាយ សុខភាពផ្លូវចិត្ត លទ្ធភាពទទួលបានទឹក គុណភាពទឹក និងសូចនាករជាច្រើនទៀតដែលចាំបាច់សម្រាប់ស្តង់ដារស់នៅដែលមានសុខភាពល្អនិងគ្រប់គ្រាន់។

ទោះបីជាទឹកភ្លៀងជាប្រភពទឹកដែលប្រើប្រាស់ច្រើនដោយប្រជាជនទាំងសម្រាប់ការទទួលទាន និងប្រើប្រាស់ក្នុងរដូវវស្សាក្នុងការសិក្សានេះ ការសិក្សាពីមុននៃការប្រមូលផលទឹកភ្លៀងបានកំណត់កត្តាហានិភ័យដែលប៉ះពាល់ដល់គុណភាពទឹកភ្លៀងដោយសារភាពកខ្វក់នៃដំបូល ក៏ដូចជាការផ្ទុកនិងការគ្រប់គ្រងដែលមិនមានសុវត្ថិភាព (Meera & Mansoor 2006; Fewtrell & Kay 2007; Kahinda et al., 2007; Ahmed et al., 2010, as cited in Shaheed, 2013)។ ការប្រមូលទឹក និងឧបករណ៍ស្តុកទឹកនៅតាមតំបន់ជនបទកម្ពុជាច្រើនតែមានលក្ខណៈមូលដ្ឋានធម្មតា ដូច្នេះហើយទើបធ្វើឱ្យប្រជាជនងាយប្រឈមនឹងជំងឺ (Pink, 2016)។ ហេតុនេះការថែរក្សាឧបករណ៍បែបប្រពៃណីក្នុងការប្រមូលផលទឹកភ្លៀងគួរត្រូវបានថែរក្សាសម្អាតឱ្យបានត្រឹមត្រូវ។ លើសពីនេះប្រព័ន្ធប្រមូលផលទឹកភ្លៀងថ្មីដែលស្របតាមលក្ខណៈបច្ចេកទេសត្រឹមត្រូវពិតជាមានសារៈសំខាន់និងគួរមាននៅតំបន់ឃុំឆែប២ ក្នុងការធានាគុណភាពទឹកភ្លៀងជូនប្រជាពលរដ្ឋជាពិសេសនៅទីសាធារណៈដូចជាសាលារៀន វត្តអារាម និង សាលាឃុំជាដើម។ លទ្ធផលនៃការស្ទង់មតិក៏បានបង្ហាញថា សហគមន៍ប្រជាជនប្រឈមនឹងគ្រោះរាំងស្ងួតស្ទើរតែរៀងរាល់ឆ្នាំ ដូចនេះការប្រមូលផលទឹកភ្លៀងពិតជាមានសារៈសំខាន់ ជាពិសេសសម្រាប់ប្រើប្រាស់ក្នុងរដូវប្រាំង។

លទ្ធផលខាងលើបានបង្ហាញថាភាគច្រើនប្រជាជនមានទស្សនថា កម្រិតអនាម័យនិងគុណភាពទឹកគឺល្អទាំងសម្រាប់ផឹកនិងប្រើប្រាស់ប្រចាំថ្ងៃ ទោះបីជាប្រភពទឹកខ្លះមិនទាន់មានអនាម័យ និងការពារបានត្រឹមត្រូវនៅឡើយ។ យោងតាម Sheat (1992, as cited in Bun et al., 2021) វាមានសារៈសំខាន់ទាក់ទងនឹងទស្សនៈឬការយល់ឃើញអំពីគុណភាពទឹកក្នុងចំណោមអ្នកប្រើប្រាស់ ព្រោះវាទាក់ទងនឹងចំណេះដឹង និងគោលគំនិតដែលអាចមានលក្ខណៈជាវប្បធម៌តាំងពីដើមរបស់ពួកគេ។ ហេតុនេះ មូលហេតុដែលប្រជាជនរស់នៅឃុំឆែប២ ភាគច្រើនយល់ឃើញវិជ្ជមានលើប្រភពទឹកអាស្រ័យផលប្រចាំថ្ងៃ អាចបណ្តាលមកពីចំណេះដឹងទូទៅរបស់ពួកគេលើគុណភាពទឹកនិងអនាម័យទឹកប៉ះពាល់ដល់សុខភាពនៅមានកម្រិត ម្យ៉ាងទៀតវាអាចទម្លាប់ប្រពៃណីតាំងពីដើមមកក្នុងការផឹកនិងប្រើប្រាស់ទឹកពីប្រភពនានា។ ការសិក្សាស្រាវជ្រាវពីមុន (i.e., Bun, et al., 2021; Orgill, et al., 2013) ក៏បានបង្ហាញពីលទ្ធផលស្រដៀងគ្នាផងដែរដោយភាគច្រើននៃប្រជាជនកម្ពុជាគិតថាទឹកផឹកប្រចាំថ្ងៃរបស់ពួកគឺល្អនិងមានសុវត្ថិភាព។ ហេតុនេះការវាយតម្លៃលើគុណភាពទឹកពិតជាមានសារៈសំខាន់ក្នុងបង្ហាញពីសុវត្ថិភាពទឹកដែលពលរដ្ឋកំពុងប្រើប្រាស់ប្រចាំថ្ងៃ លើសពីនេះព័ត៌មាននិងចំណេះដឹងពីគុណភាពទឹកនិងការប៉ះពាល់លើសុខភាពគួរផ្សព្វផ្សាយទៅដល់ប្រជាជនក្នុងសហគមន៍។

## ៥. សន្និដ្ឋាននិងអនុសាសន៍

គោលបំណងសំខាន់នៃការសិក្សានេះគឺផ្តោតលើប្រើប្រាស់ទឹក រួមមានទឹកសម្រាប់ទទួលទាន និងប្រើប្រាស់ទូទៅនៅក្នុងគ្រួសារកម្ពុជានៅក្នុងខេត្តព្រះវិហារ ប្រទេសកម្ពុជា។ លទ្ធផលការសិក្សាបានបង្ហាញថាអស់រយៈពេលជាច្រើនឆ្នាំប្រជាពលរដ្ឋក្នុងឃុំឆែប២ កំពុងរស់នៅក្នុងទម្លាប់ដែលងាយប៉ះពាល់សុខភាពទាក់ទងនឹងប្រភពទឹកផឹក និងប្រើប្រាស់ប្រចាំថ្ងៃដោយសារប្រភពទឹកផឹកខ្លះគឺងាយស្រួលនឹងឆ្លងជំងឺផ្សេងៗដោយមិនមានអនាម័យត្រឹមត្រូវ។ អ្នកស្រុកក្នុងសហគមន៍ពឹងផ្អែកខ្លាំងលើប្រភពទឹកដែលមិនមានអនាម័យគ្រប់គ្រាន់ ដូចជាអណ្តូងដៃ ទឹកភ្លៀង សម្រាប់ការទទួលទាន។ ដោយឡែកអណ្តូងស្នប់ជីកដោយដៃ និងទឹកភ្លៀងត្រូវបានប្រជាជនភាគច្រើនពេញនិយមសម្រាប់ការប្រើប្រាស់ប្រចាំថ្ងៃ។ ដោយសារភាគច្រើននៃប្រជាពលរដ្ឋបន្តការទទួលទានទឹកដោយពុំបានប្រើប្រាស់វិធានអនាម័យ

និងប្រើប្រាស់សម្ភារៈស្តុកទឹកប្រើប្រាស់ដែលមិនត្រឹមត្រូវដូចជាបីដុងទឹក និងពាងទឹកគ្មានគម្រប ហានិភ័យនៃការបង្កជំងឺដោយសារទឹកមានកម្រិតខ្ពស់។ ដំណោះស្រាយជាក់ស្តែងដើម្បីដោះស្រាយបញ្ហាទឹកបរិភោគស្អាតក្នុងទ្រង់ទ្រាយធំសម្រាប់តំបន់នេះគួរត្រូវបានណែនាំ។

ផ្អែកតាមលទ្ធផលនិងការពិភាក្សាខាងលើ អនុសាសន៍ខាងក្រោមគួរត្រូវបានពិចារណាក្នុងការលើកកម្ពស់ស្ថានភាពការប្រើប្រាស់ទឹករបស់ប្រជាពលរដ្ឋរស់នៅក្នុងឃុំធៃប២៖

- អាជ្ញាធរពាក់ព័ន្ធ ដូចជាក្រសួងសុខាភិបាលគួរយកទឹកពីប្រភពផ្សេងៗនៅតំបន់ឃុំធៃប2ដើម្បីសិក្សាពិសោធន៍ជាប្រចាំនិងវាយតម្លៃគុណភាពទឹកដើម្បីស្វែងរកសារធាតុបំពុលសំខាន់ៗដូចជា សារធាតុដែក អាសេនិក សារធាតុហ្លួយអូរីត ជាដើម។ សារធាតុបំពុលទាំងនេះមិនមានក្លិន មិនប្រែពណ៌ទឹក ឬរសជាតិ ដូចនេះការអនុវត្តជាក់ស្តែងជាមធ្យោបាយមួយក្នុងការទប់ស្កាត់ការចម្លងរោគបណ្តាលមកពីទឹក (Guppy & Shantz, 2011)។ លទ្ធផលនៃការពិនិត្យពិសោធន៍ទឹកគួរត្រូវបានផ្សព្វផ្សាយរាយការណ៍ឱ្យបានទូលំទូលាយជូនប្រជាពលរដ្ឋក្នុងសហគមន៍ ដើម្បីបង្ការហានិភ័យសុខភាពនាពេលអនាគត។
- អាជ្ញាធរពាក់ព័ន្ធគួរមានយន្តការតាមដាន និងវាយតម្លៃលើសុខភាពប្រជាពលរដ្ឋនៅក្នុងសហគមន៍ឱ្យបានទៀងទាត់ ព្រោះអាចបណ្តាលមកពីការប្រើប្រាស់ប្រភពទឹកមិនមានអនាម័យ។
- ប្រជាជននៅឃុំធៃប២និយមបរិភោគនិងប្រើប្រាស់ទឹកដោយមិនទាន់ស្អាតមានអនាម័យត្រឹមត្រូវ ទោះបីជាធ្លាប់មានការណែនាំពីអាជ្ញាធរ និងអង្គការក្រៅរដ្ឋាភិបាលផ្សេងៗ ដូចនេះកម្មវិធីបណ្តុះបណ្តាលអប់រំក្រៅប្រព័ន្ធស្តីពីអនាម័យទឹកស្អាត ពិតជាមានសារៈសំខាន់ក្នុងការផ្លាស់ប្តូរការយល់ឃើញ និងទម្លាប់របស់ពួកគេ។
- ការសិក្សាពីមុនមួយចំនួនបានបង្ហាញថាកម្មវិធីប្រមូលផលទឹកភ្លៀងបានរួមចំណែកដល់សុខភាព និងលើកកម្ពស់ជីវភាពគ្រួសារ (Pheng & Keo, 2014) យ៉ាងណាមិញការប្រមូលផលទឹកភ្លៀងក៏ត្រូវមានលក្ខណៈត្រឹមត្រូវបច្ចេកទេសផងដែរ។ ទឹកភ្លៀងដែលប្រមូលផលត្រូវបានចាត់ជាប្រភពទឹកមានលក្ខណៈប្រសើរ (WHO/UNICEF, 2012, as cited in Shaheed et al., 2013)។ ដោយសារការនិយមប្រើប្រាស់ទឹកភ្លៀងក្នុងចំណោមប្រជាជនក្នុងឃុំធៃប២ ការស្ថាបនាប្រព័ន្ធប្រមូលទឹកភ្លៀងសម្រាប់ស្តុកទុកសម្រាប់ទុកប្រើប្រាស់បានយូរ និងមានអនាម័យពិតជាមានភាពចាំបាច់សម្រាប់ប្រជាជន ជាពិសេសក្នុងរដូវប្រាំង។
- ក្រៅពីរាជរដ្ឋាភិបាលកម្ពុជា ការចូលរួមបន្ថែមពីដៃគូពាក់ព័ន្ធដូចជាអង្គការក្រៅរដ្ឋាភិបាលជាតិ និងអន្តរជាតិ និងវិស័យឯកជនពិតជាកម្លាំងចលករសំខាន់ ក្នុងការសម្រេចតាមផែនការដែលរដ្ឋាភិបាលកំណត់យកឆ្នាំ2025 ពលរដ្ឋត្រូវទទួលបានសេវាផ្គត់ផ្គង់ទឹកស្អាតនិងអនាម័យឱ្យបានពេញលេញ100% ក៏ដូចជាដើម្បីឈានទៅសម្រេចគោលដៅទី6 នៃការអភិវឌ្ឍប្រកបដោយចីរភាពរបស់អង្គការសហប្រជាជាតិ (SDG 6) ស្តីពីទឹកស្អាតនិងអនាម័យសម្រាប់ទាំងអស់គ្នាត្រឹមឆ្នាំ2030។ ក្នុងន័យនេះការបង្កើនថវិកាគាំទ្រគម្រោងផ្សេងៗក្នុងការផ្តល់សេវាផលិត ស្តុកនិងចែកចាយទឹកស្អាតអនាម័យគួរត្រូវបានបន្ថែមជារៀងរាល់ឆ្នាំជាពិសេសសម្រាប់បណ្តាខេត្តនៅទីជនបទឆ្ងាយៗ ដូចជាខេត្តព្រះវិហារដែលជាទីតាំងនៃការសិក្សាបច្ចុប្បន្ននេះជាដើម។

# ឯកសារយោង

Asian Development Bank. (2012). *Cambodia: Water Supply and Sanitation Sector Assessment, Strategy, and Road Map. Asian Development Bank: Metro Manila*. https://www.adb.org/documents/cambodia-water-supply-and-sanitation-sector-assessment-strategy-and-road-map

Bun, S., Sek, S., Oeurng, C., Fujii, M., Ham, P., & Painmanakul, P. (2021). A survey of household water use and groundwater quality index assessment in a rural community of Cambodia. *Sustainability*, *13*(18), 10071. https://doi.org/10.3390/su131810071

Ertop. H, Kocięcka. J, Atilgan. A, Liberacki. D, Niemiec. M., & Rolbiecki. R. (2023). The Importance of Rainwater Harvesting and Its Usage Possibilities: Antalya Example (Turkey). *Water*, *15*(12), 2194. https://doi.org/10.3390/w15122194

Gleick, P. H. (1996). Basic Water Requirements for Human Activities: Meeting Basic Needs. *Water International, 21*(2), 83–92. http://dx.doi.org/10.1080/02508069608686494

Guppy, L., & Shantz, A. (2011). Groundwater quality in rural Cambodia: Measures and perceptions. *Geographical Research*, *49*(4), 384-394. https://doi.org/10.1111/j.1745-5871.2011.00710.x

Levisay, M., & Sameth, C. (2006). Measuring Rural Water Supply Access: Findings from a Comparative Analysis of Cambodian National Surveys. https://documents1.worldbank.org/curated/ru/357941468137709947/pdf/372860Kh0replacement0file.pdf

Lo, A. G., & Gould, J. (2015). Rainwater Harvesting: Global Overview. In: Q. Zhu, J. Gould, Y. Li, & C. Ma (eds). Rainwater Harvesting for Agriculture and Water Supply, (pp. 213–233). https://doi:10.1007/978-981-287-964-6_7

Ministry of Rural Development. (2011). *Rural Water Supply, Sanitation and Hygiene Strategy 2011–2025.*

Ministry of Environment. (2020). *Cambodia's Updated Nationally Determined Contribution*. https://unfccc.int/sites/default/files/NDC/2022-06/20201231_NDC_Update_Cambodia.pdf

OpenDevelopment Cambodia. (2014). *UNICEF says 6.3 million Cambodians still lack access to safe water*. https://opendevelopmentcambodia.net/news/unicef-says-6-3-million-cambodians-still-lack-access-to-safe-water/

Orgill, J., Shaheed, A., Brown, J., & Jeuland, M. (2013). Water quality perceptions and willingness to pay for clean water in peri-urban Cambodian communities. *Journal of Water and Health, 11*(3), 489–506. https://doi.org/10.2166/wh.2013.212

Pheng. K., & Keo. V. K. (2014). Rainwater harvesting formalization for rural cambodia. 37th WEDC international conference, Hanoi, Vietnam.

Pink, R. M. (2016). Cambodia: A Rural Water Crisis. In: Water Rights in Southeast Asia and India. Palgrave Macmillan, New York. https://doi.org/10.1057/9781137504234_3

Royal Government of Cambodia. (2019). *National Strategic Development Plan 2019-2023*.

Shaheed, A., Orgill, J., Ratana, C., Montgomery, M. A., Jeuland, M. A., & Brown, J. (2013). Water quality risks of "improved" water sources: evidence from Cambodia. *Tropical Medicine & International Health*, *19*(2), 186–194. https://doi.org/10.1111/tmi.12229

United Nations Development Programme. (2020). *Development of Ground Water Management Strategy in Cambodia: Institutional Assessment Capacity Building Plan and Proposed Key Components of Groundwater Management in Cambodia.* https://www.adaptation-undp.org/sites/default/files/resources/groundwater_managment_in_cambodia_-_v.24.02.202027958.pdf

United Nations. (2017). *UN Millennium Campaign*. July 2017, from http://www.un.org/millenniumgoals/bkgd.shtml.

United Nations Cambodia. (n.d.). *Our Work on the Sustainable Development Goals in Cambodia*. https://cambodia.un.org/en/sdgs

UNICEF. (n.d.). *Water, Sanitation and Hygiene*. https://www.unicef.org/cambodia/water-sanitation-and-hygiene

WaterAid. (n.d.). *Rural Water Supply in Cambodia: A consolidation of data & knowledge and identification of gaps & research needs.* https://washmatters.wateraid.org/sites/g/files/jkxoof256/files/rural-water-supply-in-cambodia-consolidation-of-data-and-knowledge-gaps.pdf

Water.org. (2019, March, 25). *Cambodia's water and sanitation crisis*. Retrieved from https://water.org/our-impact/cambodia/.

World Bank., & Asian Development Bank. (2021). *Climate Risk Country Profile: Cambodia*. https://climateknowledgeportal.worldbank.org/sites/default/files/2021-08/15849-

WB_Cambodia%20Country%20Profile-WEB.pdf

World Bank. (n.d). *Water Supply and Sanitation Improvement Project.* https://documents1.worldbank.org/curated/en/992451573061257426/pdf/Cambodia-Water-Supply-and-Sanitation-Improvement-Project.pdf



**ហេង វីរិទ្ធិ**

**កន្លែងធ្វើការ៖**

- រាជបណ្ឌិត្យសភាកម្ពុជា

**សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់៖**

- គ្រប់គ្រងបរិស្ថាន
- (សាកលវិទ្យាល័យហ្លីនឌ័រ ប្រទេសអូស្ត្រាលី)

**ចំណាប់ចំណូលចិត្តស្រាវជ្រាវ៖**

- ការគ្រប់គ្រងតំបន់ទីក្រុង
- គ្រប់គ្រងនិងអភិរក្សធនធានធម្មជាតិ
- វិទ្យាសាស្ត្រកសិកម្ម
- បរិស្ថានធម្មជាតិនិងជីវវិទ្យា



**សេង សុជា**

**កន្លែងធ្វើការ៖**

- រាជបណ្ឌិត្យសភាកម្ពុជា

**សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់៖**

- អប់រំភាសាអង់គ្លេស
- (សាកលវិទ្យាល័យបូរ៉ាផា ព្រះរាជាណាចក្រថៃឡង់)

**ចំណាប់ចំណូលចិត្តស្រាវជ្រាវ៖**

- ការលើកទឹកចិត្តសិស្ស
- យុទ្ធសាស្ត្រអំណាន
- ការវាយតម្លៃលើកំហុសភាសា



**មឿង ចំរើន**

**កន្លែងធ្វើការ៖**

- រាជបណ្ឌិត្យសភាកម្ពុជា

**សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់៖**

- ពាណិជ្ជសាស្ត្រ
- (សាកលវិទ្យាល័យជាតិបាត់ដំបង)

**ចំណាប់ចំណូលចិត្តស្រាវជ្រាវ៖**

- សេដ្ឋកិច្ចសង្គម
- ពាណិជ្ជកម្មនិងទីផ្សារ
- ទេសចរណ៍



**ឆោម ជុំរ៉ុង**

**កន្លែងធ្វើការ៖**

- រាជបណ្ឌិត្យសភាកម្ពុជា

**សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់៖**

- អប់រំភាសាអង់គ្លេស
- (សាកលវិទ្យាល័យន័រតុន)

**ចំណាប់ចំណូលចិត្តស្រាវជ្រាវ៖**

- ការចូលរួមក្នុងការសិក្សា
- លទ្ធផលសិក្សារបស់សិស្ស
- ការលើកទឹកចិត្តសិស្ស
- ការបង្រៀននិងរៀនវេយ្យករណ៍

# ឧបសម្ព័ន្ធ

## កម្រងសំណួរ

## ការប្រើប្រាស់ទឹកតាមផ្ទះរបស់ប្រជាពលរដ្ឋក្នុងឃុំឆែប២ ខេត្តព្រះវិហារ៖ ប្រភព វិធានអនាម័យ និងឥរិយាបថ

**សេចក្តីផ្តើម៖**

ការសិក្សានេះមានគោលបំណងស្វែងយល់ពីទិដ្ឋភាពជាក់ស្តែងនៃការប្រើប្រាស់ទឹកប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋរស់នៅក្នុងឃុំឆែប២ ស្រុកឆែប ខេត្តព្រះវិហារ ដោយផ្តោតទៅលើទឹកសម្រាប់ទទួលទាន និងទឹកសម្រាប់ការប្រើប្រាស់ក្នុងការដាំស្ល ជុសលាងសម្ភារៈ របស់ប្រើប្រាស់ផ្សេងៗ និងសត្វចិញ្ចឹមជាដើម។ វិសាលភាពនៃការសិក្សាគឺផ្តោតទៅលើទិដ្ឋភាពចំនួនបីទាក់ទងនឹងទឹកដែលមានដូចជា ប្រភពទឹក វិធានអនាម័យទឹក និងឥរិយាបថរបស់ប្រជាពលរដ្ឋទាក់ទងនឹងទឹកប្រើប្រាស់ប្រចាំថ្ងៃ។

### ផ្នែកទី១៖ ព័ត៌មានទូទៅ

1- ភេទ៖ ☐ ប្រុស ☐ ស្រី

2- អាយុ៖ ☐ 18-30 ☐ 30-40 ☐ 40+

3- តើក្នុងគ្រួសារអ្នកមានសមាជិកប៉ុន្មាននាក់? ______________

4- កម្រិតការអប់រំ៖

| សមាជិកគ្រួសារ | កម្រិតសិក្សាទទួលបាន | | | |
|---|---|---|---|---|
| អ្នកផ្តល់ការសម្ភាស | ☐ មិនបានរៀន | ☐ ថ្នាក់ទី1-9 | ☐ ថ្នាក់ទី10-12 | ☐ ថ្នាក់ឧត្តមសិក្សា |
| ប្តី/ប្រពន្ធអ្នកផ្តល់សម្ភាស | ☐ មិនបានរៀន | ☐ ថ្នាក់ទី1-9 | ☐ ថ្នាក់ទី10-12 | ☐ ថ្នាក់ឧត្តមសិក្សា |
| កូនទទួលបានការសិក្សាខ្ពស់បំផុត | ☐ មិនបានរៀន | ☐ ថ្នាក់ទី1-9 | ☐ ថ្នាក់ទី10-12 | ☐ ថ្នាក់ឧត្តមសិក្សា |

5- ការងារ/មុខរបរចម្បង៖ ________________________________________

6- ការងារ/មុខរបរបន្ទាប់បន្សំ៖ ________________________________________

### ផ្នែកទី2៖ ការប្រើប្រាស់ទឹកប្រចាំថ្ងៃ

7- ព័ត៌មានទាក់ទងនឹងទឹកប្រើប្រាស់ប្រចាំថ្ងៃ (ចូរបំពេញ ឬគូសសញ្ញាធីក "✓" ក្នុងប្រអប់)

| | | ទឹកទទួលទាន | | ទឹកប្រើប្រាស់ទូទៅ | |
|---|---|---|---|---|---|
| | | វស្សា | ប្រាំង | វស្សា | ប្រាំង |
| ប្រភពទឹក | ប្រភពទឹកធម្មជាតិលើដី | ☐ | ☐ | ☐ | ☐ |

| | | | | | |
|---|---|---|---|---|---|
| | Borehole fitted with hand pump | ☐ | ☐ | ☐ | ☐ |
| | អណ្តូងជីកដោយដៃមានគម្របបិទ | ☐ | ☐ | ☐ | ☐ |
| | អណ្តូងជីកដោយដៃគ្មានគម្របបិទ | ☐ | ☐ | ☐ | ☐ |
| | ទឹកភ្លៀង | ☐ | ☐ | ☐ | ☐ |
| | ទឹកធុងលក់តាមទីផ្សារ | ☐ | ☐ | ☐ | ☐ |
| | រណ្តៅជីកដោយដៃតាមបាតអូរ | ☐ | ☐ | ☐ | ☐ |
| រយៈពេលដងទឹកពីប្រភព (គិតជានាទី) | ទឹកសម្រាប់ទទួលទាន | | | | |
| | ទឹកប្រើប្រាស់ទូទៅ | | | | |
| វិធីកែលម្អគុណភាពទឹក | ពុំបានសម្អាតឬចម្រិន | ☐ | ☐ | ☐ | ☐ |
| | ប្រើវិធីចម្រោះមុនប្រើប្រាស់ | ☐ | ☐ | ☐ | ☐ |
| | ដាំឱ្យពុះមុនប្រើប្រាស់ | ☐ | ☐ | ☐ | ☐ |
| | ដាក់/កូរនឹងសាច់ជូ | ☐ | ☐ | ☐ | ☐ |
| ចំនួនទឹកប្រើប្រាស់ (លីត្រ/នាក់/ថ្ងៃ) | ទឹកសម្រាប់ទទួលទាន | ☐ | ☐ | ☐ | ☐ |
| | ទឹកប្រើប្រាស់ទូទៅ | ☐ | ☐ | ☐ | ☐ |
| ចំណាយទិញទឹកទទួលទាន | គិតជាសប្តាហ៍ | ☐ | ☐ | ☐ | ☐ |
| ចំនួននៃការដងទឹកមកប្រើប្រាស់/សប្តាហ៍ | ទឹកបរិភោគ | ☐ | ☐ | ☐ | ☐ |
| | ទឹកប្រើប្រាស់ទូទៅ | ☐ | ☐ | ☐ | ☐ |

8- សូមបញ្ជាក់ពីការលំបាកណាមួយដែលអ្នកនឹងមានពេលប្រមូលទឹកពីប្រភព?

☐ ពុំមានការលំបាក

☐ ប្រភពទឹកមានចម្ងាយឆ្ងាយ

☐ ខ្វះអ្នកដឹកទឹក

☐ ការត្រូវរង់ចាំដងទឹក

☐ បរិមាណទឹកមិនគ្រប់គ្រាន់

☐ ឧបករណ៍ដឹកជញ្ជូនទឹកមានកំណត់

☐ ពុំមានមធ្យោបាយដឹកទឹក

**ផ្នែកទី3៖ ទស្សនៈប្រជាពលរដ្ឋចំពោះទឹកប្រើប្រាស់**

នៅក្នុងផ្នែកនេះ សំណួរទាំងអស់ (Q10 និង Q11) ត្រូវបានវាស់វែងលើមាត្រដ្ឋាន Likert ប្រាំកម្រិតដែលមានបង្ហាញខាងក្រោម៖

| ទស្សនៈអវិជ្ជមាន | ទស្សនៈកណ្តាល | ទស្សនៈវិជ្ជមាន |
|---|---|---|
| 1 = មិនប៉ះពាល់ទាល់តែសោះ<br>2 = ប៉ះពាល់តិចតួច | 3 = គ្មានយោបល់ | 4 = ប៉ះពាល់ខ្លាំង<br>5 = ប៉ះពាល់ខ្លាំងមែនទែន |

សូមវាយដោយគូសសញ្ញា (√) ក្នុងប្រអប់លេខពីលេខ 1 ដល់លេខ 5 ដោយបង្ហាញពីការយល់ឃើញជាក់ស្តែងរបស់លោកអ្នកទៅលើល្បះនីមួយៗក្នុងតារាងខាងក្រោម។

| សំណួរ | ល្បះបញ្ជាក់ពីទស្សនៈទៅលើផលប៉ះពាល់របស់ទឹក | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| Q10 | តើអ្នកវាយបែបណាអំពីផលប៉ះពាល់នៃការចំណាយលើការទិញទឹកស្អាតសម្រាប់ផឹកទៅលើសេដ្ឋកិច្ចគ្រួសាររបស់អ្នក? | ☐ | ☐ | ☐ | ☐ | ☐ |
| Q11 | តើអ្នកវាយតម្លៃបែបណាអំពីផលប៉ះពាល់នៃទឹកសម្រាប់ទទួលប្រចាំថ្ងៃទៅលើសុខភាពរបស់អ្នក? | ☐ | ☐ | ☐ | ☐ | ☐ |

សំណួរខាងក្រោម (Q12-Q15) វាស់វែងដោយមាត្រដ្ឋាន Likert ប្រាំកម្រិតដូចខាងក្រោម៖

| ទស្សនៈអវិជ្ជមាន | ទស្សនៈកណ្តាល | ទស្សនៈវិជ្ជមាន |
|---|---|---|
| 1 = ទាបខ្លាំង<br>2 = ទាប | 3 = មធ្យម | 4 = ល្អ<br>5 = ល្អខ្លាំង |

សូមវាយដោយគូសសញ្ញា (√) ក្នុងប្រអប់លេខពីលេខ 1 ដល់លេខ 5 ដោយបង្ហាញពីការយល់ឃើញជាក់ស្តែងរបស់លោកអ្នកទៅលើល្បះនីមួយៗក្នុងតារាងខាងក្រោម។

| សំណួរ | ល្បះបញ្ជាក់ទិដ្ឋភាពនានាទាក់ទងនឹងទឹកប្រើប្រាស់ប្រចាំថ្ងៃ | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|---|
| Q12 | តើអ្នកនឹងពិចារណា/វាយតម្លៃអនាម័យ និងគុណភាពនៃទឹកផឹកប្រចាំថ្ងៃរបស់អ្នកដោយរបៀបណា? | ☐ | ☐ | ☐ | ☐ | ☐ |
| Q13 | តើអ្នកនឹងវាយតម្លៃគុណភាពនៃទឹកដប/បារយ៉ាងដូចម្តេច ប្រសិនបើអ្នកនឹងប្រើប្រាស់វាសម្រាប់ផឹក? | ☐ | ☐ | ☐ | ☐ | ☐ |
| Q14 | តើអ្នកនឹងវាយតម្លៃគុណភាពទឹកភ្លៀងដោយរបៀបណា ប្រសិនបើអ្នកនឹងប្រើប្រាស់វាសម្រាប់ផឹក? | ☐ | ☐ | ☐ | ☐ | ☐ |
| Q15 | តើអ្នកនឹងវាយតម្លៃគុណភាព និងអនាម័យនៃទឹកផឹកដែលយកចេញពីឧបករណ៍ចម្រោះប្រភេទណា? | ☐ | ☐ | ☐ | ☐ | ☐ |
| Q16 | តើអ្នកនឹងវាយតម្លៃគុណភាព និងអនាម័យនៃទឹកផឹករបស់អ្នកជិតខាងរបស់អ្នកយ៉ាងដូចម្តេច? | ☐ | ☐ | ☐ | ☐ | ☐ |

កាលិកាបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Cambodian Journal of Humanities and Social Sciences

Website: https://cjhss-journal.com/

# ការបង្រៀននិងរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាក្នុងអំឡុងពេលបិទសាលារៀន៖ ការសិក្សាលើទស្សនៈរបស់គ្រូនិងសិស្ស

# A Perceptual Study on Teaching and Learning at Cambodian Upper Secondary School Education During School Closure

**លី តុង[១], ធី សាវរិន[២], អៀន សុគន្ធី[៣]**

[១] វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, រាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ lytongcambodia2013@gmail.com

[២] វិទ្យាស្ថានជាតិអប់រំ
អ៊ីមែល៖ thysavrin@gmail.com

[៣] វិទ្យាល័យព្រែកថ្មី ខេត្តកណ្ដាល
អ៊ីមែល៖ sokunthyean@gmail.com

បានទទួល៖ ០១កក្កដា ២០២៣; ទទួលបោះពុម្ព៖ ២២តុលា ២០២៣; បោះពុម្ព៖ ៣១ធ្នូ ២០២៣

**ទំនាក់ទំនង៖** lytongcambodia2013@gmail.com

**អាគតដ្ឋាន៖** លី តុង, ធី សាវរិន និង អៀន សុគន្ធី. (២០២៣). ការបង្រៀននិងរៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាក្នុងអំឡុងពេលបិទសាលារៀន៖ ការសិក្សាលើទស្សនៈរបស់គ្រូនិងសិស្ស. *កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*, ២(២), ២៣-៤១.

## សង្ខិត្តន័យ

វិបត្តិកូវីដ-១៩បានបង្កនូវបញ្ហាប្រឈមយ៉ាងខ្លាំងដល់ដំណើរការអប់រំនៅកម្ពុជា ដោយសាលារៀនទូទាំងប្រទេសត្រូវបានបិទដោយសារការអនុវត្តវិធានការគម្លាតសង្គម។ ប្រសិទ្ធភាពនិងគុណភាពនៃការបង្រៀននិងរៀននៅគ្រប់កម្រិតថ្នាក់ត្រូវបានគេមើលឃើញថាមានការធ្លាក់ចុះយ៉ាងខ្លាំង ដោយសារការបង្រៀននិងរៀនបានផ្លាស់ប្តូរពីក្នុងថ្នាក់មកជាការបង្រៀននិងរៀនពីចម្ងាយ។ ការសិក្សានេះផ្តោតជាចម្បងទៅលើការបង្រៀននិងរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជា ដោយមានវត្ថុបំណងចំនួនពីរគឺ សិក្សាពីទិដ្ឋភាពទូទៅនៃការបង្រៀននិងរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិអំឡុងពេលបិទសាលារៀន និង សិក្សាពីប្រសិទ្ធភាពនៃការបង្រៀននិងរៀនរបស់គ្រូនិងសិស្សក្នុងអំឡុង

ពេលបិទសាលារៀន។ ការសិក្សានេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យដោយកម្រងសំណួរស្ទង់មតិត្រូវបានប្រើប្រាស់ដើម្បីប្រមូលទិន្នន័យពីក្រុមគោលដៅស្រាវជ្រាវ។ គ្រូបង្រៀនចំនួន 717នាក់ និង សិស្សវិទ្យាល័យចំនួន 3,377នាក់ ក្នុងនោះគ្រូបង្រៀនភេទស្រី 44.1% និង សិស្សស្រី 62.5% បានចូលរួមក្នុងការសិក្សា។ លទ្ធផលស្រាវជ្រាវបង្ហាញថា គ្រូបង្រៀនចំនួន 4.5% និង សិស្ស 17.0% ពុំបានបន្តការបង្រៀននិងរៀនក្នុងពេលបិទសាលានោះទេ ហើយស្ថានភាពនេះមានភាពធ្ងន់ធ្ងរនៅសាលារៀនតាមតំបន់ឆ្ងាយទីប្រជុំជនឬតំបន់មិនសូវមានការរីកចម្រើន។ បន្ថែមពីលើនេះ លទ្ធផលក៏បង្ហាញថាប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូទទួលបានក្នុងកម្រិតលើមធ្យមបន្តិចបន្តួច ហើយទិដ្ឋភាពនេះពុំមានភាពខុសប្លែកគ្នានោះទេអាស្រ័យលើកត្តាដូចជា ភេទ ប្រភេទនិងទីតាំងសាលារៀន មុខវិជ្ជាបង្រៀន និង បទពិសោធន៍បង្រៀន ប៉ុន្តែវាខុសគ្នាផ្អែកលើគុណភាពសេវាអ៊ីនធឺណិត។ ដោយឡែកប្រសិទ្ធភាពនៃការរៀនរបស់សិស្សទទួលបានក្នុងកម្រិតមធ្យម ហើយទិដ្ឋភាពនេះមានភាពខុសប្លែកគ្នាទៅតាមកត្តាមួយចំនួនដូចជាភេទ ប្រភេទនិងទីតាំងសាលារៀន កម្រិតថ្នាក់ និងគុណភាពសេវាអ៊ីនធឺណិត។ ដើម្បីឆ្លើយតបចំពោះបញ្ហាស្រដៀងគ្នាដែលអាចកើតមាននៅថ្ងៃអនាគតឱ្យមានប្រសិទ្ធភាព អ្នកស្រាវជ្រាវផ្តល់ជាអនុសាសន៍មួយចំនួនដូចជា ធ្វើឌីជីថលនីយកម្មវិស័យអប់រំ, បញ្ជ្រាបយន្តការរៀនតាមវិធីចម្រុះ, ផលិតឯកសារសិក្សាឱ្យស្របស្ថានភាពជាក់ស្តែង, ពង្រឹងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល។

**ពាក្យគន្លឹះ:** លទ្ធផលបង្រៀន, លទ្ធផលសិក្សា, កម្ពុជា, ថ្នាក់មធ្យមសិក្សា, ទស្សនៈ

## ABSTRACT

The COVID-19 crisis posed challenges to education in Cambodia due to social distancing measure. The quality of teaching and learning at all grades plummeted due to the adoption of online teaching and learning. This study centered on the teaching and learning in upper secondary schools during school closure. The study focused on two objectives: (i) to explore the overview of teaching and learning during school closure and (ii) to assess the quality of teaching and learning during school closure. The study employed quantitative method where data were gathered using online surveys. A total of 717 school teachers (female=44.1%) and 3,377 students (female=62.5%) participated in the study. It was found that 4.5% of teachers and 17.0% of the students failed to continue their educational activities with more serious situation among schools at rural or under-developed areas. In addition, the quality of teaching was at slightly above average, and it was of no significant different across sub-groups based on gender, school type and location, teaching subject and teaching experience; however, it varied based on the quality of Internet. The student's learning was at an average level with significant different among sub-groups based on gender, school type and location, grade level and the quality of Internet. To improve the future readiness for unexpected similar crisis, the study recommended that digitalization in education, adopt blended learning, produce teaching and learning materials that fit the actual situation and strengthening and further developing the ICT and digital infrastructure should be considered.

**KEYWORDS:** teaching performance, learning performance, Cambodia, secondary school, perception

# ១. សេចក្តីផ្តើម

ការរីករាលដាលនៃជំងឺកូវីដ-១៩កាលពីចុងឆ្នាំ២០១៩ ជាពិសេសដើមឆ្នាំ២០២០ បានក្លាយទៅជាវិបត្តិសង្គមមួយយ៉ាងធ្ងន់ធ្ងរសម្រាប់គ្រប់ជាតិសាសន៍នៅលើសកលលោក។ វិបត្តិនេះបាននាំឱ្យមានផលប៉ះពាល់យ៉ាងខ្លាំងទៅលើដំណើរការសង្គម សេដ្ឋកិច្ច និង ការអប់រំក្នុងប្រទេសនានានៅទូទាំងសកលលោក (MoEYS, 2020; UNICEF et al., 2021; United Nations, 2020)។ ក្នុងប្រទេសកម្ពុជា ដើម្បីទប់ស្កាត់ការរីករាលជំងឺកូវីដ-១៩ក្នុងសហគមន៍ រាជរដ្ឋាភិបាលកម្ពុជាបានកំណត់នូវវិធានការគម្លាតសង្គម ដោយដំណើរការសង្គមដូចជាអាជីវកម្មស្ទើរគ្រប់ប្រភេទ សាលារៀន គ្រឹះស្ថានរដ្ឋាភិបាលជាដើម ត្រូវបានផ្អាកដំណើរការឬកម្រិតវិសាលភាពប្រតិបត្តិការ។ ក្នុងអំឡុងពេលនេះទាំងគ្រូបង្រៀននិងសិស្សបានប្រឈមមុខទៅនឹងបញ្ហានានាទាំងផ្នែកសេដ្ឋកិច្ច ផ្លូវចិត្ត ការអប់រំ និង ការរស់នៅ (Dy et al., 2020; Thy et al., 2023)។ ក្នុងដំណាក់កាលនៃការបិទសាលារៀននេះ រាជរដ្ឋាភិបាលកម្ពុជាបានសហការគ្នាយ៉ាងជិតស្និទជាមួយនឹងដៃគូអភិវឌ្ឍនានាដើម្បីបង្កើតនូវកម្មវិធីអប់រំពីចម្ងាយតាមមធ្យោបាយជាច្រើនដូចជាបណ្តាញសង្គមហ្វេសប៊ុគ, យូធូប, តេឡេក្រាម, វិទ្យុ, ទូរទស្សន៍ និង ការថតចម្លងនិងចែករំលែកឯកសារដោយផ្ទាល់ដល់សិស្សជាដើម (Chea et al., 2022; MoEYS, 2020; MoEYS & ESWG, 2021)។

ដោយសារការទទួលយកលឿនពេកនៃបច្ចេកវិទ្យាក្នុងការបង្រៀននិងរៀនពីចម្ងាយ គួបផ្សំជាមួយនឹងកង្វះខាតផ្នែកហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាផងនោះ ដំណើរការអប់រំក្នុងអំឡុងពេលនោះជួបប្រទះនូវបញ្ហាប្រឈមជាច្រើន (Chhy, 2020; Heng & Sol, 2021; MoEYS & ESWG, 2021; Pokhrel & Chhetri, 2021; Thy et al., 2023)។ តំបន់ជាច្រើននៅក្នុងប្រទេសកម្ពុជា ពុំមានអ៊ីនធឺណិតប្រើប្រាស់ ដោយឡែកតំបន់ខ្លះដែលមានអ៊ីនធឺណិតប្រើប្រាស់ ប៉ុន្តែល្បឿនឬគុណភាពពុំអាចទ្រទ្រង់ការបង្រៀននិងរៀនពីចម្ងាយបានដោយរលូននោះទេ។ បញ្ហាប្រឈមមួយទៀតនោះគឺតម្រូវការឧបករណ៍អេឡិកត្រូនិកសម្រាប់ការរៀបចំមេរៀន បង្រៀន និងរៀន ព្រោះមិនមែនគ្រូនិងសិស្សទាំងអស់សុទ្ធតែមានឧបករណ៍ទាំងនេះប្រើប្រាស់នោះទេ ជាពិសេសសិស្សានុសិស្សតែម្តង។ សិស្សានុសិស្សជាច្រើនត្រូវចែករំលែកឧបករណ៍ទាំងនេះក្នុងចំណោមបងប្អូន ដោយឡែក គ្រូបង្រៀនជាច្រើនមានការពិបាកដោយខ្លួនត្រូវបង្រៀនស្របពេលដែលកូនៗរបស់គាត់ក៏ត្រូវការឧបករណ៍ទាំងនេះដើម្បីរៀន។

## ១.១. មធ្យោបាយបង្រៀននិងរៀនក្នុងពេលកូវីដ-១៩

របាយការណ៍ MoEYS and ESWG (2021) បានបង្ហាញថាទម្រង់នៃការរៀនពីចម្ងាយក្នុងអំឡុងពេលបិទសាលារៀនមានច្រើនរូបភាពដូចជា ការចែកសន្លឹកកិច្ចការនិងឯកសារ, ការរៀនតាមវីដេអូរៀនតាមអ៊ីនធឺណិត, រៀនតាមវិទ្យុឬទូរទស្សន៍ និង រៀនតាមប្រព័ន្ធគ្រប់គ្រងការរៀនពីចម្ងាយជាដើម។ ផ្អែកលើបទពិសោធន៍ផ្ទាល់របស់អ្នកស្រាវជ្រាវដែលជាគ្រូបង្រៀន ព្រមទាំងការពិភាក្សាជាលក្ខណៈឯកជនជាមួយមិត្តរួមអាជីព ទម្រង់ការបង្រៀននិងរៀនពីចម្ងាយចំនួនប្រាំពីរដូចខាងក្រោមៈ

- *ការប្រើប្រាស់វីដេអូអនឡាញ៖* ទម្រង់នៃការបង្រៀននិងរៀនដែលគ្រូនិងសិស្សបង្កើតជាថ្នាក់រៀនឌីជីថលនិងធ្វើសកម្មភាពសិក្សាជាមួយគ្នាពីចម្ងាយដោយប្រើប្រាស់បរិក្ខារបច្ចេកវិទ្យា បណ្តាញអ៊ីនធឺណិត ផ្សំជាមួយនឹងកម្មវិធីបង្រៀននិងរៀនអនឡាញដូចជា កម្មវិធី Zoom, Google Meet និង Microsoft Teams ជាដើម

- *ការថតចម្លងនិងចែករំលែកក្រដាសឯកសារសិក្សា៖* ទម្រង់នៃការបង្រៀននិងរៀនដែលគ្រូរៀបចំឯកសារសិក្សា ដូចជា សន្លឹកកិច្ចការ កម្រងលំហាត់ សំណួរសាកល្បង មេរៀនសង្ខេប បន្ទាប់មកថតចម្លងនិងចែកដល់សិស្ស ដើម្បីរៀននិងអនុវត្តនៅផ្ទះ
- *ការចែករំលែកឯកសារឌីជីថល៖* គំរូនេះគឺស្រដៀងទៅនឹងវិធីខាងលើដែរ ប៉ុន្តែជំនួសឱ្យការប្រើប្រាស់ក្រដាស សន្លឹកឯកសារចម្លង គ្រូបង្រៀនប្រើប្រាស់ឯកសារឌីជីថលផ្ញើទៅសិស្សតាមអ៊ីនធឺណិតក្នុងក្រុមសិក្សាឌីជីថល ដូចជា Telegram និង Messenger ជាដើម
- *បង្រៀននិងរៀនដោយប្រើប្រព័ន្ធគ្រប់គ្រងការរៀន៖* ទម្រង់នៃការបង្រៀននិងរៀនដែលគ្រូប្រើប្រាស់កម្មវិធី ជំនាញដូចជា Google Classroom, Microsoft Teams ឬ Moodle ជាដើម ដើម្បីរៀបចំ គ្រប់គ្រង និង បង្កើត សកម្មភាពរៀនដល់សិស្ស
- *ការបង្រៀនតាមវិទ្យុឬទូរទស្សន៍៖* ទម្រង់នៃការបង្រៀននិងរៀនដែលគ្រូរៀបចំមេរៀននិងថតជាវីដេអូឬសម្លេងរួច ចាក់ផ្សាយតាមវិទ្យុឬទូរទស្សន៍ សម្រាប់សិស្សរៀននៅតាមផ្ទះ
- *ការបង្រៀននិងរៀនតាមបណ្តាញសង្គម៖* ទម្រង់នៃការបង្រៀននិងរៀនដែលគ្រូរៀបចំមេរៀនរួចថតជាខ្សែវីដេអូ បង្ហោះតាមបណ្តាញសង្គមដូចជាហ្វេសប៊ុកឬយូធូប ដើម្បីសិស្សរៀន
- *កម្មវិធីសិក្សាតាមកម្មវិធី E-Learning Apps៖* កម្មវិធីបង្រៀននិងរៀនដែលអ្នកអប់រំ គ្រូបង្រៀនរៀបចំមេរៀន កំណែលំហាត់ សំណួរ-ចម្លើយ រួចបញ្ចូលទៅក្នុងកម្មវិធីសិក្សាពីចម្ងាយនានាដើម្បីសិស្សចុះឈ្មោះចូលរៀន។

ជាក់ស្តែង ក្នុងពេលអនុវត្តសកម្មភាពបង្រៀននិងរៀន គ្រូនិងសិស្សបានប្រើប្រាស់មធ្យោបាយទាំងនេះមួយឬច្រើនអាស្រ័យតាមស្ថានភាពជាក់ស្តែងនៃទីតាំងសាលារៀន មុខវិជ្ជាបង្រៀននិងរៀន គុណភាពនិងសេវាអ៊ីនធឺណិត និង លទ្ធភាពជាក់ស្តែងដែលមាន។

## ១.២. ចំណោទបញ្ហាស្រាវជ្រាវ

ការបង្រៀននិងរៀនពីចម្ងាយ បូកផ្សំជាមួយនឹងតម្រូវការប្រើប្រាស់បច្ចេកវិទ្យា ឧបករណ៍អេឡិកត្រូនិកសម្រាប់បន្តសកម្មភាពបង្រៀននិងរៀនដូចជា កម្មវិធី Telegram, Zoom, Microsoft Team, Google Meet ឬ Google Classroom ជាដើម បានបង្កើតឱ្យមានបញ្ហាប្រឈមទាំងសម្រាប់គ្រូនិងសិស្ស (Chhy, 2020; Heng & Sol, 2021; MoEYS, 2020; MoEYS & ESWG, 2021; MoEYS & UNICEF, 2022; Pokhrel & Chhetri, 2021; Thy et al., 2023)។ បន្ថែមពីលើចំណុចនេះ កត្តាទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធអ៊ីនធឺណិត, ធនធានសិក្សាតាមអនឡាញ, ធន្ទៈបុគ្គល និងកត្តាសម្ពាធសង្គម ក៏បានចូលរួមបង្កើតជាបញ្ហាប្រឈមដល់គ្រូបង្រៀននិងសិស្សផងដែរ។ បញ្ហាប្រឈមដែលបានលើកឡើងនេះ បានចូលរួមដោយផ្ទាល់និងដោយប្រយោលក្នុងការធ្វើឱ្យប្រសិទ្ធភាពនិងគុណភាពនៃការបង្រៀននិងរៀនមានការធ្លាក់ចុះ។ កន្លងមកមានការស្រាវជ្រាវមួយចំនួនដែលសិក្សាអំពីផលប៉ះពាល់នៃកូវីដ-១៩លើវិស័យអប់រំនិងស្ថានភាពជាក់ស្តែងនៃការបង្រៀននិងរៀនក្នុងបរិបទកូវីដ-១៩។ ជាឧទាហរណ៍ MoEYS and ESWG (2021) សិក្សាពីបញ្ហាប្រឈមនិងការធ្លាក់ចុះនៃការសិក្សា, Ean et al. (2023) និង MoEYS (2020) ផ្តោតលើវិធានការឆ្លើយតបក្នុងវិស័យអប់រំអំឡុងពេលបិទសាលារៀន, Heng and Sol (2021); MoEYS and UNICEF

(2022); Thy et al. (2023); Chhy (2020) និង Chet and Sok (2020) បង្ហាញពីឱកាស ផលប៉ះពាល់ និងបញ្ហាប្រឈមក្នុងការបង្រៀននិងរៀនជាដើម។ បន្ថែមពីលើនេះ Chea et al. (2022) ក៏បានសិក្សាទៅលើការត្រៀមខ្លួនរបស់គ្រូក្នុងការបង្រៀនពីចម្ងាយដោយប្រើបច្ចេកវិទ្យា និង Chea et al. (2021) បង្ហាញពីការប្រើប្រាស់បច្ចេកវិទ្យាក្នុងការអប់រំអំឡុងពេលកូវីដ-១៩។

បើទោះបីជា ការសិក្សាទាំងនេះមានលើកឡើងអំពីការធ្លាក់ចុះនៃការបង្រៀននិងរៀនក្តី ក៏ប៉ុន្តែ កម្រិតនៃការធ្លាក់ចុះឬប្រសិទ្ធភាពជាក់ស្តែងយ៉ាងណានោះ ហាក់ពុំឃើញមានបង្ហាញឱ្យបានស៊ីជម្រៅនោះទេ ជាពិសេសក្នុងបរិបទថ្នាក់មធ្យមសិក្សាតែម្តង។ ជាមួយនឹងកង្វះខាតទិន្នន័យនិងការសិក្សាស្រាវជ្រាវជាក់ស្តែងអំពីប្រសិទ្ធភាពនៃការបង្រៀន និងរៀន បូកផ្សំជាមួយនឹងចំណូលចិត្តផ្ទាល់របស់អ្នកស្រាវជ្រាវគឺជាកត្តាជំរុញឱ្យមានការសិក្សានេះកើតឡើង។

### ១.៣. វត្ថុបំណងស្រាវជ្រាវ

ការស្រាវជ្រាវនេះផ្តោតទៅលើការបង្រៀននិងរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិនៅក្នុងប្រទេសកម្ពុជាអំឡុងពេលបិទសាលារៀនទូទាំងប្រទេសដោយសារការរីករាលដាលនៃជំងឺកូវីដ-១៩។ ជាមួយនឹងគោលបំណងនេះ ការសិក្សាផ្តោតលើវត្ថុបំណងស្រាវជ្រាវចំនួនពីរដូចខាងក្រោម៖

- សិក្សាឈ្វេងយល់ពីទិដ្ឋភាពទូទៅនៃការបង្រៀននិងរៀននៅតាមគ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិនៅកម្ពុជាអំឡុងពេលបិទសាលារៀនដោយសារវិបត្តិកូវីដ-១៩
- សិក្សាពីប្រសិទ្ធភាពឬគុណភាពនៃការបង្រៀននិងរៀនរបស់គ្រូនិងសិស្សក្នុងអំឡុងពេលបិទសាលារៀនដោយសារវិបត្តិជំងឺកូវីដ-១៩

## ២. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សានេះអនុវត្តតាមដំណាក់កាលនៃវិធីសាស្ត្រស្រាវជ្រាវបរិមាណវិស័យ (Creswell & Cresswell 2018) ដោយប្រើប្រាស់កម្រងសំណួរស្ទង់មតិដើម្បីប្រមូលទិន្នន័យពីក្រុមគោលដៅស្រាវជ្រាវជាគ្រូបង្រៀននិងសិស្សានុសិស្សនៅថ្នាក់មធ្យមសិក្សាទុតិយភូមិ។

### ២.១. សំណាកស្រាវជ្រាវនិងទិន្នន័យ

សំណាកស្រាវជ្រាវចំពោះការសិក្សានេះគឺជាគ្រូបង្រៀននិងសិស្សានុសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិ (ថ្នាក់ទី១០-១២) ដែលបានស្ម័គ្រចិត្តបំពេញកម្រងសំណួរស្ទង់មតិតាមមធ្យោបាយអនឡាញនិងការបំពេញដោយផ្ទាល់នៅក្នុងថ្នាក់រៀន។ ការជ្រើសរើសក្រុមគោលដៅស្រាវជ្រាវទាំងពីរមធ្យោបាយអនុវត្តតាមការស្ម័គ្រចិត្តចូលរួមបំពេញកម្រងសំណួរតាមតំណ URL នៃទម្រង់ Google Form ដែលបានផ្តល់ជូនតាមកម្មវិធីបណ្តាញសង្គមតេឡេក្រាមនិងកម្មវិធី Facebook Messenger (ចំពោះការប្រមូលទិន្នន័យតាមអនឡាញ) និងវិធីជ្រើសរើសសំណាកបែបងាយៗ (convenient sampling technique) ចំពោះការប្រមូលទិន្នន័យដោយផ្ទាល់។ ការជ្រើសរើសក្រុមគោលដៅស្រាវជ្រាវសម្រាប់ការប្រមូលទិន្នន័យដោយផ្ទាល់ធ្វើឡើងតាមដំណាក់កាលបីដូចខាងក្រោម៖

- ដំណាក់កាលទី១៖ ការជ្រើសរើសខេត្ត

អ្នកស្រាវជ្រាវជ្រើសរើសខេត្តនីមួយៗស្ថានភាពជាក់ស្តែងនៃតំបន់នានាក្នុងប្រទេសកម្ពុជា មានដូចជាខេត្តកំពង់ចាម កំពង់ឆ្នាំង កំពត រតនគិរី និងរាជធានីភ្នំពេញ ដែលខេត្តនិងរាជធានីទាំងនេះតំណាងឱ្យតំបន់ទំនាបកណ្តាល ខេត្តជុំវិញបឹងទន្លេសាប តំបន់ឆ្នេរសមុទ្រ តំបន់ខ្ពង់រាប និងរាជធានី។

- ដំណាក់កាលទី២៖ ការជ្រើសរើសសាលារៀន

អ្នកស្រាវជ្រាវបានជ្រើសរើសវិទ្យាល័យរដ្ឋចំនួន២ចេញពីខេត្តនីមួយៗតាមវិធីងាយៗ ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យនៃទីតាំងប្រជុំជនខេត្ត និងស្រុកជនបទ។ ដោយឡែកទីតាំងរាជធានីភ្នំពេញ អ្នកស្រាវជ្រាវបានជ្រើសរើសសាលារៀនចំនួន៨ ក្នុងនោះសាលារដ្ឋមានចំនួន៥ និងសាលាឯកជនមានចំនួន៣ និងផ្អែកលើព័ត៌មានភូមិសាស្ត្រជាសាលារៀនកណ្តាលរាជធានីនិងជាយរាជធានី។

- ដំណាក់កាលទី៣៖ ការជ្រើសរើសគ្រូបង្រៀននិងសិស្ស

ថ្នាក់រៀនចំនួន២ត្រូវបានជ្រើសរើសចេញពីកម្រិតថ្នាក់នីមួយៗដោយប្រើវិធីជ្រើសរើសសំណាកងាយៗ ហើយសិស្សានុសិស្សទាំងអស់ដែលកំពុងសិក្សាក្នុងថ្នាក់ដែលបានជ្រើសរើស ត្រូវបានស្នើសុំឱ្យចូលរួមបំពេញកម្រងសំណួរស្ទង់មតិ។ លោកគ្រូអ្នកគ្រូដែលបង្រៀនថ្នាក់ទី១០ដល់ទី១២នៅវិទ្យាល័យដែលបានជ្រើសរើសទាំងអស់ក៏ត្រូវបានស្នើសុំឱ្យចូលរួមបំពេញកម្រងសំណួរស្ទង់មតិផងដែរ។

គ្រូបង្រៀនសរុបចំនួន 717 នាក់ និងសិស្សចំនួន 3377 នាក់បានចូលរួមក្នុងការសិក្សានេះ ហើយក្នុងចំណោមគ្រូបង្រៀនមានសមាមាត្រ 44.1% ជាស្ត្រី និងក្នុងចំណោមសិស្សានុសិស្សមានសមាមាត្រ 62.5% ជាសិស្សស្រី។

តារាងទី1

*របាយទិន្នន័យសំណាកស្រាវជ្រាវទៅតាមប្រភេទសាលារៀននិងមធ្យោបាយប្រមូលទិន្នន័យ*

| ការប្រមូលទិន្នន័យ | ប្រភេទសាលារៀន | សិស្ស | | សរុប | គ្រូបង្រៀន[១] | | សរុប |
|---|---|---|---|---|---|---|---|
| | | ស្រី | ប្រុស | | ស្រី | ប្រុស | |
| តាមអនឡាញ | សាលារដ្ឋ | 1018 | 618 | 1636 | 235 | 318 | 553 |
| | សាលាឯកជន | 200 | 39 | 239 | 24 | 29 | 53 |
| ប្រមូលផ្ទាល់ | សាលារដ្ឋ | 810 | 538 | 1348 | 42 | 32 | 74 |
| | សាលាឯកជន | 82 | 72 | 154 | 15 | 22 | 37 |
| | សរុប | 2110 | 1267 | 3377 | 316 | 401 | 717 |

[១] គួរបញ្ជាក់ថា ក្នុងបរិបទប្រទេសកម្ពុជា យើងមានការពិបាកក្នុងការកំណត់ថាគ្រូណាម្នាក់បង្រៀននៅសាលារដ្ឋឬឯកជនឱ្យបានច្បាស់លាស់ ដោយសារពេលខ្លះពួកគេបង្រៀននៅសាលាទាំងពីរ ដូចនេះ ក្នុងដំណើរការបំពេញកម្រងសំណួរ អ្នកស្រាវជ្រាវបានស្នើឱ្យគ្រូបង្រៀនជ្រើសរើសប្រភេទសាលារៀនដោយស្ម័គ្រចិត្ត និងបំពេញកម្រងសំណួរទៅតាមស្ថានភាពជាក់ស្តែងនៃសាលារៀនដែលគាត់បានជ្រើសរើស។

### ២.២. ឧបករណ៍ស្រាវជ្រាវ

កម្រងសំណួរស្ទង់មតិចំនួនពីរច្បាប់(មួយសម្រាប់គ្រូនិងមួយទៀតសម្រាប់សិស្ស) ត្រូវបានផលិតឡើងដោយអ្នកស្រាវជ្រាវ និងបានរៀបចំជាបីផ្នែកដូចខាងក្រោម៖

- ផ្នែកទី១៖ ព័ត៌មានផ្ទាល់ខ្លួនរបស់អ្នកចូលរួម
- ផ្នែកទី២៖ ព័ត៌មានអំពីការបង្រៀននិងរៀនក្នុងអំឡុងពេលបិទសាលារៀន
- ផ្នែកទី៣៖ ទស្សនៈអំពីការវាយតម្លៃគុណភាពការបង្រៀនឬរៀនក្នុងអំឡុងពេលបិទសាលារៀន

តារាងទី2

*កម្រិតជឿជាក់និងសុពលភាព (validity) របស់កម្រងសំណួរស្ទង់មតិ*

| | កម្រងសំណួរស្ទង់មតិ | ចំនួនសំណួរ | កម្រិតជឿជាក់ | ការពិនិត្យបោយទិន្នន័យ | | |
|---|---|---|---|---|---|---|
| | | | | Skewedness | Kurtosis | ការសន្និដ្ឋាន[២] |
| គ្រូ | គុណភាពបង្រៀនពេលបិទសាលា | 7 | 0.817 | -0.548 | 0.533 | ណរម៉ាល់ (Normal) |
| សិស្ស | គុណភាពរៀនពេលបិទសាលា | 4 | 0.882 | -0.567 | 0.299 | ណរម៉ាល់ (Normal) |

### ២.៣. ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានត្រូវបានវិភាគដោយប្រើកម្មវិធីវិភាគទិន្នន័យ SPSS កំណែ២៥ និងវិធីវិភាគស្ថិតិបែបពណ៌នា (descriptive statistical methods) និងវិធីវិភាគស្ថិតិបែបវិចារណ៍ (inferential statistical methods)។ តេស្តស្ថិតិ t-Test និង One-Way ANOVA ត្រូវបានប្រើដើម្បីសិក្សាប្រៀបធៀបទស្សនៈរបស់ក្រុមគោលដៅទាក់ទងនឹងលទ្ធផលនៃការបង្រៀននិងរៀនអំឡុងពេលកូវីដ-១៩ ធៀបនឹងអថេរមួយចំនួនដូចជា ភេទ ប្រភេទសាលារៀន ទីតាំងសាលាជាដើម។ ការបកស្រាយពិពណ៌នាអំពីការអនុវត្តការបង្រៀន និងការរៀនដែលយល់ឃើញគឺផ្អែកលើតារាងខាងក្រោម។

តារាងទី3

*លក្ខណៈវិនិច្ឆ័យសម្រាប់បកស្រាយលទ្ធផលវិភាគទាក់ទងនឹងទស្សនៈអំពីការបង្រៀននិងរៀនរបស់គ្រូនិងសិស្ស*

| ចន្លោះតម្លៃ | គុណភាព | ការបកស្រាយ |
|---|---|---|
| 1 - 2 | ទាប | ប្រសិទ្ធភាពការបង្រៀនឬរៀនស្ថិតក្នុងកម្រិតទាប |

[២] ការសន្និដ្ឋាននេះផ្អែកលើការសិក្សារបស់ George & Mallery (2010), Hair et al. (2010) និង Bryne (2010) ដែលបានលើកឡើងថាសម្រាប់សំណាកស្រាវជ្រាវដែលធំជាង៣០០ បោយទិន្នន័យណរម៉ាល់គួរវិនិច្ឆ័យដោយផ្អែកលើតម្លៃ Kurtosis និង Skewness ដោយតម្លៃ Skewness ស្ថិតក្នុងចន្លោះ -2 ទៅ 2 និងតម្លៃ Kurtosis ស្ថិតក្នុងចន្លោះ -7 ទៅ 7 នោះបោយទិន្នន័យមានទម្រង់ណរម៉ាល់។

| | | |
|---|---|---|
| 2 - 3 | ក្រោមមធ្យម | ប្រសិទ្ធភាពការបង្រៀនឬរៀនស្ថិតក្នុងកម្រិតក្រោមមធ្យម |
| 3 - 4 | មធ្យម | ប្រសិទ្ធភាពការបង្រៀនឬរៀនស្ថិតក្នុងកម្រិតមធ្យម |
| 4 - 5 | លើមធ្យម | ប្រសិទ្ធភាពការបង្រៀនឬរៀនស្ថិតក្នុងកម្រិតលើមធ្យម |
| 5 - 6 | ល្អ | ប្រសិទ្ធភាពការបង្រៀនឬរៀនស្ថិតក្នុងកម្រិតល្អ |

**កំណត់សម្គាល់៖** ការគណនាចន្លោះតម្លៃលេខក្នុងតារាងនេះផ្អែកទៅលើតម្លៃមធ្យមដែលតំណាងឱ្យទស្សនៈរបស់ក្រុមគោលដៅ

# ៣. លទ្ធផលស្រាវជ្រាវ

## ៣.១. ព័ត៌មានអំពីអ្នកចូលរួម

ការសិក្សានេះមានការចូលរួមពីគ្រូបង្រៀនចំនួន 717នាក់និងសិស្សវិទ្យាល័យចំនួន 3,377នាក់ ក្នុងនោះគ្រូបង្រៀនភេទស្រីមានសមាមាត្រ 44.1% ដោយឡែកក្នុងចំណោមសិស្សទាំងអស់ 62.5% ជាសិស្សស្រី។ គ្រូបង្រៀនភាគច្រើន (87.4%) បង្រៀននៅសាលារដ្ឋ[៣] ចំណែកគ្រូបង្រៀននៅសាលាឯកជនមាន 12.6%។ ក្នុងចំណោមសិស្សទាំងអស់ ទិន្នន័យបានបង្ហាញថា 88.4% ជាសិស្សរៀននៅសាលារដ្ឋ ដោយឡែកសិស្សរៀននៅសាលាឯកជនមានប្រមាណ 11.6%។ ផ្អែកលើតំបន់ភូមិសាស្ត្រ គ្រូបង្រៀនចំនួន 22.4% បង្រៀននៅរាជធានីភ្នំពេញ ដោយឡែកតំបន់ផ្សេងទៀតដូចជាតំបន់វាលទំនាប, តំបន់ខ្ពង់រាបនិងភ្នំ, ខេត្តជាប់មាត់សមុទ្រ និងខេត្តស្ថិតនៅជុំវិញបឹងទន្លេសាប មានសមាមាត្ររៀងគ្នា 28.5%, 24.1%, 14.1%, 10.9%។ ក្នុងចំណោមសិស្សទាំងអស់ ទិន្នន័យបានបង្ហាញថា សិស្សមកពីរាជធានីភ្នំពេញមាន 19.8% ហើយសិស្សដែលកំពុងសិក្សានៅក្នុងតំបន់វាលទំនាប, ខេត្តជុំវិញបឹងទន្លេសាប, ខេត្តជាប់មាត់សមុទ្រ និងតំបន់ខ្ពង់រាបនិងភ្នំ មានសមាមាត្រ 28.3%, 16.8%, 19.8%, 15.3% រៀងគ្នា។

ទាក់ទងនឹងទីតាំងសាលានិងការសិក្សា លទ្ធផលស្រាវជ្រាវបានបង្ហាញថា សិស្សថ្នាក់ទី១០មានប្រមាណ 30.2%, ថ្នាក់ទី១១ មាន 38.9% និងសិស្សថ្នាក់ទី១២ មាន 30.9% ហើយក្នុងចំណោមនោះ សិស្សដែលសិក្សានៅសាលារៀនកណ្តាលរាជធានីភ្នំពេញមាន 12.8%, សាលាស្ថិតនៅជាយរាជធានីមាន 13.6%, សាលាតាមទីតំបន់ប្រជុំជននៃខេត្តស្រុកនានាមាន 32.6% និងសាលារៀននៅតាមទីជនបទមានប្រមាណ 41.0%។ ជាមួយគ្នានេះ ទិន្នន័យគ្រូបង្រៀនបានបង្ហាញថា 6.1% នៃគ្រូបង្រៀនទទួលបានការសិក្សាក្រោមបរិញ្ញាបត្រ, សិក្សាត្រឹមកម្រិតបរិញ្ញាបត្រមាន 74.3% ខណៈគ្រូដែលទទួលបានសិក្សាដល់ថ្នាក់ក្រោយបរិញ្ញាបត្រមានប្រមាណ 19.5%។ ដោយឡែកផ្អែកលើកម្រិតជំនាញវិជ្ជាជីវៈគ្រូបង្រៀនវិញ លទ្ធផលបានបង្ហាញថាគ្រូបង្រៀន 18.9% ទទួលបានការអប់រំវិជ្ជាជីវៈគ្រូបង្រៀនកម្រិតមូលដ្ឋាន, 8.1% ទទួលបានគ្រូដែលមានការអប់រំកម្រិតមធ្យមសិក្សា ខណៈដែលគ្រូបង្រៀនកម្រិតឧត្តមមាន 73.0%។ លទ្ធផលក៏បានបង្ហាញថា ក្នុងចំណោមគ្រូបង្រៀនទាំងអស់ 25.0% មានបទពិសោធន៍បង្រៀនតិចជាង 5ឆ្នាំ, អ្នកដែលមានបទពិសោធន៍បង្រៀន 5-10ឆ្នាំមាន 18.0% និងគ្រូដែលមានបទពិសោធន៍បង្រៀនលើសពី 10ឆ្នាំមាន 57.0%។ ជាមួយគ្នានេះ គ្រូដែលបង្រៀនមុខវិជ្ជាគណិតវិទ្យាឬមុខវិជ្ជាទាក់ទងនឹងវិទ្យាសាស្ត្រមាន 57.6% ដោយឡែកគ្រូដែលបង្រៀនមុខវិជ្ជាទាក់ទងនឹងវិទ្យាសាស្ត្រសង្គមមាន 42.4%។

[៣] គួរកត់សំគាល់ថា ផ្អែកទៅលើបរិបទនៃការស្រាវជ្រាវ ពាក្យ 'សាលា' ឬ 'សាលារៀន' នៅក្នុងអត្ថបទនេះសំដៅដល់សាលាមធ្យមសិក្សាទុតិយភូមិ និងគ្រូបង្រៀនឬគ្រូ សំដៅដល់គ្រូបង្រៀនកម្រិតមធ្យមសិក្សាទុតិយភូមិ។

## ៣.២. ការបង្រៀននិងរៀនអំឡុងពេលកូវីដ-១៩

### ៣.២.១. ទិដ្ឋភាពទូទៅនៃការបង្រៀននិងរៀន

លទ្ធផលនៃការសិក្សាបានបង្ហាញថា ក្នុងអំឡុងពេលនៃការបិទសាលារៀនទូទាំងប្រទេស មានគ្រូបង្រៀនតែ 4.5% ប៉ុណ្ណោះដែលមិនបានបន្តសកម្មភាពបង្រៀនប្រចាំថ្ងៃរបស់ខ្លួន ដោយឡែកសិស្សានុសិស្សវិញមានរហូតដល់ 17.0% ដែលមិនបានបន្តការរៀនសូត្ររបស់ខ្លួនក្នុងដំណាក់កាលនេះ។ លទ្ធផលក្នុងតារាងទី4ខាងក្រោមបង្ហាញថា ក្នុងចំណោមគ្រូមិនបានបន្តការបង្រៀន មានគ្រូនៅសាលារដ្ឋ 90.6% ខណៈគ្រូនៅសាលាឯកជនមានត្រឹមតែ 9.4% ប៉ុណ្ណោះ។ ធៀបនឹងទីតាំងភូមិសាស្ត្រ គ្រូមិនបានបង្រៀនភាគច្រើន (53.1%) នៅតំបន់ខ្ពង់រាបនិងភ្នំ ដោយឡែកគ្រូរស់នៅរាជធានីភ្នំពេញ, ខេត្តជាប់មាត់សមុទ្រ, ខេត្តតាមតំបន់វាលទំនាប និងខេត្តជុំវិញបឹងទន្លេសាបមានសមាមាត្រ 9.4%, 6.3%, 21.8% និង 9.4% រៀងគ្នា។ ធៀបនឹងទីតាំងសាលារៀន លទ្ធផលបង្ហាញថា មានគ្រូនៅសាលានៅទីជនបទឬតំបន់ដាច់ស្រយាល 71.8%, គ្រូនៅតំបន់ទីប្រជុំជនស្រុក/ខេត្តនានា 18.8% មិនបានបន្តការបង្រៀន ដោយឡែកគ្រូនៅសាលារៀនកណ្ដាលរាជធានីនិងជាយរាជធានីមានសមាមាត្រ 0.0% និង 9.4% រៀងគ្នាដែលមិនបានបន្តបង្រៀនក្នុងអំឡុងពេលបិទសាលា។ ធៀបនឹងកត្តាមុខវិជ្ជាបង្រៀន មានគ្រូ 56.3% បង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម និងគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យាឬវិទ្យាសាស្ត្រពិត 43.7% ដែលមិនបានបន្តការបង្រៀន។ ផ្អែកលើកត្តាបទពិសោធន៍ជាគ្រូបង្រៀន គ្រូដែលធ្លាប់បង្រៀនលើសពី១០ឆ្នាំមាន 62.5%, តិចជាង៥ឆ្នាំមាន 28.1% និងគ្រូដែលមានបទពិសោធន៍បង្រៀនចន្លោះ5-10ឆ្នាំមាន 9.4% ។ ជាមួយគ្នានេះ លទ្ធផលក៏បានបង្ហាញថាមានគ្រូបង្រៀនប្រុស ច្រើនជាងស្រីដែលមិនបានបន្តការបង្រៀនដោយមានសមាមាត្ររៀងគ្នា 59.4% និង 40.6%។

តារាងទី4

*របាយទិន្នន័យអំពីការបង្រៀនឬរៀនរបស់គ្រូនិងសិស្សក្នុងអំឡុងពេលបិទសាលាអាស្រ័យលើកត្តាមួយចំនួន*

| | កត្តា | គ្រូបង្រៀន | | សិស្ស | |
|---|---|---|---|---|---|
| | | បន្តបង្រៀន | មិនបានបង្រៀន | បន្តរៀន | មិនបានរៀន |
| ភេទ | ស្រី | 44.2% | 40.6% | 65.4% | 48.3% |
| | ប្រុស | 55.8% | 59.4% | 36.6% | 51.7% |
| ប្រភេទសាលា | សាលារដ្ឋ | 87.3% | 90.6% | 87.3% | 93.5% |
| | សាលាឯកជន | 12.7% | 9.4% | 12.7% | 6.5% |
| ទីតាំងសាលា | កណ្ដាលរាជធានី | 14.7% | 0.0% | 13.6% | 8.9% |
| | ជាយរាជធានី | 8.2% | 9.4% | 14.6% | 8.9% |
| | ទីប្រជុំជនស្រុក/ខេត្ត | 24.7% | 18.8% | 32.6% | 32.1% |
| | ជនបទ/ដាច់ស្រយាល | 52.4% | 71.8% | 39.2% | 50.1% |
| តំបន់ភូមិសាស្ត្រ | រាជធានីភ្នំពេញ | 23.0% | 9.4% | 21.0% | 13.6% |
| | តំបន់វាលទំនាប | 28.8% | 21.8% | 28.1% | 29.4% |
| | ជុំវិញបឹងទន្លេសាប | 11.0% | 9.4% | 15.3% | 24.6% |
| | តំបន់មាត់សមុទ្រ | 14.5% | 6.3% | 19.5% | 21.0% |

| | | | | | |
|---|---|---|---|---|---|
| | ខ្ពង់រាបឬតំបន់ភ្នំ | 22.7% | 53.1% | 16.1% | 11.4% |
| មុខវិជ្ជាបង្រៀន | គណិត/វិទ្យាសាស្ត្រ | 58.2% | 43.8% | - | - |
| | វិទ្យាសាស្ត្រសង្គម | 41.8% | 56.2% | - | - |
| បទពិសោធន៍បង្រៀន | តិចជាង៥ឆ្នាំ | 24.9% | 28.1% | - | - |
| | ចន្លោះ៥-១០ឆ្នាំ | 18.4% | 9.4% | - | - |
| | លើសពី១០ឆ្នាំ | 56.7% | 62.5% | - | - |
| កម្រិតថ្នាក់ | ថ្នាក់ទី១០ | - | - | 31.3% | 25.0% |
| | ថ្នាក់ទី១១ | - | - | 39.2% | 37.5% |
| | ថ្នាក់ទី១២ | - | - | 29.5% | 37.5% |

លទ្ធផលពីទិន្នន័យសិស្សបង្ហាញថា ក្នុងចំណោមសិស្សានុសិស្សដែលពុំបានបន្តការសិក្សាក្នុងអំឡុងពេលបិទសាលារៀនមាន 29.4% មកពីខេត្តក្នុងតំបន់វាលទំនាប, 24.7% មកពីខេត្តជុំវិញបឹងទន្លេសាប, ខេត្តជាប់មាត់សមុទ្រមាន 21.0%, រាជធានីភ្នំពេញមាន 13.6% និងខេត្តនៅតំបន់ខ្ពង់រាបនិងភ្នំមាន 11.4%។ ជាមួយនឹងទីតាំងសាលារៀនសិស្សមិនបានបន្តការសិក្សាសាលារៀនតាមទីជនបទឬតំបន់ដាច់ស្រយាលមាន 50.1%, សាលារៀនតាមទីប្រជុំជនខេត្ត/ស្រុកនានាមាន 32.1%, សាលាជាយរាជធានីនិងកណ្តាលរាជធានីមាន 8.9% ដូចគ្នា។ សិស្សមិនបានបន្តការសិក្សាភាគច្រើន (93.5%) សិក្សានៅសាលារដ្ឋ ដោយឡែកសាលាឯកជនមានតែ 6.5% ប៉ុណ្ណោះ។ សិស្សប្រុសប្រមាណ 51.7% មិនបានបន្តរៀន និងសិស្សស្រី 48.3% មិនបានបន្តរៀន។

ពាក់ព័ន្ធនឹងវិធីបង្រៀននិងរៀនក្នុងអំឡុងពេលបិទសាលា លទ្ធផលបានបង្ហាញថា គ្រូប្រមាណ 32.7% នៃការឆ្លើយតប បង្រៀនដោយប្រើវិធីចែកឯកសារសិក្សាឌីជីថល(pdf)តាមអ៊ីនធឺណិតដល់សិស្ស, ការបង្រៀនដោយប្រើប្រាស់វីដេអូអនឡាញមាន 27.0%, បង្រៀនតាមប្រព័ន្ធគ្រប់គ្រងការរៀន (LMS) មាន 26.2%, ថតចម្លងឯកសារឬកិច្ចការនិងចែកដល់សិស្សយកទៅរៀននៅផ្ទះដោយខ្លួនឯងមាន 12.4% ដោយឡែកការបង្រៀនដោយប្រើកម្មវិធីទូរទស្សន៍មានតែ 1.7% ប៉ុណ្ណោះ។ លទ្ធផលរបស់សិស្សបានបង្ហាញថា 32.2% រៀនតាមវីដេអូនអនឡាញផ្ទាល់, 19.5% រៀនតាមប្រព័ន្ធគ្រប់គ្រងការរៀន, 13.9% រៀនតាមបណ្តាញសង្គមនានា, 10.2% រៀនតាមឯកសារឌីជីថលដែលគ្រូចែកឱ្យ, 14.2% រៀនតាមឯកសារឬសន្លឹកកិច្ចការដែលគ្រូថតចម្លងនិងចែកឱ្យ ដោយឡែកអ្នកដែលរៀនតាមកម្មវិធី E-Learning Apps មានតែ 9.5% ប៉ុណ្ណោះ។

តារាងទី5

*របាយទិន្នន័យអំពីវិធី/របៀបបង្រៀននិងរៀនរបស់គ្រូនិងសិស្សក្នុងអំឡុងពេលបិទសាលារៀន*

| វិធីបង្រៀននិងរៀនអំឡុងពេលបិទសាលា | គ្រូបង្រៀន | | សិស្សរៀន | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| តាមវីដេអូអនឡាញផ្ទាល់ (Video Call) | 328 | 27.0% | 1889 | 32.2% |
| ឯកសារឬក្រដាសកិច្ចការថតចម្លងនិងចែក | 150 | 12.4% | 637 | 10.2% |
| ចែក/តាមឯកសារសិក្សាឌីជីថលអ៊ីនធឺណិត | 397 | 32.7% | 888 | 14.2% |

| | | | | |
|---|---|---|---|---|
| តាមប្រព័ន្ធគ្រប់គ្រងការរៀន (LMS) | 318 | 26.2% | 1223 | 19.5% |
| បង្រៀនតាមកម្មវិធីទូរទស្សន៍ | 21 | 1.7% | 158 | 2.5% |
| តាមបណ្ដាញសង្គមនានា | - | - | 869 | 13.9% |
| តាមកម្មវិធី E-Learning Apps មួយចំនួន | - | - | 596 | 9.5% |

ជាមួយគ្នានេះ ឧបករណ៍ដែលប្រើប្រាស់ច្រើនសម្រាប់បង្រៀនគឺទូរសព្ទ (52.5%), ឧបករណ៍ Tablet/iPad មាន 14.9% ដោយឡែកឧបករណ៍ កុំព្យូទ័រ(Desktop/Laptop) វិញមានតែ 42.6% ប៉ុណ្ណោះ។ ចំពោះទិន្នន័យសិស្ស លទ្ធផលបង្ហាញថា ការប្រើប្រាស់ទូរសព្ទមាន 93.3%, ឧបករណ៍ Tablet/iPad មាន 1.7% ដោយឡែកកុំព្យូទ័រ (Desktop/Laptop) វិញមានតែ 5.0% ប៉ុណ្ណោះ។

តារាងទី6

*របាយទិន្នន័យអំពីប្រភេទឧបករណ៍ប្រើប្រាស់ដើម្បីបង្រៀននិងរៀនអំឡុងពេលមានការបិទសាលារៀន*

| ឧបករណ៍បង្រៀននិងរៀន | គ្រូបង្រៀន | | សិស្ស | |
|---|---|---|---|---|
| | ចំនួនចម្លើយ | ភាគរយ | ចំនួនចម្លើយ | ភាគរយ |
| ទូរសព្ទដៃ | 535 | 52.5% | 2626 | 93.3% |
| Tablet/iPad | 50 | 4.9% | 48 | 1.7% |
| កុំព្យូទ័រ(Desktop/Laptop) | 434 | 42.6% | 140 | 5.0% |

ទាក់ទិននឹងសេវាអ៊ីនធឺណិត លទ្ធផលបង្ហាញថា គ្រូបង្រៀនទាំងអស់ប្រើប្រាស់សេវាអ៊ីនធឺណិតតាមទូរសព្ទនិងប្រព័ន្ធ Wi-Fi ដើម្បីបង្រៀនពីចម្ងាយ ក្នុងនោះ អ៊ីនធឺណិតតាមទូរសព្ទមាន 63.1% និង 36.9% ជាអ៊ីនធឺណិតតាម Wi-Fi។ ដោយឡែកទិន្នន័យរបស់សិស្សបង្ហាញថា ពួកគេប្រើប្រាស់អ៊ីនធឺណិតតាមទូរសព្ទច្រើនជាងគេលើសលុប (79.8%) ដោយឡែកអ៊ីនធឺណិតតាមខ្សែកាបមានតែ 1.6% ប៉ុណ្ណោះ។

តារាងទី7

*របាយទិន្នន័យអំពីប្រភេទអ៊ីនធឺណិតប្រើប្រាស់ដើម្បីបង្រៀននិងរៀនអំឡុងពេលមានការបិទសាលារៀន*

| ប្រភេទអ៊ីនធឺណិត | គ្រូបង្រៀន | | សិស្ស | |
|---|---|---|---|---|
| | ចំនួនចម្លើយ | ភាគរយ | ចំនួន | ភាគរយ |
| អ៊ីនធឺណិតទូរសព្ទដៃ | 547 | 63.1% | 2400 | 79.8% |
| អ៊ីនធឺណិតខ្សែកាប | - | - | 49 | 1.6% |
| សរុបអ៊ីនធឺណិត Wi-Fi | 320 | 36.9% | 560 | 18.6% |

ទាក់ទងនឹងគុណភាពអ៊ីនធឺណិត ទិន្នន័យបង្ហាញថា គ្រូបង្រៀនចំនួន 53.8% និង សិស្សប្រមាណ 57.5% យល់ថាគុណភាពអ៊ីនធឺណិតរបស់គេមានល្បឿនលឿនឬអាចប្រើការបាន។

តារាងទី8

*របាយទិន្នន័យអំពីគុណភាពអ៊ីនធឺណិតប្រើប្រាស់ដើម្បីបង្រៀននិងរៀនអំឡុងពេលមានការបិទសាលារៀន*

| គុណភាពអ៊ីនធឺណិត | គ្រូបង្រៀន | | សិស្ស | |
|---|---|---|---|---|
| | ចំនួន | ភាគរយ | ចំនួន | ភាគរយ |
| យឺតខ្លាំងណាស់(ប្រើមិនកើត) | 49 | 7.2% | 275 | 9.8% |
| យឺតនិងប្រើដាច់ៗ | 267 | 39.0% | 918 | 32.7% |
| អាចប្រើប្រាស់បាន | 337 | 49.3% | 1454 | 51.9% |
| លឿនឬមិនរអាក់រអួល | 31 | 4.5% | 129 | 4.6% |
| លឿនខ្លាំងឬល្អឥតខ្ចោះ | - | - | 28 | 1.0% |

### ៣.២.២. ប្រសិទ្ធភាពនៃការបង្រៀននិងរៀន

ដូចបានបង្ហាញក្នុង ចំណុច៣.២.១ ខាងលើ មានគ្រូបង្រៀន 95.5% និងសិស្ស 83.0% ដែលនៅបន្តការបង្រៀននិងរៀនក្នុងអំឡុងពេលបិទសាលារៀនទូទាំងប្រទេស ដូចនេះ លទ្ធផលស្រាវជ្រាវនៅក្នុងផ្នែកនេះ គឺជាការវិភាគទិន្នន័យដែលចេញពីសំណាកស្រាវជ្រាវដែលបានបន្តសកម្មភាពបង្រៀននិងរៀនក្នុងអំឡុងពេលបិទសាលារៀននៅទូទាំងប្រទេស។

ផ្អែកទៅលើលក្ខណៈវិនិច្ឆ័យក្នុងតារាងទី3 ខាងលើ លទ្ធផលនៃការស្រាវជ្រាវនេះបានបង្ហាញថា ការយល់ឃើញរបស់គ្រូបង្រៀនទាក់ទងនឹងប្រសិទ្ធភាពឬគុណភាពនៃការបង្រៀនរបស់ពួកគេក្នុងអំឡុងពេលបិទសាលារៀនស្ថិតក្នុងកម្រិតខ្ពស់ជាងមធ្យមបន្តិច (Mean=4.07, SD=0.916) ដោយឡែកចំពោះសិស្សានុសិស្សវិញ ពួកគេបានយល់ថាប្រសិទ្ធភាពឬគុណភាពនៃការសិក្សារបស់ពួកគេក្នុងអំឡុងពេលនេះស្ថិតក្នុងកម្រិតមធ្យម (Mean=3.73, SD= 1.28) ។ ទិន្នន័យបង្ហាញថា 42.9% នៃគ្រូបង្រៀនយល់ថាប្រសិទ្ធភាពនៃការបង្រៀនរបស់ពួកគេក្នុងអំឡុងបិទសាលារៀនស្ថិតក្នុងកម្រិត "លើមធ្យម" ស្របពេលដែលប្រសិទ្ធភាពកម្រិតខ្ពស់មានតែ 17.7%។ ផ្អែកលើទិន្នន័យនេះ គ្រូបង្រៀនជាង៦០% យល់ថាការបង្រៀនរបស់ពួកគេអាចទទួលយកបាន(លើមធ្យម)។ ជាមួយគ្នានេះ ទិន្នន័យសិស្សបានបង្ហាញថា សិស្សានុសិស្សប្រមាណ 35.9% យល់ថាប្រសិទ្ធភាពនៃការរៀនរបស់ពួកគេក្នុងអំឡុងបិទសាលារៀនស្ថិតក្នុងកម្រិត "លើមធ្យម" ដោយឡែកអ្នកដែលយល់ថាគុណភាពស្ថិតក្នុងកម្រិតខ្ពស់មានតែ 18.3%។ ជាលទ្ធផល មានសិស្សជាង ៥០% យល់ថាការរៀនរបស់ពួកក្នុងអំឡុងពេលបិទសាលារៀនមានកម្រិតអាចទទួលយកបាន។

រូបភាពទី1

*របាយទិន្នន័យអំពីប្រសិទ្ធភាពឬគុណភាពនៃការបង្រៀននិងរៀនរបស់គ្រូនិងសិស្សក្នុងអំឡុងពេលបិទសាលារៀន*



លទ្ធផលតេស្តស្ថិតិ t-Test និង One-way ANOVA ក្នុងការប្រៀបធៀបប្រសិទ្ធភាពការបង្រៀននិងរៀន ផ្អែកទៅលើកត្តាមួយចំនួនបង្ហាញថា ប្រសិទ្ធភាពនៃការបង្រៀនរបស់គ្រូពុំមានភាពខុសប្លែកគ្នានោះទេអាស្រ័យលើកត្តាភេទ, ទីតាំងសាលារៀន, ប្រភេទសាលា, តំបន់ភូមិសាស្ត្រ, បទពិសោធន៍បង្រៀន និង មុខវិជ្ជាបង្រៀនរបស់គ្រូ (តារាងទី9)។ ក៏ប៉ុន្តែ ប្រសិទ្ធភាពការបង្រៀនខុសគ្នាអាស្រ័យលើល្បឿនអ៊ីនធឺណិតដែលលោកគ្រូអ្នកគ្រូប្រើប្រាស់ដើម្បីបង្រៀន។ លទ្ធផលបានបង្ហាញថា គ្រូដែលមានមានល្បឿនអ៊ីនធឺណិតលឿន (Mean=4.39) និងល្បឿនអាចទទួលយកបាន (Mean=4.08) បង្រៀនបានប្រសើរជាងគ្រូដែលមានល្បឿនអ៊ីនធឺណិតយឺតខ្លាំង (Mean=3.55)។

លទ្ធផលទាក់ទងនឹងប្រសិទ្ធភាពនៃការរៀនរបស់សិស្សបានបង្ហាញពីភាពខុសគ្នា ផ្អែកលើកត្តាភេទ កម្រិតថ្នាក់ ទីតាំងសាលារៀន តំបន់ភូមិសាស្ត្រ និង ប្រភេទសាលា។ ជាលទ្ធផល ក្នុងអំឡុងពេលបិទសាលារៀននេះ ការសិក្សារបស់សិស្សស្រី (Mean=3.82) ហាក់មានភាពប្រសើរជាងសិស្សប្រុស (Mean=3.55) និង សិស្សរៀននៅសាលាឯកជន (Mean=3.97) រៀនបានប្រសើរជាងសិស្សនៅសាលារដ្ឋ (Mean=3.69)។ លទ្ធផលតេស្ត Post hoc របស់ One-way ANOVA ទៅលើកត្តាតំបន់ភូមិសាស្ត្រ, ទីតាំងសាលារៀន និង កម្រិតថ្នាក់បានបង្ហាញថាប្រសិទ្ធភាពនៃការរៀនរបស់សិស្សនៅរាជធានីភ្នំពេញ (Mean=3.83), ខេត្តជុំវិញបឹងទន្លេសាប (Mean=3.90) និង ខេត្តនៅតាមតំបន់វាលទំនាប (Mean=3.80) មានភាពប្រសើរជាងសិស្សនៅតាមបណ្ដាខេត្តជាប់មាត់សមុទ្រ (Mean=3.55) និងខេត្តតាមតំបន់ខ្ពង់រាបនិងភ្នំ (Mean=3.55)។ បន្ថែមពីលើនេះ សិស្សនៅសាលារៀនជាយរាជធានី (Mean=3.94) ទទួលបានការសិក្សាប្រសើរជាងសិស្សនៅតាមសាលារៀនកណ្ដាលរាជធានី (Mean=3.73) និង សាលារៀនតាមទីជនបទឬតំបន់ដាច់ស្រយាល (Mean=3.74)។ ទន្ទឹមគ្នានេះ លទ្ធផលពីទិន្នន័យសិស្សក៏បង្ហាញថាសិស្សានុសិស្សថ្នាក់ទី១០ (Mean=3.84) ទទួលបានការសិក្សាប្រសើរជាងសិស្សថ្នាក់ទី១១ (Mean=3.70) និងថ្នាក់ទី១២ (Mean=3.67)។ លទ្ធផលចំពោះភាពខុសគ្នាទាក់ទងនឹងល្បឿនអ៊ីនធឺណិតបានបង្ហាញថា សិស្សដែលរៀនដោយមានល្បឿនអ៊ីនធឺណិតល្អ ទទួលបានការសិក្សាល្អប្រសើរដូចគ្នា (តារាងទី9)។

តារាងទី9

*លទ្ធផលតេស្តស្ថិតិ t-Test និង One-way ANOVA ប្រៀបធៀបប្រសិទ្ធភាពនៃការបង្រៀននិងរៀនធៀបនឹងកត្តាមួយចំនួន*

| កត្តាប្រៀបធៀប | | តម្លៃវិភាគស្ថិតិទិន្នន័យគ្រូនិងសិស្ស | |
|---|---|---|---|
| | | ការបង្រៀន | ការរៀន |
| ភេទ | ស្រី | 4.10 | 3.82 |
| | ប្រុស | 4.05 | 3.55 |
| | *p-value* | *0.122* | ***0.000*** |
| កម្រិតថ្នាក់ | ថ្នាក់ទី១០ | - | 3.84 |
| | ថ្នាក់ទី១១ | - | 3.70 |
| | ថ្នាក់ទី១២ | - | 3.67 |
| | *p-value* | - | ***0.009*** |
| ប្រភេទសាលា | សាលារដ្ឋ | 4.05 | 3.69 |
| | សាលាឯកជន | 4.20 | 3.97 |
| | *p-value* | *0.871* | ***0.000*** |
| តំបន់ភូមិសាស្ត្រ | រាជធានីភ្នំពេញ | 4.16 | 3.83 |

| | | | |
|---|---|---|---|
| | តំបន់វាលទំនាប | 4.05 | 3.80 |
| | ខេត្តជុំវិញបឹងទន្លេសាប | 4.06 | 3.90 |
| | ខេត្តជាប់មាត់សមុទ្រ | 4.06 | 3.55 |
| | តំបន់ខ្ពង់រាប/ភ្នំ | 4.00 | 3.55 |
| | *p-value* | *0.658* | ***0.000***$^{***}$ |
| ទីតាំងសាលា | កណ្ដាលរាជធានី | 4.15 | 3.73 |
| | តំបន់ជាយរាជធានី | 4.18 | 3.94 |
| | ប្រជុំជនស្រុក/ខេត្ត | 4.09 | 3.63 |
| | ជនបទ/ដាច់ស្រយាល | 4.02 | 3.74 |
| | *p-value* | *0.395* | ***0.001***$^{**}$ |
| គុណភាពអ៊ីនធឺណិត | ល្បឿនយឺតខ្លាំង | 3.72 | 3.12 |
| | ល្បឿនយឺត | 4.08 | 3.61 |
| | ល្បឿនអាចប្រើបាន | 4.08 | 3.88 |
| | ល្បឿនលឿន | 4.39 | 4.10 |
| | ល្បឿនលឿនខ្លាំង | - | 4.47 |
| | *p-value* | ***0.011***$^{*}$ | ***0.000***$^{***}$ |
| មុខវិជ្ជាបង្រៀន | គណិត/វិទ្យាសាស្ត្រ | 4.04 | - |
| | វិទ្យាសាស្ត្រសង្គម | 4.10 | - |
| | *p-value* | *0.444* | - |
| បទពិសោធន៍បង្រៀន | តិចជាង៥ឆ្នាំ | 4.00 | - |
| | ចន្លោះ ៥-១០ឆ្នាំ | 4.00 | - |
| | លើស ១០ឆ្នាំ | 4.12 | - |
| | *p-value* | *0.303* | - |

សម្គាល់៖ តម្លៃប្រូបាបនៃតេស្ត Significance៖ $^{*}p < .05$, $^{**}p < .01$ និង $^{***}p < .001$

## ៤. ការពិភាក្សា

លទ្ធផលនៃការស្រាវជ្រាវអំពីការបង្រៀននិងរៀននៅថ្នាក់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជាក្នុងអំឡុងនៃការបិទសាលារៀនទូទាំងប្រទេសនេះបានបង្ហាញថាគ្រូបង្រៀនប្រមាណ 4.5% និង សិស្សានុសិស្សប្រមាណ 17.0% មិនបានបន្តសកម្មភាពបង្រៀននិងរៀនរបស់ខ្លួន។ ផ្អែកទិន្នន័យនេះ វាមិនអាក្រក់ពេកនោះទេសម្រាប់លទ្ធផលនៃការបង្រៀន ក៏ប៉ុន្តែ លទ្ធផលទាក់ទងនឹងការរៀនរបស់សិស្សហាក់មានភាពធ្ងន់ធ្ងរបន្តិច។ ទោះបីជាការសិក្សានេះពុំផ្ដោតទៅលើមូលហេតុនៃការមិនបន្តសកម្មភាពបង្រៀននិងរៀនក្ដី សិក្សាមួយចំនួនបានបញ្ជាក់ថា កត្តាអ៊ីនធឺណិត សម្ភារៈ បរិក្ខារ និង ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាដែលគាំទ្រដល់ការបង្រៀននិងរៀនពីចម្ងាយ (Chhy, 2020; Heng & Sol, 2021; MoEYS & ESWG, 2021; Thy et al., 2023) អាចជាបញ្ហាចម្បងដែលរាំងស្ទះដល់សកម្មភាពទាំងនេះ។ ជាមួយគ្នានេះ MoEYS (2020) និង Thy et al. (2023) ក៏បានលើកឡើងអំពីបញ្ហាប្រឈមនៃការបង្រៀននិងរៀនដោយបានគូសបញ្ជាក់ពីទិដ្ឋភាពអាក្រក់ខ្លាំងសម្រាប់គ្រូបង្រៀននិងសិស្សនៅតាមតំបន់មានការរីកចម្រើនទាបឬតំបន់ជនបទដាច់ស្រយាល។ លទ្ធផលនេះពុំមានអ្វីចម្លែកនោះទេបើគិតតាមស្ថានភាពជាក់ស្ដែង ដោយសារគ្រូបង្រៀនចាំបាច់ត្រូវបំពេញ

កាតព្វកិច្ចរបស់ខ្លួន ដោយឡែកចំណេះដឹងផ្នែកបច្ចេកវិទ្យាសម្រាប់វិស័យអប់រំទៀតសោធក៏អាចនឹងខ្ពស់ជាងសិស្ស។ របាយការណ៍របស់ Open Development Cambodia (2021) បានបង្ហាញថា ក្នុងអំឡុងនៃការបិទសាលារៀន កំណើនគ្រូបង្រៀនប្រើប្រាស់បច្ចេកវិទ្យាមានវិសាលភាពខ្ពស់ជាងសិស្សច្រើន ដោយកំណើនលើគ្រូបង្រៀនមានប្រមាណ 82.0% ធៀបនឹងសិស្សមានតែ 37.0% ប៉ុណ្ណោះ។ បន្ថែមពីលើនេះ គ្រូបង្រៀនមួយចំនួនក៏បានបញ្ជាក់ផងដែរថា សិស្សជាច្រើនបានអវត្តមាននិងសិស្សខ្លះសឹងតែមិនបានចូលរៀនតាមថ្នាក់អនឡាញរបស់គាត់ផងក៏មាន[៤] ដែលចំណុចទាំងនេះក៏អាចជាកត្តាដែលធ្វើឱ្យអត្រាសិស្សមិនបានរៀនខ្ពស់ជាងអត្រាគ្រូដែលមិនបានបង្រៀនក្នុងអំឡុងនៃការបិទសាលារៀនទូទាំងប្រទេស។

ជាលទ្ធផលស្រាវជ្រាវ ទិន្នន័យបង្ហាញថាប្រសិទ្ធភាពការបង្រៀនស្ថិតក្នុងកម្រិតលើមធ្យមបន្តិចបន្តួច ដោយឡែកការរៀនស្ថិតក្នុងកម្រិតមធ្យមប៉ុណ្ណោះ។ ទោះជាយ៉ាងណា លទ្ធផលនេះបានមកពីការធ្វើស្វ័យវាយតម្លៃពីស្ថានភាពការបង្រៀននិងរៀនរបស់ខ្លួន ដែលស្ថានភាពជាក់ស្តែងអាចនឹងអាក្រក់ជាងនេះក៏ថាបាន។ ការផ្លាស់ប្តូរលឿនពេកក្នុងការទទួលយកបច្ចេកវិទ្យា ទើបធ្វើឱ្យគ្រូនិងសិស្សមិនទាន់បានត្រៀមខ្លួនរួចរាល់ក្នុងការទទួលយកបរិបទនេះ ដែលនេះក៏អាចជាមូលហេតុនៃការធ្លាក់ចុះនៃគុណភាពបង្រៀននិងរៀនផងដែរ។ Chea et al. (2022) បានគូសបញ្ជាក់ថា គ្រូបង្រៀននៅកម្ពុជាមិនទាន់បានត្រៀមខ្លួននោះទេក្នុងការប្រើប្រាស់បច្ចេកវិទ្យាក្នុងការបង្រៀន។ Thy et al. (2023) បានរកឃើញថា ក្នុងអំឡុងពេលបិទសាលារៀន គ្រូនិងសិស្សក៏ជួបប្រទះនូវបញ្ហាប្រឈមទាក់ទងនឹងផ្លូវចិត្ត និង សេដ្ឋកិច្ចគ្រួសារផងដែរ។ ស្ថានភាពហិរញ្ញវត្ថុធ្លាក់ចុះ គួបផ្សំជាមួយនឹងការភ័យខ្លាចពីការឆ្លងជំងឺកូវី-១៩ អាចជាកត្តាដែលធ្វើឱ្យមានការប៉ះពាល់ដល់កម្លាំងចិត្តក្នុងការបំពេញការងារ ការបង្រៀន ឬ រៀនផងដែរ។

## ៥. សន្និដ្ឋាននិងអនុសាសន៍

### ៥.១. សេចក្តីសន្និដ្ឋាន

ជាការពិត វិបត្តិជំងឺកូវីដ-១៩បាននាំមកនូវផលប៉ះពាល់អវិជ្ជមានយ៉ាងធ្ងន់ធ្ងរទៅលើវិស័យអប់រំនៅកម្ពុជានិងបានឈានទៅដល់ការដាក់វិធានការបិទសាលារៀននៅទូទាំងប្រទេសក្នុងរយៈពេលយូរ។ ដោយមានការសហការគ្នាយ៉ាងសកម្មរវាងក្រសួងអប់រំយុវជននិងកីឡាជាមួយដៃគូអភិវឌ្ឍជាច្រើន សកម្មភាពអប់រំគ្រប់កម្រិតថ្នាក់បានបន្តក្នុងកម្រិតមួយ និងបានប្តូរពីការបង្រៀននិងរៀនក្នុងថ្នាក់ ផ្ទាល់ទៅជាការបង្រៀននិងរៀនពីចម្ងាយតាមមធ្យោបាយដែលអាចប្រព្រឹត្តទៅបានអាស្រ័យលើស្ថានភាពជាក់ស្តែងនៃតំបន់ភូមិសាស្ត្រ បច្ចេកវិទ្យា និង កត្តាមួយចំនួនទៀត។ ការស្រាវជ្រាវពីផលប៉ះពាល់នៃវិបត្តិកូវីដ-១៩មកលើការបង្រៀននិងរៀនរបស់គ្រូនិងសិស្សនៅថ្នាក់មធ្យមសិក្សាទុតិយភូមិនៅកម្ពុជានេះ មានវត្ថុបំណងចម្បងគឺសិក្សាពីទិដ្ឋភាពនៃដំណើរការបង្រៀននិងរៀនរបស់គ្រូនិងសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិ និង វាស់វែងអំពីកម្រិតប្រសិទ្ធភាពនៃការបង្រៀននិងរៀនរបស់គ្រូនិងសិស្សក្នុងអំឡុងនៃការបិទ

[៤] គួរបញ្ជាក់ថា ខ្លឹមសារនៅត្រង់ចំណុចនេះបានមកពីការសន្ទនាក្រៅផ្លូវការរវាងអ្នកស្រាវជ្រាវជាមួយមិត្តរួមការងារ និងគ្រូបង្រៀនមួយចំនួនក្នុងអំឡុងពេលនៃការប្រមូលទិន្នន័យ។

សាលារៀនទូទាំងប្រទេស។ ការសិក្សាមានការចូលរួមពីក្រុមគោលដៅជាគ្រូបង្រៀនចំនួន 717នាក់ និងសិស្សានុសិស្សចំនួន 3,377នាក់ ដែលបានបំពេញកម្រងសំណួរស្ទង់មតិដែលរៀបចំដោយអ្នកស្រាវជ្រាវ។

លទ្ធផលស្រាវជ្រាវនេះបានបង្ហាញថាមានគ្រូបង្រៀនចំនួន 4.5% និងសិស្សថ្នាក់មធ្យមសិក្សាទុតិយភូមិចំនួន 17.0% មិនបានបន្តសកម្មភាពបង្រៀននិងរៀនរបស់ខ្លួននោះទេក្នុងអំឡុងនៃការបិទសាលារៀន។ ទិដ្ឋភាពនេះមានសភាពធ្ងន់ធ្ងរក្នុងចំណោមគ្រូនិងសិស្សនៅតាមសាលារៀនស្ថិតនៅតាមទីជនបទឬឆ្ងាយពីទីប្រជុំជន។ សមាមាត្រគ្រូនិងសិស្សនៅសាលារៀនរដ្ឋដែលមិនបានបន្តសកម្មភាពបង្រៀននិងរៀនរបស់ខ្លួនមានចំនួនច្រើនលើសលុប បើធៀបនឹងសមាមាត្រគ្រូនិងសិស្សក្នុងសាលាឯកជន។ ទិដ្ឋភាពនេះក៏មានសភាពធ្ងន់ធ្ងរក្នុងចំណោមគ្រូបង្រៀនមុខវិជ្ជាវិទ្យាសាស្ត្រសង្គម ធៀបនឹងគ្រូបង្រៀនមុខវិជ្ជាគណិតវិទ្យាឬវិទ្យាសាស្ត្រ និងក្នុងចំណោមសិស្សថ្នាក់ទី១១និងទី១២ បើធៀបនឹងសិស្សថ្នាក់ទី១០។ សកម្មភាពបង្រៀននិងរៀនក្នុងអំឡុងពេលបិទសាលាកើតមានក្រោមរូបភាពផ្សេងៗដូចជាការបង្រៀននិងរៀនតាមវីដេអូអនឡាញផ្ទាល់, ការបង្រៀននិងរៀនដោយចែកឯកសារឬក្រដាសកិច្ចការ, ការចែកចាយឯកសារឌីជីថល, ការបង្រៀននិងរៀនតាមប្រព័ន្ធគ្រប់គ្រងការរៀន (LMS), ការបង្រៀននិងរៀនតាមកម្មវិធីទូរទស្សន៍, ការបង្រៀននិងរៀនតាមប្រព័ន្ធបណ្ដាញសង្គម និង ការរៀនតាមកម្មវិធី E-Learning ជាដើម។ លទ្ធផលក៏បានបង្ហាញថា គ្រូនិងសិស្សបានប្រើប្រាស់មធ្យោបាយបង្រៀនឬរៀនពីចម្ងាយមួយឬច្រើនប្រភេទក្នុងចំណោមវិធីខាងលើ អាស្រ័យទៅតាមស្ថានភាពជាក់ស្ដែងរបស់គាត់។

លទ្ធផលទាក់ទងនឹងប្រសិទ្ធភាពនៃការបង្រៀននិងរៀនបានបង្ហាញថាការបង្រៀនរបស់គ្រូស្ថិតក្នុងកម្រិតលើមធ្យមបន្តិចបន្តួច ដោយឡែកប្រសិទ្ធភាពនៃការរៀនរបស់សិស្សស្ថិតក្នុងកម្រិតមធ្យម។ បន្ថែមពីលើនេះ ការបង្រៀនរបស់គ្រូពុំបង្ហាញនូវភាពខុសគ្នានោះទេផ្អែកតាមកត្តាភេទ ប្រភេទសាលារៀន មុខវិជ្ជាបង្រៀន ទីតាំងសាលារៀន តំបន់ភូមិសាស្ត្រ និងកត្តាបទពិសោធន៍បង្រៀន ប៉ុន្តែប្រសិទ្ធភាពការបង្រៀនរបស់គ្រូមានភាពខុសគ្នាផ្អែកលើកត្តាគុណភាពសេវាអ៊ីនធឺណិតដែលប្រើប្រាស់ដើម្បីបង្រៀន។ គ្រូដែលមានគុណភាពសេវាអ៊ីនធឺណិតប្រសើរឬអាចប្រើការបានបង្រៀនបានប្រសើរជាងគ្រូដែលប្រឈមនឹងគុណភាពសេវាអ៊ីនធឺណិត។ ផ្ទុយពីការបង្រៀនរបស់គ្រូ លទ្ធផលរបស់សិស្សបានបង្ហាញថា ប្រសិទ្ធភាពនៃការរៀនរបស់គេមានភាពខុសប្លែកគ្នាផ្អែកលើកត្តាភេទ ទីតាំងសាលារៀន ប្រភេទសាលារៀន តំបន់ភូមិសាស្ត្រ កម្រិតថ្នាក់ និងគុណភាពសេវាអ៊ីនធឺណិតដែលពួកគេប្រើប្រាស់។ សិស្សស្រីរៀនបានប្រសើរជាងសិស្សប្រុស, សិស្សនៅតំបន់ឬសាលារៀនដែលមានស្ថានភាពល្អ រៀនបានប្រសើរជាងសិស្សនៅតាមតំបន់ជនបទ, សិស្សរៀននៅសាលាឯកជនរៀនបានប្រសើរជាងនៅសាលារដ្ឋ, សិស្សសិក្សានៅថ្នាក់ទី១០ហាក់រៀនបានប្រសើរជាងសិស្សនៅថ្នាក់កាន់តែខ្ពស់។ មិនខុសពីគ្រូបង្រៀន សិស្សដែលមានគុណភាពសេវាអ៊ីនធឺណិតល្អបង្ហាញនូវប្រសិទ្ធភាពនៃការសិក្សាប្រសើរជាងសិស្សដែលជួបប្រទះនឹងបញ្ហាអ៊ីនធឺណិត។

## ៥.២. អនុសាសន៍

ជាការពិត វិបត្តិកូវីដ-១៩ហាក់បង្ហាញនូវអវត្តមានចេញពីប្រទេសកម្ពុជា បើទោះបីជាវត្តមានអ្នកឆ្លងជំងឺនេះនៅបន្តកើតមានបន្តិចបន្តួចក្តី ប៉ុន្តែវាពុំបានជំរុញដល់ដំណាក់កាលធ្ងន់ធ្ងរដូចមុននោះទេសម្រាប់វិស័យអប់រំ។ មេរៀនពីការសិក្សានេះ ក៏ដូចជាការសិក្សាជាច្រើនអំពីផលប៉ះពាល់នៃជំងឺកូវីដ-១៩មកលើវិស័យអប់រំនៅកម្ពុជា បានផ្តល់ជាមេរៀនដល់យើងផងដែរ។ ការសិក្សានេះផ្តល់ជាអនុសាសន៍មួយចំនួនដល់ក្រសួងអប់រំយុវជននិងកីឡា ក៏ដូចជាភាគីពាក់ព័ន្ធ

នានាសម្រាប់ត្រៀមខ្លួនដើម្បីពង្រឹងសេវាអប់រំ សកម្មភាពបង្រៀននិងរៀនរបស់ខ្លួនក្នុងករណីមានវិបត្តិប្រហាក់ប្រហែលនេះកើតឡើងនាពេលអនាគត ដែលមានដូចជាៈ

- *អភិវឌ្ឍន៍ឌីជីថលនីយកម្មវិស័យអប់រំៈ* ក្រៅពីផលប៉ះពាល់នៃជំងឺកូវីដ-១៩មកលើការអប់រំ វិបត្តិនេះក៏បានបង្កើតនូវឱកាសសម្រាប់កម្ពុជាផងដែរ ជាពិសេសក្នុងការធ្វើឌីជីថលនីយកម្មក្នុងវិស័យអប់រំ ដោយវិបត្តិនេះបានជំរុញការអនុវត្តផែនការឌីជីថលនីយកម្មវិស័យអប់រំនៅកម្ពុជាដើរលឿនជាងការគ្រោងទុក។ ដើម្បីត្រៀមខ្លួនសម្រាប់វិបត្តិប្រហាក់ប្រហែលគ្នានេះដែលនឹងអាចកើតឡើងនាពេលអនាគត ក៏ដូចជាពង្រឹងវិស័យអប់រំឱ្យដើរស្របនឹងបរិបទនៃបដិវត្តឧស្សាហកម្ម4.0 កម្ពុជាចាំបាច់ត្រូវជំរុញការងារឌីជីថលនីយកម្មវិស័យអប់រំដោយផ្តោតលើចំណុចមួយចំនួនខាងក្រោមៈ
    - អភិវឌ្ឍកម្មវិធីអប់រំគ្រប់កម្រិតថ្នាក់ (ថ្នាក់បឋម សាលាគរុកោសល្យ និង សាកលវិទ្យាល័យ) ដោយបង្កប់នូវធាតុបច្ចេកវិទ្យាឌីជីថលទាំងក្នុងខ្លឹមសារមេរៀន វិធីសាស្ត្របង្រៀន និង ការអនុវត្តជាក់ស្តែង។
    - ពង្រឹងសមត្ថភាពគ្រូបង្រៀនទាំងគ្រូបង្វឹកផ្នែកគរុកោសល្យ គរុនិសិស្ស-និស្សិត និងគ្រូបង្រៀនដែលចេញបម្រើការរួចហើយ នូវខ្លឹមសារបច្ចេកវិទ្យាសម្រាប់ការបង្រៀននិងរៀនឱ្យស្របតាមតម្រូវជាក់ស្តែង។
    - បំពាក់បរិក្ខារឌីជីថលសមស្របនៅតាមសាលារៀន ដោយផ្តោតការយកចិត្តទុកដាក់ឱ្យបានស្មើភាពគ្នាដោយមិនផ្តោតតែលើតំបន់ទីប្រជុំជន។

- *បញ្ហាបយន្តការរៀនតាមវិធីចម្រុះ (Blended Learning)ៈ* ក្រសួងអប់រំយុវជននិងកីឡាគួរសោកល្បងការប្រើប្រាស់វិធីបង្រៀនចម្រុះនៅតាមសាលាចំណេះទូទៅ ប៉ុន្តែត្រូវមានការពិសោធឱ្យបានច្បាស់លាស់ថាត្រូវអនុវត្តការរៀនក្នុងថ្នាក់ប៉ុន្មានភាគរយ និង ការរៀនពីចម្ងាយប៉ុន្មានភាគរយ ឬមួយ គួរចាប់ផ្តើមពីកម្រិតថ្នាក់ជាក់លាក់ណាមួយ។ ការអនុវត្តដោយគ្មានមូលដ្ឋានច្បាស់លាស់ អាចនឹងប៉ះពាល់ដល់គុណភាពនៃការអប់រំ និង អាចផ្តល់ផលអាក្រក់ដល់សង្គមនិងសេដ្ឋកិច្ចជាតិផងដែរ។

- *ផលិតឯកសារសិក្សាឱ្យស្របស្ថានភាពជាក់ស្តែងៈ* ឯកសារសិក្សាដែលអាចប្រើប្រាស់បានតាមស្ថានភាពជាក់ស្តែងនៃបញ្ហាគឺជាធនធានឯកសារដែលមានប្រយោជន៍បំផុត។ ឆ្លងកាត់បទពិសោធន៍កូវីដ-១៩ ការបង្រៀននិងរៀនតាមវីដេអូអនឡាញ ហាក់មិនអាចអនុវត្តទៅបានល្អប្រសើរនោះទេ ប៉ុន្តែ បន្សំនូវមធ្យោបាយបង្រៀនដែលបានលើកឡើងក្នុងចំណុច១.១ អាចបំពេញនូវកង្វះខាតនេះបាន។ ក្រសួងអប់រំ យុវជន និងកីឡា គួរផលិតឯកសារសិក្សាដែលអាចប្រើប្រាស់បានច្រើនមធ្យោបាយ ជាពិសេសផ្តោតការយកចិត្តទុកដាក់ឱ្យបានខ្ពស់ទៅលើឯកសារសិក្សាដែលសមស្របសម្រាប់ស្ថានភាពគ្រូនិងសិស្សនៅតាមទីជនបទ និង តំបន់មានការអភិវឌ្ឍទាប។

- *ពង្រឹងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលៈ* បញ្ហាប្រឈមទាក់ទងនឹងហេដ្ឋារចនាសម្ព័ន្ធឌីជីថលបានចូលរួមយ៉ាងខ្លាំងក្នុងការអប់រំដោយប្រើប្រព័ន្ធបច្ចេកវិទ្យា។ ក្នុងន័យនេះ រាជរដ្ឋាភិបាលកម្ពុជាត្រូវជំរុញបន្ថែមទៀតទៅលើវិស័យឯកជនក្នុងការពង្រឹងសេវាអ៊ីនធឺណិតនៅតាមតំបន់មិនសូវរីកចម្រើន តំបន់ភ្នំនិងខ្ពង់រាប និង តំបន់ទីជនបទនានា ដោយមិនគិតតែបរិមាណទេ ត្រូវគិតដល់គុណភាពផងដែរ។

# ឯកសារយោង


Chea, P., Bo, C., & Minami, R. (2022). *Cambodian Secondary School Teachers' Readiness for Online Teaching During the Covid-19 Pandemic* (Issue 134).

Chea, P., Chhim, R., Ob, B., & Hak, M. (2021). *Blended Learning: Practices, Challenges and Possibilities in Cambodia Secondary Resource Schools* (pp. 1–9).

Chet, C., & Sok, S. (2020). Dangers and opportunities related to COVID-19 pandemic for Higher Education Institutions in Cambodia. *Cambodia Journal of Basic and Applied Research (CJBAR)*, *2*(1), 20–26.

Chhy, S. (2020). THE IMPACT OF THE COVID-19 PANDEMIC ON EDUCATION IN CAMBODIA. *British Journal of Education*, *9*(1), 13–19. https://doi.org/10.1080/23311932.2023.2214432

Dy, K., Phann, S., & Meng, H. (2020). Cambodia's education responses to COVID-19.pdf. *SEAMEO Journal*, *2*(Special Issue), 1–10.

Ean, S., Thy, S., & Ly, T. (2023). *MoEYS ' s Intervention During Covid-19 School Closure : Strategies and Measures , Challenges and Future Readiness*. *Cambodian Journal of Humanities and Social Sciences*, *2*(1), 66–75.

Heng, K., & Sol, K. (2021). Online learning during COVID-19: Key challenges and suggestions to enhance effectiveness. *Cambodian Education Research Journal*, *1*(1), 1–20.

MoEYS. (2020). *Cambodia Education Response Plan to COVID 19 Pandemic* (Issue July).

MoEYS, & ESWG. (2021). *Cambodia COVID-19: Joint Education Needs Assessment* (Issue March).

MoEYS, & UNICEF. (2022). *Learning Loss in the Covid-19 Pandemic Era: Evidence from the 2016-2021 Grade Six National Learning Assessment in Cambodia* (Issue April).

Open Development Cambodia. (2021). *The ICT-Enabled Distance Learning: Response to COVID-19 In Cambodia* (Issue JULY).

Thy, S., Ly, T., & Ean, S. (2023). *Cambodian Upper Secondary School Education amid COVID-19 Pandemic : Challenges and Opportunities* (CDRI Working Paper, Issue 137).

UNICEF, UNDP, Prospera, & SMERU. (2021). Analysis of the Social and Economic Impacts of COVID-19 on Households and Strategic Policy Recommendations for Indonesia. *Unicef*, 1–90.

United Nations. (2020). Policy Brief: Education during COVID-19 and Beyond. In *United Nations* (Issue 26). https://doi.org/10.24215/18509959.26.e12



**លី តុង**

**កន្លែងការងារ៖**
- រាជបណ្ឌិត្យសភាកម្ពុជា

**ការអប់រំ៖**
- Mathematics Education
- Educational Administration
- Mathematics

**ចំណូលចិត្តស្រាវជ្រាវ៖**
- ចំណូលចិត្តសិក្សារបស់សិស្ស
- វិទ្យាសាស្ត្រទិន្នន័យ
-



**ជី សាវីន**

**កន្លែងការងារ៖**
- វិទ្យាស្ថានជាតិអប់រំ

**ការអប់រំ៖**
- បេក្ខជនបណ្ឌិតជំនាញរូបវិទ្យានិងអប់រំ សាកលវិទ្យាល័យ Aichi ប្រទេសជប៉ុន
- អនុបណ្ឌិតជំនាញរូបវិទ្យានិងអប់រំ សាកលវិទ្យាល័យហ៊ីរ៉ូហ្ស៊ីម៉ា, ជប៉ុន

**ចំណូលចិត្តស្រាវជ្រាវ៖**
- បច្ចេកវិទ្យាក្នុងការបង្រៀននិងការអប់រំ
- ការតាមដាននិងវាយតម្លៃការសិក្សា
- ការអប់រំស្ទែម ( STEM Education )



**អៀន សុគន្ធី**

**កន្លែងការ៖**
- វិទ្យាល័យព្រែកថ្មី ខេត្តកណ្ដាល

**ការអប់រំ៖**
- បរិញ្ញាបត្រជំនាញជីវវិទ្យា សាកលវិទ្យាល័យភូមិន្ទភ្នំពេញ

**ចំណូលចិត្តស្រាវជ្រាវ៖**
- ឥរិយាបថសិក្សារបស់សិស្ស

កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Cambodian Journal of Humanities and Social Sciences

Website: https://cjhss-journal.com/

# មូលហេតុនៃការបែកបាក់គ្រួសារនៅកម្ពុជា៖ ការសិក្សានៅក្នុងសង្កាត់ស្ទឹងមានជ័យរាជធានីភ្នំពេញ

# Major Causes Divorce among Cambodian People's Families: A Study at Sangkat Steung Meanchey, Phnom Penh

**ឈុន ផាវ៉េង[១], ប៉ាន់ វុត្ថា[២], ហ៊ឹម ញាណារិទ្ធ[៣], ក្ដាន់ ធុល[៤]**

[១] វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ phaveng@gmail.com

[២] វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ pannvutha1973@yahoo.com

[៣] វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ narith1971@gmail.com

[៤] វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម នៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ kdann_thoul@yahoo.com

បានទទួល៖ ២៦កញ្ញា ២០២៣; ទទួលបោះពុម្ព៖ ២៧វិច្ឆិកា ២០២៣; បោះពុម្ព៖ ៣១ធ្នូ ២០២៣

**ទំនាក់ទំនង៖** phaveng@gmail.com

**អាគតដ្ឋាន៖** ឈុន ផាវ៉េង, ប៉ាន់ វុត្ថា, ហ៊ឹម ញាណារិទ្ធ និង ក្ដាន់ ធុល. (២០២៣). មូលហេតុនៃការបែកបាក់គ្រួសារនៅកម្ពុជា៖ ការសិក្សានៅក្នុងសង្កាត់ស្ទឹងមានជ័យរាជធានីភ្នំពេញ. *កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម*, *២*(២), ៤២-៥៥.

## សង្ខិត្តន័យ

ការបែកបាក់គ្រួសារឬការលែងលះក្នុងសង្គមគ្រួសារបានក្លាយជាបញ្ហាប្រឈមមួយមិនត្រឹមតែសម្រាប់បុគ្គលខ្លួនឯងផ្ទាល់នោះទេ ប៉ុន្តែវាក៏បាននាំមកនូវផលវិបាកដល់គ្រួសារ សាច់ញាតិ និងសង្គមកម្ពុជាផងដែរ។ ការសិក្សាអំពីមូលហេតុនៃការបែកបាក់គ្រួសារនៅក្នុងសង្គមកម្ពុជាមួយនេះ ធ្វើឡើងនៅក្នុងសង្កាត់ស្ទឹងមានជ័យនៃរាជធានីភ្នំពេញ។ ដំណើរការស្រាវជ្រាវអនុវត្តតាមវិធីសាស្ត្រស្រាវជ្រាវបែបគុណវិស័យ ដោយប្រើវិធីសម្ភាសស៊ីជម្រៅជាមួយក្រុមគោល

ដៅស្រាវជ្រាវចំនួន២៥នាក់ ដែលក្នុងនោះមានស្ត្រីចំនួន១៥នាក់។ លទ្ធផលស្រាវជ្រាវបង្ហាញថា មូលហេតុដែលឈានទៅដល់ការលែងលះឬបែកបាក់ក្នុងសង្គមកម្ពុជាមានដូចជា ហិង្សាសេដ្ឋកិច្ចគ្រួសារ, ការប្រចណ្ឌ, ការជ្រៀតជ្រែកនៃញាតិពន្ធ, បញ្ហាហិង្សាផ្លូវភេទ, អំពើហិង្សាផ្លូវកាយ និង កង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារ។ ក្នុងទិដ្ឋភាពជាក់ស្តែង មានក្រុមគ្រួសារមួយចំនួនបានបែកបាក់គ្នាបណ្តាលមកមូលហេតុពីរឬច្រើនក្នុងចំណោមមូលហេតុទាំងនេះ។ លទ្ធផលក៏បានបង្ហាញថា មានកត្តាមួយចំនួនដែលជំរុញឱ្យមូលហេតុទាំងនេះកាន់តែក្តៅនិងឈានទៅដល់ការលែងលះ ដែលកត្តាទាំងនោះមានដូចជា កត្តាចំណេះដឹង ការងារ កត្តាទំហំប្រាក់ចំណូលជាដើម។ ដើម្បីចូលរួមជាទស្សនទានសម្រាប់វិធីសាស្ត្របង្ការឬជៀសវាងនូវបញ្ហាបែកបាក់គ្រួសារនេះ ការសិក្សាបានផ្តល់អនុសាសន៍មួយចំនួនដូចជា ស្វែងយល់ពីគ្នាឱ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តរៀបការ, ចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានត្រឹមត្រូវ, ព្យាយាមរម្ងាប់អារម្មណ៍ពេលមានបញ្ហាគ្រួសារជាដើម។

**ពាក្យគន្លឹះ:** មូលហេតុ, ការបែកបាក់គ្រួសារ, សង្គមកម្ពុជា, សង្កាត់ស្ទឹងមានជ័យ

**ABSTRACT**

Family separation or divorce has become a challenge not only for the individual but also for the family, relatives and society in Cambodia. This study focused on the causes of family separation in Cambodian which took place in Sangkat Stung Meanchey, Phnom Penh. The research process followed a qualitative method where in-depth interviews with 25 target groups, including 15 women were conducted. The findings showed that the major causes of divorce or separation among families in the study context were economic violence, jealousy, relative intrusion, sexual violence, physical violence, and a lack of discussion methods. In fact, some families split up for a combination of two or more reasons. The results also showed that there were other factors such as level of knowledge, employment status, income and so on were directly or indirectly stimulated the causes mentioned above. To prevent family breakdown, the study recommended that both parties should understand each other well before getting married, get lawful marriage registration, and try to calm down when finding the resolution to the family's issues.

**KEYWORDS:** cause, family breakup, Cambodian society, Sangkat Steung Meanchey

# ១. សេចក្តីផ្តើម

## ១.១. ទិដ្ឋភាពទូទៅ

អាពាហ៍ពិពាហ៍គឺជាចំណងរវាងភ្ជាប់និស្ស័យរវាងមនុស្សពីរនាក់តាមប្រពៃណីឬតាមផ្លូវច្បាប់ និងដែលបានស្ម័គ្រចិត្តរួមរស់ជាមួយគ្នា បង្កើតជាគ្រួសារ និង បន្តខ្សែស្រឡាយមនុស្សជាតិ។ នៅក្នុងការរស់នៅ ចំណងអាពាហ៍ពិពាហ៍តែងមានបង្កប់នូវគោលបំណងផ្សេងៗគ្នា អាស្រ័យទៅតាមការយល់ឃើញរបស់ក្រុមមនុស្សនៅក្នុងសង្គម ដែលគោលបំណងទាំងនោះមានដូចជា ដើម្បីបំពេញសេចក្តីរីករាយត្រេកត្រអាលនៃកាមតណ្ហាបែបសភាវធម្មជាតិ, ការបន្តពូជពង្សវង្សត្រកូល, ការបន្តដំណើរជីវិតរស់នៅរួមសុខរួមទុក្ខជាមួយគ្នាប្រកបដោយកិត្តិយស ភាពថ្លៃថ្នូរ និង សណ្តាប់ធ្នាប់ជាដើម។ ក៏ប៉ុន្តែ ដោយថាហេតុ មានប្តីប្រពន្ធជាច្រើនបានប្រឈមមុខនឹងទំនាស់វិបត្តិគ្រួសារ រស់នៅមិនចុះសម្រុងនឹងគ្នា កើតមានអំពើហិង្សា ឬ ប្រព្រឹត្តសកម្មភាពមិនគប្បីនិងឈានរហូតបែកបាក់គ្រួសារក៏មាន។

ទូទៅ បុរសនិងស្ត្រីតែងប្រាថ្នាកសាងជីវិតប្តីប្រពន្ធតាមរយៈចំណងអាពាហ៍ពិពាហ៍តាមប្រពៃណីឬតាមផ្លូវច្បាប់ ក៏ប៉ុន្តែ គេក៏សង្កេតឃើញមានគូស្វាមីភរិយាខ្លះបានសម្រេចចិត្តរស់នៅជាមួយគ្នាដោយពុំមានចំណងអាពាហ៍ពិពាហ៍ស្របច្បាប់។ សម្រាប់សង្គមខ្មែរ យោងតាមនីតិវិធីច្បាប់ជាធរមាន បានបែងចែកប្តីប្រពន្ធជាពីរប្រភេទគឺ អនីតិសង្វាសជនឬប្តីប្រពន្ធឥតខាន់ស្លា និង សហព័ទ្ធឬប្តីប្រពន្ធមានខាន់ស្លា។ ចំពោះអនីតិសង្វាសជន បើយោងតាមក្រមព្រហ្មទណ្ឌនិងច្បាប់ឯកពន្ធភាព (រដ្ឋសភា, ២០០៦) គឺជាជនដែលរស់នៅរួមរស់ជាមួយគ្នាជាគូស្នេហ៍ឬប្តីប្រពន្ធដោយមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍(អេតាស៊ីវិល) ទោះបីពួកគេបានរៀបចំពិធីអាពាហ៍ពិពាហ៍អធិកអធមយ៉ាងណាក៏ដោយ។ ចំណែកសហព័ទ្ធ យោងតាមច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ១៩៨៩ (រដ្ឋសភា, ១៩៨៩) និង ក្រមរដ្ឋប្បវេណី២០០៧ (រដ្ឋសភា, ២០០៧) គឺប្តីប្រពន្ធដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ទោះបីគេបានឬមិនបានរៀបចំពិធីអាពាហ៍ពិពាហ៍អធិកអធម្មក៏ដោយ។ ប្រជាពលរដ្ឋខ្មែរទាំងពីរភេទដែលមានចំណងអាពាហ៍ពិពាហ៍ ត្រូវគោរពគោលការណ៍ឯកពន្ធភាពដោយស្ម័គ្រចិត្ត ប្តីមួយប្រពន្ធមួយ ដោយមានចុះសំបុត្រអាពាហ៍ពិពាហ៍ ចំពោះមុខមន្ត្រីអត្រានុកូលដ្ឋាន ស្របតាមលក្ខខណ្ឌដែលមានចែងក្នុងច្បាប់ស្តីពីអាពាហ៍ពិពាហ៍និងគ្រួសារ (រដ្ឋសភា, ២០១១)។

ទិដ្ឋភាពខាងលើនេះ មានភាពខុសគ្នាចំពោះបុរសប្រសិនបើយើងក្រឡេកមើលទៅលើស្ថានភាពសង្គមកម្ពុជាកាលពីអំឡុងទសវត្សរ៍ឆ្នាំ១៩៦៧ ដោយតាមក្រមរដ្ឋប្បវេណីឆ្នាំ១៩៦៧ បានអនុញ្ញាតឱ្យ ស្ត្រីយកប្តីបានតែមួយនាក់ ចំណែកបុរសអាចយកប្រពន្ធបានច្រើននាក់។ ប្រពន្ធទាំងឡាយត្រូវទទួលស្តាប់ឱវាទប្តី ត្រូវឱនលំទោន ស្លូតត្រង់នឹងប្តី ចំណែកប្តីត្រូវទំនុកបម្រុងប្រពន្ធទាំងឡាយឱ្យប្រាក់កាសចាយវាយតាមសមគួរដល់មុខរបរនិងធនធានដែលខ្លួនមាន។ ស្ត្រីដែលទន់ខ្សោយ ខំតស៊ូខាំមាត់សង្កត់ចិត្ត ទ្រាំទ្រការលំបាកសព្វបែបយ៉ាង នេះប្រសិនបើគេបានស្វាមីដែលមិនយកចិត្តទុកដាក់លើភរិយា ដែលការរស់នៅបែបនេះផ្ទុយពីទស្សនៈដ៏ពេញនិយមរបស់ខ្មែរមួយគឺ "ស៊ូលំបាកផ្លូវកាយ កុំឱ្យតែលំបាកផ្លូវចិត្ត"។ ដោយសារតែកត្តាប្រពៃណី ស្ត្រីខ្មែរខ្លាចណាស់ការរិះគន់ពីញាតិជិតឆ្ងាយ ខ្លាចពាក្យថាមេម៉ាយ ព្រោះមេម៉ាយចាយមាត់ញាតិ ជាពិសេសមេម៉ាយប្តីលែង និង មេម៉ាយលែងប្តី។ ក៏ប៉ុន្តែ ការប្រកាន់ទស្សនៈបែបនេះបានសាបរលាបបន្តិចម្តងៗសម្រាប់និន្នាការបច្ចុប្បន្ន ហើយគេសង្កេតឃើញថា មានស្ត្រីខ្មែរជាច្រើនបានជ្រើសរើសយកការបាក់បែកគ្រួសារជាដំណោះស្រាយ ប្រសិនបើស្ថានភាពនៃការរស់នៅជាមួយគ្នាកើតមានបញ្ហាជាប្រចាំ ឬ ត្រូវរងទុក្ខគ្រប់បែបគ្រប់យ៉ាងទាំងសម្រាប់ខ្លួនឯងឬកូនៗ។

ការបែកបាក់គ្រួសារអាចជាដោះស្រាយនូវទុកសោកឈឺចាប់ទាំងឡាយដែលកើតមាននៃអតីតគូស្នេហ៍ទាំងឡាយ ប៉ុន្តែវាក៏បានបង្កនូវផលវិបាកដល់សាម៉ីខ្លួន គ្រួសារ និង សង្គមជាតិជាច្រើនដែរ។ ការបែកបាក់គ្រួសារអាចបង្កើតនូវបញ្ហាអវិជ្ជមាននៅក្នុងសង្គម ជាពិសេសពាក់ព័ន្ធនិងវប្បធម៌ សេដ្ឋកិច្ច និង ការអភិវឌ្ឍន៍ (Judy, 2021)។ នៅកម្ពុជាការបែកបាក់គ្រួសារមានចំនួនច្រើនគួរឱ្យកត់សំគាល់ ដោយនៅក្នុងឆ្នាំ២០១៣ នៅរាជធានីភ្នំពេញមានប្តីប្រពន្ធជាង ១២០០គូ បានលែងលះគ្នា ដោយក្នុងនោះមាន ៧០% ស្ត្រីជាអ្នកសុំលែងលះ (ប៉ែន, ២០១៤)។ ការបែកបាក់គ្រួសារនេះបង្កដោយមូលហេតុមួយចំនួនដូចជា ការរស់នៅមិនចុះសម្រុងគ្នា អំពើហិង្សាក្នុងគ្រួសារ ការផិតក្បត់ និង ការគ្មានទំនួលខុសត្រូវក្នុងគ្រួសារ ជាដើម (រឹម, ២០២០)។ ទិន្នន័យមួយចំនួនបង្ហាញថា បណ្តឹងលែងលះតាមផ្លូវតុលាការនៅកម្ពុជាមានអត្រាខ្ពស់ បើប្រៀបនឹងប្រទេសនានា ហើយបើធៀបនឹងប្រទេសជប៉ុនការលែងលះតាមបណ្តឹងមានប្រហែល

១% ប៉ុណ្ណោះ (Akanishi, 2016)។ នៅក្នុងសង្គមខ្មែរពីអតីតកាល ការបែកបាក់គ្រួសារមិនសូវកើតមានឡើយ ដែលនេះអាចដោយសារកត្តាសង្គមធម៌ វប្បធម៌ គំនាបប្រពៃណី និង កត្តាផ្សេងៗទៀត។

### ១.២. ក្របខណ្ឌគំនិតស្រាវជ្រាវ

ការប្រើប្រាស់ពាក្យ "បាក់បែកគ្រួសារ" នៅក្នុងអត្ថបទនេះសំដៅការចែកផ្លូវគ្នារវាងប្តីប្រពន្ធដែលមិនមានសំបុត្រអាពាហ៍ពិពាហ៍(ភាសាច្បាប់ហៅថា ប្តីប្រពន្ធអនីតិសង្វាសឬប្តីប្រពន្ធគ្មានសំបុត្រអាពាហ៍ពិពាហ៍) និងការចែកផ្លូវគ្នារវាងសហព័ទ្ធ(ប្តីប្រពន្ធនីតិសង្វាសឬប្តីប្រពន្ធមានសំបុត្រអាពាហ៍ពិពាហ៍)។ ចំពោះសហព័ទ្ធ ពេលបែកបាក់គ្រួសារចែកផ្លូវគ្នា ច្បាប់កំណត់ប្រើពាក្យថា "ការលែងលះ" ដែលសំដៅដល់ការរំលាយចោលកិច្ចសន្យាប្តីប្រពន្ធនិងញាតិពន្ធរវាងភាគីទាំងពីរ។ ការលែងលះត្រូវបានចាត់ទុកថាជាការផ្តាច់ចំណងអាពាហ៍ពិពាហ៍រវាងសហព័ទ្ធនីតិសង្វាស ដោយសេចក្តីសម្រេចឬដីការបស់តុលាការ ការសុំដាច់មគ្គសង្វាស នឹងត្រូវបានតុលាការសម្រេចតាមនីតិវិធី។ ចំណែកអសហព័ទ្ធ (អនីតិសង្វាសជនឬប្តីប្រពន្ធមិនពេញច្បាប់ ឬ អត់សំបុត្រអាពាហ៍ពិពាហ៍) ការបែកបាក់គ្រួសារ សំដៅដល់ការចែកផ្លូវគ្នា លែងទទួលយកគ្នាជាប្តីឬប្រពន្ធ ដោយគ្រាន់តែមានសាក្សីដឹងឮប៉ុណ្ណោះ (BTV, ២០១៧)។ ការបែកបាក់គ្រួសារនៅទីនេះមិនមែនសំដៅដល់ករណីក្រុមគ្រួសារដែលមានភាគីម្ខាងណាម្នាក់បាត់បង់ជីវិតនោះទេ។

### ១.៣. វត្ថុបំណងនិងសំណួរស្រាវជ្រាវ

ការស្រាវជ្រាវនេះមានវត្ថុបំណងសិក្សាទៅលើបុព្វហេតុចម្បងនិងបន្ទាប់បន្សំដែលបណ្តាលឱ្យមានការបែកបាក់ (លែងលះ) គ្រួសារក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា។ ជាមួយនឹងវត្ថុបំណងនេះ ការសិក្សានេះព្យាយាមឆ្លើយទៅនឹងសំណួរខាងក្រោម៖

តើមូលហេតុអ្វីខ្លះដែលបណ្តាលឱ្យមានការបែកបាក់គ្រួសារក្នុងចំណោមប្រជាពលរដ្ឋកម្ពុជា?

## ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១. សំណាកស្រាវជ្រាវនិងទិន្នន័យ

ការសិក្សានេះប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវគុណភាពវិស័យដែលធ្វើឡើងតាមរយៈការសម្ភាសស៊ីជម្រៅជាមួយក្រុមគោលដៅស្រាវជ្រាវដែលបានស្ម័គ្រចិត្តចូលរួមក្នុងការសិក្សា និងផ្តល់ទិន្នន័យសម្រាប់វត្ថុបំណងនៃការស្រាវជ្រាវមួយនេះ។ ការសិក្សានេះធ្វើឡើងដោយមានការចូលរួមពីក្រុមគោលដៅស្រាវជ្រាវចំនួន២៥នាក់ ដែលមានអាយុចន្លោះពី ២៦ ដល់ ៦៥ឆ្នាំ និងមានការបែកបាក់គ្រួសារ។ ការជ្រើសរើសសំណាកស្រាវជ្រាវ ធ្វើឡើងដោយប្រើប្រាស់វិធីជ្រើសរើសសំណាកងាយៗ ហើយអ្នកចូលរួមទាំងអស់ក៏បានស្ម័គ្រចិត្តចូលរួមដោយពុំមានការបង្ខិតបង្ខំអ្វីឡើយ។ ការសម្ភាសប្រើប្រាស់រយៈពេលជាមធ្យមប្រហែល២៦នាទីនិងត្រូវបានថតទុកជាសារសម្លេង ក្នុងនោះ មានស្ត្រី៣នាក់ និងប្រុស៣នាក់បានស្ម័គ្រចិត្តផ្តល់ការសម្ភាសរហូតដល់៦០នាទី។ ការសម្ភាសធ្វើឡើងនៅគេហដ្ឋានផ្ទាល់របស់ក្រុមគោលដៅស្រាវជ្រាវ ហើយការសន្ទនានីមួយៗដំណើរការដោយប្រើសំណួរគន្លឹះមួយចំនួនទាក់ទងនឹងចំណោទបញ្ហាស្រាវជ្រាវ។

### ២.២. ការវិភាគទិន្នន័យ

ទិន្នន័យដែលទទួលបានពីការសម្ភាសនីមួយៗត្រូវបានវិភាគដោយអ្នកស្រាវជ្រាវផ្ទាល់និងប្រើប្រាស់វិធីវិភាគទិន្នន័យគុណភាពបែបកំណត់ទីសេចក្តី (content analysis) និងបង្កើតជាកន្សោមពាក្យគន្លឹះតំណាងឱ្យទីសេចក្តីដែលបានកំណត់។

## ៣. លទ្ធផលស្រាវជ្រាវ

### ៣.១. ព័ត៌មានទូទៅអំពីក្រុមគោលស្រាវជ្រាវ

ការសិក្សានេះមានការចូលរួមពីក្រុមគោលដៅដែលបានបែកបាក់គ្រួសារចំនួន25នាក់ ក្នុងនោះ មានស្ត្រីចំនួន15នាក់ និងបុរសចំនួន10នាក់។ ក្នុងនោះ ក្រុមគោលដៅមួយចំនួនធ្លាប់បានរស់នៅជាមួយគ្នាក្នុងនាមប្តីប្រពន្ធប៉ុន្តែពុំបានរៀបអាពាហ៍តាមផ្លូវច្បាប់នោះទេ និងរហូតមានគត៌ បង្កើតបានកូនដោយពុំមានខាន់ស្លា។ ក្នុងចំណោមក្រុមគោលដៅស្រាវជ្រាវទាំងនេះ អ្នកដែលបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវមានចំនួន11នាក់ ស្មើ 44.0% ចំណែក14នាក់ទៀត ស្មើ 56.0% ធ្លាប់បានរស់នៅជាមួយគ្នាដោយពុំមានចុះសំបុត្រអាពាហ៍ពិពាហ៍នោះទេ។

រូបភាពទី1

*អត្រាកូនមានខាន់ស្លានិងឥតខាន់ស្លាក្នុងចំណោមក្រុមគ្រួសារដែលមានការបែកបាក់គ្នា*




### ៣.២. មូលហេតុនៃការបែកបាក់គ្រួសារ

ផ្នែកនេះបង្ហាញលទ្ធផលស្រាវជ្រាវទាក់ទងនឹងមូលហេតុនៃការបែកបាក់គ្រួសារក្នុងចំណោមក្រុមគោលដៅដែលបានចូលរួមក្នុងការសិក្សានេះ។ លទ្ធផលបានបង្ហាញថា មានមូលហេតុចំនួនប្រាំមួយដែលបានជំរុញដល់ការបែកបាក់គ្រួសារ ឬឈានដល់ការលែងលះគ្នា។

រូបភាពទី2

*មូលហេតុនៃការបែកបាក់គ្រួសារក្នុងចំណោមគ្រួសារដែលចូលរួមក្នុងការសិក្សា*




លទ្ធផលបានបង្ហាញថា កត្តាហិង្សាសេដ្ឋកិច្ចគឺជាមូលហេតុចម្បងជាងគេ ដែលមានគ្រួសាររហូតដល់ 28.0% បានបែកបាក់គ្រួសារដោយសារកត្តាមួយនេះ។ ការជ្រៀតជ្រែកពីញាតិពន្ធ និង ការប្រេចណ្ឌ គឺជាមូលហេតុធំបន្ទាប់ដែលមានគ្រួសាររហូតដល់ 20.0% ដូចគ្នាដែលរងគ្រោះដោយសារបញ្ហានេះ។ បញ្ហាហិង្សាផ្លូវភេទ បញ្ហាអំពើហិង្សាក្នុងគ្រួសារ និង កត្តាកង្វះខាតនូវវិធីសាស្ត្រក្នុងការពិភាក្សាបញ្ហាគ្រួសារ គឺជាកត្តាបីផ្សេងទៀតដែលបានចូលរួមធ្វើឱ្យក្រុមគ្រួសាររស់នៅសង្កាត់ស្ទឹងមានជ័យឈានទៅដល់ការបែកបាក់ ហើយកត្តាទាំងបីនេះមានភាគរយ 16.0%, 8.0% និង 8.0% រៀងគ្នា។ ទោះជាយ៉ាងណា លទ្ធផលស្រាវជ្រាវក៏បានបញ្ជាក់បន្ថែមថា គ្រួសារមួយចំនួនបានបែកបាក់ដោយមូលហេតុចម្បងមួយឬផ្សំគ្នារវាងបញ្ហាពីរឬច្រើនក្នុងចំណោមបញ្ហាទាំងប្រាំមួយនេះ។ ម្យ៉ាងទៀត មូលហេតុមួយចំនួនបានក្លាយជាដើមចមដំបូងនៃមូលហេតុមួយទៀត និងចុងក្រោយឈានទៅដល់ការបែកបាក់គ្រួសារ។

## មូលហេតុទី១៖ ហិង្សាសេដ្ឋកិច្ចគ្រួសារ

អ្នកនិពន្ធប្រើប្រាស់បច្ចេកសព្ទ "ហិង្សាសេដ្ឋកិច្ចគ្រួសារ" នៅក្នុងការសិក្សាពីព្រោះតែវាគ្របដណ្តប់លើសពីកង្វះខាតថវិកាសម្រាប់ផ្គត់ផ្គង់គ្រួសារ បង់ថ្លៃឈ្នួលផ្ទះ បង់ការប្រាក់ធនាគារជាដើម។ បញ្ហានេះកើតឡើងក្នុងទិដ្ឋភាពផ្សេងទៀតទាក់ទងនឹងហិរញ្ញវត្ថុគ្រួសារដូចជា ការរារាំងមិនឱ្យដៃគូទៅធ្វើការងាររកប្រាក់កម្រៃមកផ្គត់ផ្គង់គ្រួសារ និងការមិនផ្តល់ថវិកាជាប្រចាំសម្រាប់ចំណាយលើជីវភាពគ្រួសារជាដើម។ ស្វាមីដែលខិតខំធ្វើការនឿយហត់នៅខាងក្រៅផ្ទះ បានមើលងាយមើលថោកចំពោះភរិយារបស់ខ្លួនដែលគ្មានការងារធ្វើ ឬធ្វើតែកិច្ចការផ្ទះ ដោយគាត់ (ស្វាមី) យល់ថាប្រពន្ធនៅផ្ទះដេកស៊ីដោយកម្លាំងគាត់។ សង្គមកម្ពុជា ផ្តល់តម្លៃខ្ពស់ដល់ភរិយាក្នុងការចាត់ចែងការងារផ្ទះ ដោយឡែកស្វាមីប្រឹងប្រែងរកប្រាក់កាសនិងប្រគល់ជូនភរិយាក្នុងការចាត់ចែងការចាយវាយក្នុងគ្រួសារ។ បញ្ហាហិង្សាសេដ្ឋកិច្ចគ្រួសារនេះ ផ្សារភ្ជាប់ទៅនឹងសំនួនខ្មែរដ៏ពេញនិយមមួយដែលបានលើកឡើងថា "ទុក្ខស្រីប្តីកាន់លុយ"។

> *(...) ខ្ញុំមានអារម្មណ៍ថា ប្ដីខ្លួនចាត់ទុកខ្លួនដូចសំរាម ជាមនុស្សឥតមានការ។ ក្នុងគ្រាដំបូងគាត់(អតីតប្ដី)ដែលធ្វើការក្រៅផ្ទះរាល់ពេល បើកលុយបាន តែងប្រគល់ឱ្យប្រពន្ធដើម្បីយកទៅចាត់ចែងក្នុងការចំណាយក្នុងគ្រួសារ ប៉ុន្តែក្រោយមកគាត់ឈប់ប្រគល់ឱ្យសូម្បីមួយរយរៀល ផ្ទុយទៅវិញគាត់បែរជាយកទៅចំណាយចាយវាយ ស៊ីផឹកជាមួយពួកម៉ាក បនភឿន ញាតិមិត្ត និងចំណាយលើកម្មវិធីបុណ្យផ្សេង ពិធីមង្គលការ ខាងគាត់ គ្មានលោះពេលណាឡើយ។*
>
> *(...) ហើយការលំបាកជាងនេះទៅទៀត គឺ ទុក្ខស្រីប្ដីកាន់លុយឬទុក្ខស្រីប្ដីស្រីគ្មានលុយ។ មានគ្រួសារ(ប្ដីប្រពន្ធ)ដូចអត់គ្រួសារ គាត់មិនបានគិតគូរដល់គ្រួសារប្ដីប្រពន្ធទេ គិតតែចាយវាយខ្លួនឯង និងកម្មវិធីផ្សេងៗនៃសាច់ញាតិរបស់គាត់ប៉ុណ្ណោះ។*

## មូលហេតុទី២៖ ការប្រចណ្ឌ

ការប្រចណ្ឌគឺជាចំណុចដែលបណ្ដាលឱ្យមានប្រតិកម្មធំធេងបំផុតដែលឈានទៅរកការលែងលះក្នុងចំណោមគូជីវិតជាច្រើន ពីព្រោះការស៊ូទ្រាំរស់នៅក្នុងសភាពលំបាកផ្លូវចិត្តគ្មានន័យអ្វីឡើយ។ ការប្រចណ្ឌគឺជាការដែលមិនឱ្យតម្លៃលើដៃគូស្នេហាដោយភ័យខ្លាចដៃគូក្បត់ផិតទៅមានក្រៅ ដែលបញ្ហានេះបានធ្វើឱ្យដៃគូម្ខាងទៀតតែងតែរងនូវសម្ពាធផ្លូវចិត្ត ពិបាកទ្រាំក្នុងការទប់ទល់នឹងកំហឹង ឬការព្រួយបារម្ភរបស់ខ្លួន។ ការប្រចណ្ឌនេះបានក្លាយទៅជាមូលហេតុចម្បងទី២ ដែលចូលរួមដល់ការបែកបាក់គ្រួសារ។

> *(...) ពេលណាតែងខ្លួនចេញដំណើរទៅក្រៅផ្ទះ និងចូលមកវិញគាត់តែង ប្រើពាក្យសម្ដីណែនាំ និងដៀមដាម ឌឺដងផ្លែផ្កាដាក់របៀបមើលងាយថាយើងជាស្រីចិត្តងាយ គួរឱ្យឈឺចាប់បំផុត...។*
>
> *(...) នៅពេលប្ដីទៅក្រៅផ្ទះម្ដងៗ មិនថាចេញទៅធ្វើការឬទៅកម្មវិធីណាមួយ ខ្ញុំតែងតែបារម្ភខ្លាចគាត់មានស្រី ពេលខ្លះខំទប់ចិត្ត ទប់សម្ដីមិនបង្ហាញការឈឺចាប់ដែរតែទប់មិនជាប់ ជារឿយតែងបង្កឱ្យមានជម្លោះតានតឹងកើតឡើង...។*
>
> *(...) ពេលរៀបការដំបូង ចេះយកចិត្តគ្នាដោយប្រើកាយវិកានិងពាក្យសម្ដីពិរោះពិសា រស់នៅសប្បាយចិត្ត តែក្រោយមកពាក្យសម្ដីល្អទាំងនោះបាត់បង់ទៅណាអស់ ការរស់នៅជាមួយគ្នាកាន់តែតានតឹងចិត្ត មិនទុកចិត្តគ្នា ប្រកបដោយភ្លើងប្រចណ្ឌខុសទំនង...។*
>
> *(... ) អរគុណចំពោះសេចក្ដីស្រឡាញ់របស់ប្ដី ប៉ុន្តែការប្រចណ្ឌរបស់ប្ដី ស្មើនឹងការមិនទុកចិត្តប្រពន្ធ ដែលចាត់ទុកជាការមើលងាយយ៉ាងធ្ងន់ធ្ងរចំពោះសេចក្ដីស្មោះត្រង់ទាំងកាយចិត្តដែលខ្លួនមានក្នុងនាមជាស្ត្រីខ្មែរ។*
>
> *(... ) គាត់មិនមែនជាមនុស្សអាក្រក់គួរឱ្យស្អប់ខ្ពើមនោះទេ តាមពិតគាត់(អតីតប្ដី)ជាមនុស្សមានសមត្ថភាពគ្រប់បែបយ៉ាង ចំណុចខ្សោយរបស់គាត់មានតែមួយគត់គឺការប្រចណ្ឌហួងហែងមិនសមហេតុផល ហើយចំណុចខ្សោយរបស់ខ្លួនគឺ មិនអាចទ្រាំទ្រនឹងការមិនឱ្យតម្លៃភាពត្រឹមត្រូវពីសំណាក់ប្ដី។*

## មូលហេតុទី៣៖ ការជ្រៀតជ្រែកពីញាតិពន្ធ

ក្នុងការរស់នៅ បើទោះបីជារៀបការរួចក្ដី ក៏ឪពុកម្ដាយនិងបងប្អូនតែងតែនៅខ្វល់ខ្វាយ គិតគូរពីសេចក្ដីសុខទុក្ខ ការចម្រើននិងវិនាសរបស់សាច់ឈាមខ្លួនជានិច្ច ផ្ទុយទៅវិញ ក៏កើតមានផងដែរនូវករណីសាច់ញាតិជ្រៀតជ្រែកហួសប្រមាណដល់ជីវិតគ្រួសារប្ដីប្រពន្ធ។ ក្នុងសង្គមខ្មែរ គេច្រើនពោលថា  ប្ដីឬប្រពន្ធអាចរកបាន ប៉ុន្តែឪពុកម្ដាយ និង បងប្អូន មិនអាចរកបានទេ។ អ្វីដែលកាន់តែពិបាកទ្រាំនោះគឺពាក្យសំដីម្ដាយក្មេក និងសាច់ថ្លៃនិយាយឆ្កឹះឆ្កៀលរករឿងអំពី

អ្វីដែលយើងមិនបានប្រព្រឹត្តប្រាប់ទៅកាន់ញាតិមិត្តជិតឆ្ងាយ។ ប្ដីឬប្រពន្ធខ្លះ មិនសូវអើពើអំពីធុរៈក្នុងគ្រួសារខ្លួន ប៉ុន្តែបែរជាគិតគូរដោះស្រាយតែរឿងសាច់ញាតិរបស់ខ្លួនមិនចេះចប់មិនចេះហើយឱ្យតែមានការទទូចនិងហៅរក។

> *(...) ការផ្គាប់ចិត្តសាច់ថ្លៃ ជាពិសេសម្ដាយក្មេកមិនងាយស្រួលទេ។ ពេលណាប្ដីឬប្រពន្ធបានស្ដាប់ពាក្យម្ដាយខ្លួន និងការញុះញង់របស់សាច់ញាតិនោះតែងតែមានប្រតិកម្មមិនសប្បាយចិត្ត ហើយក៏ចាប់ផ្ដើមបង្កជម្លោះឡើង។*
>
> *(...) សាច់ញាតិខាងគាត់(ខាងប្ដីខ្ញុំ)ចាត់ទុកខ្ញុំដូចអ្នកបម្រើ មិនឱ្យតម្លៃអ្វីទាល់តែសោះ។*
>
> *(...) ខ្ញុំនិងអតីតប្ដីតែងមានជម្លោះទាស់ទែងគ្នាមិនចេះចប់ ដោយសារ បញ្ហាជាច្រើនដូចជា ការជ្រៀតជ្រែកចាក់រុកពីម្ដាយក្មេក ដោយគាត់មិនសូវពេញចិត្តខ្ញុំជាកូនប្រសារ...*

## មូលហេតុទី៤៖ បញ្ហាហិង្សាផ្លូវភេទ

នៅក្នុងការសិក្សានេះ បញ្ហាហិង្សាផ្លូវភេទសំដៅដល់ការបៀតបៀន ការធ្វើឱ្យឈឺចាប់ខាងផ្លូវភេទពីដៃគូដោយពុំមានការយល់ព្រមឬដោយទើសទាល់ពីដៃគូម្ខាង ឬជាការបង្ខំដៃគូឱ្យប្រព្រឹត្តការរួមភេទដែលពួកគេមិនចង់ធ្វើ។ បញ្ហានេះក៏គ្របដណ្ដប់ដល់សកម្មភាពអវិជ្ជមានដូចជាភាពជើយប្រមើយចំពោះតម្រេកតណ្ហារបស់ដៃគូ តែបែរទៅប្រព្រឹត្តសេវនកិច្ចចំពោះអ្នកដទៃ ឬ ការផិតក្បត់ជាដើម។ មានករណីខ្លះ ភាគីប្ដីឬប្រពន្ធមានតម្រេកកាមខ្ពស់ដែលពិបាកទ្រាំមិនអាចគ្រប់គ្រងខ្លួនបានរហូតឈានដល់មានការប្រេចុយប្រថាន លបលួចមានដៃគូក្រៅ ផិតក្បត់ មានសហាយស្មន់ ឬទៅរកសេវាផ្លូវភេទខាងក្រៅ ដូចជានៅបនស្រី ឬបារ ខារ៉ាអូខេ ឬ លួចសេពសន្ថវៈជាមួយនារីណាម្នាក់ផ្សេងទៀត ម្ដងម្កាលឬជារឿយៗជាដើម។

> *(...) អតីតប្ដីរបស់ខ្ញុំដែលអាងលើកេរ្តិ៍តែករបស់ម៉ែឪ មិនបានខ្វល់ខ្វាយឬយកចិត្តទុកដាក់លើវាសនាកូនប្រពន្ធខ្លួន។ គាត់គិតតែសេពគប់មិត្តកក្តិណាដែលបបួលដើរលេង ចូលចិត្តស្រីស្រាល្បែងមិនគិតរកស៊ី ពឹងផ្អែកលើលុយម៉ែឪ និងជាពិសេសនៅតែជេរប្រមាថមើលងាយប្រពន្ធខ្លួនមិនព្រមកែប្រែខ្លួនឡើយ។*
>
> *(...) បន្ទាប់ពីខ្លួនកើតមានជំងឺទឹកនោមផ្អែម ថាមពលផ្លូវភេទចុះខ្សោយ គួបផ្សំប្រាក់ចំណូលប្រចាំខែមិនអាចទិញសម្ភារៈប្រើប្រាស់ទំនើបទាន់សម័យនឹងគេនោះ ប្រពន្ធរបស់គាត់អាយុ៣២ឆ្នាំដែលកំពុងពេញដោយសក្ដានុពលចំណង់ផ្លូវភេទ និងមានចិត្តស្រើបស្រាលផងនោះ គួបផ្សំនឹងឱកាសដែលប្ដីទៅបំពេញបេសកកម្មខេត្តឆ្ងាយអស់រយៈពេលយូរ អ្វីៗកន្លងហួសអស់ អង្គរក្លាយជាបាយ។ ទីផុតប្រពន្ធឆ្លើយសារភាព ព្រមទាំងអង្វរឱ្យដោះលែងគេឱ្យមានសេរីភាពដើម្បីបំពេញបំណងប្រាថ្នាគឺការវិលទៅជួបសង្សារចាស់វ័យក្មេងរបស់គេវិញ។ ទីបំផុតយើងទាំងពីរក៏ចែកផ្លូវគ្នាដោយសន្តិវិធី ហើយមានគូថ្មីរៀងៗខ្លួន។*
>
> *(...) កុំយកប្រពន្ធស្អាតហើយអាយុក្មេងជាងខ្លួនពេក ព្រោះបើយើងចាស់កម្លាំងកាយ កម្លាំងធនធានសេដ្ឋកិច្ចមិនដល់ (មិនគ្រប់) ពិបាកឃាត់ចិត្ត ឃាត់ខ្លួនប្រាណគេណាស់ វាហាក់ដូចជារឿងធម្មតាទៅហើយក្នុងសម័យយើងនេះ។ ករណីរបស់ខ្ញុំស្រដៀងនឹងបុរសម្នាក់ទៀតដែលនៅជិតផ្ទះគាត់ដែរប្រពន្ធផិតដូចគ្នា។ ប្រពន្ធបុរសម្នាក់នោះវ័យក្មេងនិងមានសម្រស់ដ៏ស្រស់ស្អាតដែលមនុស្សប្រុសស្រីតែងសរសើរមិនដាច់ពីមាត់។ ការលង់នឹងពាក្យសរសើរនិងលួងលោមបោកបញ្ឆោតក៏ធ្លាក់ខ្លួនចាញ់ល្បួង និងប្រគល់ខ្លួនឱ្យក្រុមដែលប្រព្រឹត្តសេពគ្រឿងញៀនតាមអំណាចទឹកលុយ ដើរចោលផ្ទះចោលប្ដី ទៅចូលបារខារ៉ាអូខេ ទម្រាំភ្ញាក់ខ្លួន អ្វីៗហួសពេលពិបាកកែ។ នាងចង់វិលរកទេនំចាស់ប៉ុន្តែ បុរសជាប្ដីមិនអាចទទួលយកបានព្រោះតែពាក្យ ខ្លាចគេថា អាវែក។ មិនមែនមានតែបុរសទេដែលផិតក្បត់ សម័យនេះក៏មានស្ត្រីផិតក្បត់ដែរដោយសារកោរភ្លើតភ្លើននឹងបញ្ហាផ្លូវភេទ គ្រឿងញៀន និងសម្ភារនិយម។*

## មូលហេតុទី៥៖ អំពើហិង្សាលើរាងកាយ

អំពើហិង្សាលើរាងកាយឬអំពើហិង្សាក្នុងគ្រួសារសំដៅដល់សកម្មភាពវាយដំឬបង្កឱ្យមានរបួសស្នាមលើផ្នែកនានានៃរាងកាយរបស់ដៃគូ។ តាមរយៈលទ្ធផលនៃការស្រាវជ្រាវនេះ អ្នករំលោភបំពានអាចជាប្ដីឬប្រពន្ធ (ភាគច្រើនតែកើតឡើងដោយ បុរសជាអ្នកប្រព្រឹត្តទៅលើស្ត្រី) ដោយស្មានថាខ្លួនជាម្ចាស់កម្មសិទ្ធនៃជនដែលរងគ្រោះនោះ។ គេតែងតែយល់ថា ខ្លួនរៀបការតាមប្រពៃណី ឬរៀបការតាមផ្លូវច្បាប់គឺមានន័យថា ដៃគូរបស់ខ្លួនជាកម្មសិទ្ធិផ្ដាច់មុខរបស់ខ្លួន ហើយខ្លួនអាចធ្វើការគ្រប់គ្រងវាយប្រដៅបានតាមចិត្ត។

> *(...) ដោយសារតែប្ដីខ្ញុំមិនមានរកចំណូលអ្វីសោះ ថែមទាំងស្រវឹងខ្ទប ជេរប្រទេចផ្ដាសា បណ្ដេញចេញពីផ្ទះ ហើយតែងមានការវាយប្រតប់ធ្វើឱ្យមានរបួសស្នាមផងដែរ។*

## មូលហេតុទី៦៖ កង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារ

នៅក្នុងការសិក្សានេះ កត្តាកង្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារសំដៅដល់ភាពរកាំរកូសនៃទំនាក់ទំនងគ្រួសារដែលបង្កមកពីការមិនពេញចិត្តពីដៃគូម្ខាងទៀត ការពុំព្រមទទួលយកហេតុផល យោបល់ អាកប្បកិរិយា ឥរិយាបថ ឬអ្វីៗដែលដៃគូខ្លួនមាន។ ទិដ្ឋភាពនេះក៏សំដៅដល់ការប្រកាន់លើគំនិតរៀងខ្លួន ការមិនស្ដាប់គំនិតដៃគូពេលពិភាក្សាឬដោះស្រាយបញ្ហានៅក្នុងគ្រួសារជាដើម។ ក្រោយរៀបអាពាហ៍ពិពាហ៍រួច គ្រួសារខ្លះមានការឈ្លោះប្រកែកគ្នាជាញឹកញាប់ ដែលធ្វើដៃគូពិបាកគោរពគ្នាទៅវិញទៅមកបំផុត។ ប្ដីនិងប្រពន្ធខ្លះមិនចុះសម្រុងគ្នាអាស្រ័យដោយបញ្ហាជាច្រើន ដូចជា ការទុកដាក់និងចាយវាយប្រាក់កាស ការមិនឯកភាពគ្នាលើទីកន្លែងរស់នៅ និង បញ្ហាជាច្រើនទៀត។ កាលពីមិនទាន់រៀបការ ម្ខាងៗមិនសូវហ៊ានបញ្ចេញចរិត ទស្សនៈ គំនិតពិតរបស់ខ្លួនដល់ដៃគូទាំងស្រុងឡើយ ដោយម្នាក់ៗតែងបង្ហាញនូវកាយវិការទន់ភ្លន់ ភាពមានសុជីវធម៌ និងមិនហ៊ានប្រកែកជំទាស់នឹងដៃគូរបស់ខ្លួននោះឡើយ។ ប៉ុន្តែក្រោយពីរៀបការរួច ភាគីនីមួយៗ រមែងបញ្ចេញនូវសារជាតិពិតរបស់ខ្លួន ជួនកាលបង្ខំឱ្យដៃគូទទួលយកនូវអ្វីៗដែលខ្លួនបានសម្ដែងឬមាន ដោយពុំបានពន្យល់ហេតុផលគ្រប់គ្រាន់ក៏មាន។ កត្តាកង្វះខាតនូវវិធីសាស្ត្រក្នុងពិភាក្សា ពន្យល់ហេតុផលឱ្យភាគីម្ខាងយល់ស្របឬសម្របសម្រួលគ្នារបៀបនេះ បានក្លាយជាបញ្ហាចម្បងមួយដែលឈានដល់ការលែងលះឬបែកបាក់គ្រួសារ។

> *(...) ពេលរៀបការហើយទើបយើងដឹងថា យើងទាំងពីរគ្រាន់តែមានចិត្ត មនោសញ្ចេតនាស្រឡាញ់គ្នាប៉ុណ្ណោះ ចំណែកឯគំនិតទស្សនៈគឺខុសគ្នាដាច់ស្រឡះទាំងស្រុង។ មុនពេលការយើងមិនបានដឹងថាវាខុសគ្នាទាំងស្រុងបែបនេះឡើយ។ នៅពេលប្រពន្ធចង់រស់នៅផ្ទះជាមួយឪពុកម្ដាយបង្កើតរបស់ខ្លួនដែលនៅឆ្ងាយពីកន្លែងធ្វើការ ចំណែកប្ដីចង់រស់នៅផ្ទះជួលដែលនៅជិតរោងចក្រដែលជាកន្លែងឯការងារ។*

ទិដ្ឋភាពនៃការមិនចុះសម្រុងមួយទៀតគឺប្រពន្ធចង់បានកូនរីឯប្ដីវិញមិនទាន់ចង់មាន ព្រោះគិតឃើញថាជីវភាពគ្រួសារមិនទាន់មានលំនឹង ដោយសារប្រាក់ចំណូលស្មើរស្មើនឹងប្រាក់ចំណាយ ចាយមិនគ្រប់គ្រាន់។ ដោយសារតែពុំមានការយោគយល់និងស្វែងរកដំណោះស្រាយដែលអាចទទួលយកបានទាំងពីរនាក់ បញ្ហានេះបានឈានដល់ការលែងលះគ្នា។

គួរបញ្ជាក់ថា បើទោះបីជាលទ្ធផលនៃការសិក្សានេះបង្ហាញពីមូលហេតុដោយឡែកៗក្តី តាមរយៈលទ្ធផលនៃការសន្ទនាផ្ទាល់ជាមួយក្រុមគោលដៅស្រាវជ្រាវ គេអាចកំណត់បានថានៅក្នុងការរស់នៅជាក់ស្តែង កត្តាមួយចំនួនទៀតដូចជាកម្រិតនៃការសិក្សា មុខរបរឬការងារ ទំហំប្រាក់ចំណូលជាដើម ក៏បានក្លាយជាមូលហេតុចូលរួមដោយប្រយោលផ្ទាល់ឬជាផ្នែកមួយដែលជំរុញឱ្យលេចឡើងនូវមូលហេតុទាំងប្រាំមួយខាងលើហើយដែលបានឈានទៅដល់ការបែកបាក់គ្រួសារផងដែរ។ ម្យ៉ាងទៀត ទិដ្ឋភាពនៃបញ្ហាមានការស្មុគស្មាញច្រើន ជាឧទាហរណ៍ គ្រួសារខ្លះដោយសារតែប្រពន្ធរបស់ខ្លួនពុំមានអារម្មណ៍ផ្លូវភេទឬមានជំងឺពុំរ៉ៃមិនអាចរួមភេទបាន បុរសជាប្តីបានស្វែងរកដៃគូពីខាងក្រៅ ឬលបមានស្រីខាងក្រៅ។ គ្រួសារខ្លះ ដោយសារតែមុខរបររកស៊ីត្រូវមានទំនាក់ទំនងជាមួយនឹងមនុស្សច្រើន ក៏បានធ្វើឱ្យដៃគូរបស់ខ្លួនមានការប្រចណ្ឌ ខ្វះការយោគយល់ និងដោយខ្វះការពិភាក្សាគ្នាឱ្យបានត្រឹមត្រូវផងនោះអាចឈានដល់ហិង្សាក្នុងគ្រួសារនិងបង្កើតឱ្យការបែកបាក់គ្រួសារ។

## ៤. ការពិភាក្សា

ការស្រាវជ្រាវអំពីការបែកបាក់គ្រួសារក្នុងចំណោមគ្រួសាររបស់ប្រជាពលរដ្ឋកម្ពុជាក្នុងសង្កាត់ស្ទឹងមានជ័យនេះមានវត្ថុបំណងកំណត់អំពីមូលហេតុដែលឈានទៅដល់ការបែកបាក់គ្រួសារ ដែលបញ្ហានេះ បានក្លាយជាទិដ្ឋភាពអវិជ្ជមានមួយក្នុងសង្គម និងបានប៉ះពាល់យ៉ាងខ្លាំងដល់សាម៉ីខ្លួន អនាគតកូន និង សង្គមជាតិផងដែរ។ លទ្ធផលស្រាវជ្រាវបានបង្ហាញថាមូលហេតុដែលបណ្តាលឱ្យមានការបែកបាក់គ្រួសារសម្រាប់ករណីកសង្កាត់ស្ទឹងមានជ័យនេះមានដូចជា កត្តាហិង្សាសេដ្ឋកិច្ច ការប្រចណ្ឌ ការជ្រៀតជ្រែកនៃញាតិពន្ធ បញ្ហាផ្លូវភេទ អំពើហិង្សាផ្លូវកាយ និងខ្វះវិធីសាស្ត្រក្នុងការពិភាក្សាបញ្ហាគ្រួសារ។ បើទោះបីជាមូលហេតុទាំងនេះកើតចេញពីវិសាលភាពនៃការស្រាវជ្រាវលើក្រុមគោលដៅរស់នៅសង្កាត់ស្ទឹងមានជ័យក្តី គេសង្កេតឃើញថាវាក៏ជាមូលហេតុចម្បងៗដែលបណ្តាលឱ្យមានការបែកបាក់គ្រួសារក្នុងចំណោមប្រជាពលរដ្ឋកម្ពុជាទូទៅដែរ។ ទិដ្ឋភាពអំពីមូលហេតុនៃការបែកបាក់គ្រួសារប្រហាក់ប្រហែលគ្នានេះក៏បានបង្ហាញផងដែរតាមបណ្តាញទំនាក់ទំនងសង្គមដូចជា វិទ្យុ ABC Cambodia News និងភ្នាក់ងារជំរុញការអនុវត្តច្បាប់នៅស្ថានីយ៍ទូរទស្សន៍ត្រយ៉ងជាដើម។ នៅលើបណ្តាញទំនាក់ទំនងសង្គម មានសាច់រឿងលែងលះឬបែកបាក់គ្រួសារជាច្រើនដែលបង្ហោះនិងផ្សព្វផ្សាយ ដែលមូលហេតុកើតចេញពីទិដ្ឋភាពជាច្រើនដូចជា អំពើហិង្សាក្នុងគ្រួសារ, ការមិនឱ្យតម្លៃគ្នា (KHMERLOAD, 2021) ការលូកដៃជ្រៀតជ្រែកពីញាតិពន្ធ ការផិតក្បត់និងប្រចណ្ឌជាដើម (ABC CAMBODIA NEWS, 2023)។

លទ្ធផលស្រាវជ្រាវក៏បានបង្ហាញផងដែរថា មូលហេតុនៃការបែកបាក់របស់ក្រុមគ្រួសារខ្លះបង្កឡើងដោយកត្តាមួយឬច្រើនចេញពីមូលហេតុខាងលើ និងទិដ្ឋភាពក៏មានលក្ខណៈស្មុគស្មាញផងដែរ។ ជាឧទាហរណ៍ គ្រួសារខ្លះ បញ្ហាកើតឡើងចេញពីការផិតក្បត់ ទើបបង្កើតឱ្យមានការប្រចណ្ឌពីភាគីម្ខាងទៀត និងចុងក្រោយក៏បានឈានទៅដល់អំពើហិង្សាក្នុងគ្រួសារ។ ដោយសារតែពុំអាចទ្រាំនឹងការវាយដំច្រំជាក់(ជាទូទៅប្តីវាយប្រពន្ធ)ពីសំណាក់ភាគីម្ខាងបាន ទើបឈានទៅដល់ការសុំចែកផ្លូវគ្នា ឬ កើតមាននូវបណ្តឹងសុំលែងលះជាដើម។ ករណីខ្លះទៀត ដោយសារតែបញ្ហាហិរញ្ញវត្ថុក្នុងគ្រួសារ ការចូលចិត្តសប្បាយហ៊ឺហា ទើបឈានទៅកើតមានអំពើផិតក្បត់ មានការប្រចណ្ឌ និង ឈានទៅដល់ការបែកបាក់គ្រួសារ។ ក្រុមគ្រួសារខ្លះ ពុំមានបញ្ហាធំដុំប៉ុន្មានទេ ដោយគ្រាន់តែភាគីទាំងពីរមានការពិបាកក្នុងការទំនាក់

ទំនង ពិបាកនិយាយគ្នា ពេលមានបញ្ហាក៏មិនដឹងពិភាក្សាដោះស្រាយគ្នាបែបណា ក៏សម្រេចចិត្តសុំបែកគ្នាក៏មាន។ តាមរយៈការសិក្សានេះ អ្នកស្រាវជ្រាវក៏កំណត់បានថា កត្តាបុគ្គលដូចជាកម្រិតសិក្សា មុខរបរការងារ ការសេពគប់មិត្តភក្តិ របៀបនៃការចាយវាយប្រាក់កាសជាដើម ក៏ចូលរួមបង្កើតឱ្យចេញជាបញ្ហាចម្បងធំៗខាងលើ និងចុងក្រោយបានឈានទៅដល់ការលែងលះឬបែកបាក់គ្រួសារផងដែរ។

ផ្អែកលើកត្តាប្រពៃណី សង្គមកម្ពុជាពុំសូវផ្ដល់តម្លៃទៅលើការលែងលះគ្នានោះទេ នារីដែលលែងលះប្ដីឬត្រូវប្ដីលែង តែងទទួលរងនូវការមាក់ងាយពីបងប្អូនឬញាតិជិតខាង។ ដោយសារកត្តានេះ នារីខ្មែរជាច្រើនបានក្លាយខ្លួនជាជនរងគ្រោះអាពាហ៍ពិពាហ៍ ដោយពួកគេត្រូវរស់នៅរងអំពើហិង្សាទាំងផ្លូវកាយនិងផ្លូវចិត្ត។ ទោះជាយ៉ាងណា ទិដ្ឋភាពបែបនេះមានការប្រែប្រួលច្រើនសម្រាប់សង្គមនាពេលបច្ចុប្បន្ន ដោយនិន្នាការសព្វថ្ងៃគេសង្កេតឃើញមានភាគីរងគ្រោះខ្លះយល់ឃើញថា ការលែងលះអាចជាដំណោះស្រាយនៃបញ្ហា ហើយការទ្រាំរស់នៅក្នុងវិបត្តិគ្រួសារទៅវិញទេជាបញ្ហា។ គេយល់ថា ការទ្រាំរស់នៅជុំគ្នាជាមួយដៃគូដែលពុំចុះសម្រុងនឹងគ្នា ដៃគូផិតក្បត់ គ្រួសារដែលតែងកើតមានអំពើហិង្សាគ្រប់រូបភាព នឹងផ្ដល់ផលវិបាកច្រើន ហើយប្រសិនបើមានកូនទៀតនោះនឹងអាចប៉ះពាល់ដល់ពួកគេផងដែរ។ ការបែកបាក់គ្រួសារតិចឬច្រើនតែងបង្កនូវផលប៉ះពាល់ទាំងផ្លូវកាយ ផ្លូវចិត្ត ទាំងសម្រាប់បច្ចុប្បន្ននិងអនាគត ទាំងសម្រាប់បុគ្គលខ្លួនឯងផ្ទាល់ កូនៗ និងសង្គមផងដែរ។ សម្រាប់បុគ្គល ផលប៉ះពាល់អាចធ្វើឱ្យសាមីខ្លួនបាក់ទឹកចិត្ត កើតមានវិបត្តិផ្លូវចិត្ត អាចប៉ះពាល់ដល់សេដ្ឋកិច្ចគ្រួសារ ជាដើម។ ការលែងលះ អាចបង្កជាការឈឺចាប់ដល់កុមារជាពិសេសផ្លូវចិត្ត ដែលអាចកែប្រែកុមារពីក្មេងដែលតែងតែរួសរាយ មកជាក្មេងស្ងប់ស្ងាត់ ពីក្មេងស្លូតបូត មកជាក្មេងលែងចេះស្ដាប់បង្គាប់ចាស់ទុំក៏មាន។ ជាមួយនឹងហេតុផលនេះ ឪពុកម្ដាយខ្លះដែលចង់លែងលះ ប៉ុន្តែដោយមានការព្រួយបារម្ភពីសុខុមាលភាពកូនៗរបស់គេក៏សុខចិត្តរស់នៅក្នុងអាពាហ៍ពិពាហ៍ ដែលគ្មានសុភមង្គល ដើម្បីការពារកូនពីភាពរន្ធត់នៃការលែងលះ។

ការបែកបាក់គ្រួសារក៏អាចបង្កើតនូវបញ្ហាអវិជ្ជមាននៅក្នុងសង្គមទាំងដោយផ្ទាល់និងដោយប្រយោល ជាពិសេសពាក់ព័ន្ធនឹងប្រពៃណី វប្បធម៌ សន្តិសុខសង្គម សេដ្ឋកិច្ចនិងការអភិវឌ្ឍន៍ជាដើម ( Judy, 2021 )។ ផលប៉ះពាល់អវិជ្ជមានលើសង្គម ក៏មានប្រភពដោយប្រយោលចេញពីកុមារដែលមានការបែកបាក់គ្រួសារផងដែរ។ ដោយសារខ្វះភាពកក់ក្ដៅ ខ្វះលំនឹងផ្លូវចិត្តពីក្រុមគ្រួសារ កុមារអាចមានចិត្តគំនិតទុទិដ្ឋិនិយម ទៅលើទំនាក់ទំនងជាមួយមនុស្សជុំវិញខ្លួនគេ អាចប្រព្រឹត្តអំពើអវិជ្ជមានទៅលើសង្គមដូចជាសេពគប់មិត្តមិនល្អ សេពគ្រឿងញៀន ឬ អាចឈានទៅដល់ការប្រព្រឹត្តនូវបទល្មើសធ្ងន់ធ្ងរកម្រិតព្រហ្មទណ្ឌក៏មាន។ ក្មេងខ្លះដោយសារការបែកបាក់គ្រួសារ ខ្វះភាពកក់ក្ដៅ ធ្វើឱ្យបាក់ទឹកចិត្ត សុខភាពធ្លាក់ខ្សោយ សិក្សាមិនកើត ដែលចុងក្រោយបង្កើតជាបន្ទុកកាន់តែច្រើនសម្រាប់សង្គម និងរាំងស្ទះដល់ការអភិវឌ្ឍជាតិ។

# ៥. សន្និដ្ឋាននិងអនុសាសន៍

## ៥.១. សេចក្ដីសន្និដ្ឋាន

ការសិក្សាអំពីការបែកបាក់គ្រួសារក្នុងសង្គមកម្ពុជាមានវត្ថុបំណងចម្បងគឺកំណត់នូវបុព្វហេតុដែលឈានទៅដល់ការបែកបាក់គ្រួសាររបស់ប្រជាពលរដ្ឋក្នុងសង្កាត់ស្ទឹងមានជ័យ។ ការសិក្សានេះមានការចូលរួមពីក្រុមគោលដៅស្រាវ

ជ្រាវចំនួន២៥នាក់ ដែលបានផ្តល់ទិន្នន័យតាមរយៈការសម្ភាសស៊ីជម្រៅ។ លទ្ធផលបង្ហាញថា មូលហេតុចម្បងនៃការលែងលះរបស់គ្រួសារនៅក្នុងសង្កាត់ស្ទឹងមានជ័យមានដូចជា ហិង្សាសេដ្ឋកិច្ច, ការប្រចណ្ឌ, ការជ្រៀតជ្រែកនៃញាតិពន្ធ, បញ្ហាផ្លូវភេទ, អំពើហិង្សាផ្លូវកាយ និង ខ្វះវិធីសាស្ត្រពិភាក្សាបញ្ហាគ្រួសារ។ ក្រៅពីមូលហេតុចម្បងៗទាំងនេះ ការសិក្សាក៏បង្ហាញនូវទិដ្ឋភាពផ្សេងទៀតដែលបង្កទៅជាមូលហេតុទាំងនេះ ឬ បានចូលរួមដោយផ្ទាល់ឬប្រយោលទៅក្នុងបញ្ហានៃការបែកបាក់គ្រួសារផងដែរ។ គ្រួសារខ្លះបែកបាក់គ្នាដោយសារមូលហេតុមួយឬច្រើន និងកត្តាផ្ទាល់ខ្លួនដូចជាកម្រិតសិក្សា មុខរបរឬការងារ របៀបចាយវាយប្រាក់កាស ការសេពគប់មិត្តភក្តិសុទ្ធតែមានចំណែកក្នុងការបញ្ហានេះ។

ការសិក្សានេះមានវិសាលភាពចង្អៀត ប៉ុន្តែ លទ្ធផលនៃការសិក្សាពិតជាបានឆ្លុះបញ្ចាំងពីទិដ្ឋភាពជាក់ស្តែងដែលកំពុងកើតមាននៅក្នុងសង្គមកម្ពុជា បើទោះបីជាមិនបានគ្រប់ជ្រុងជ្រោយក្តី។ លទ្ធផលចេញពីប្រធានបទនេះមានសារៈសំខាន់សម្រាប់អ្នកធ្វើគោលនយោបាយ អ្នកស្រាវជ្រាវ អ្នកធ្វើការងារទាក់ទងនឹងបញ្ហាសង្គម ដើម្បីពិចារណានិងស្វែងរកដំណោះស្រាយសម្រាប់បញ្ហាដែលកើតមាន។

### ៥.២. អនុសាសន៍

គោលដៅនៃការចាប់យកជីវិតគូគឺចង់រួមរស់នៅជាមួយគ្នារហូតដល់ចាស់ឬរហូតដល់ស្លាប់រៀងៗខ្លួន ក៏ប៉ុន្តែ ការចង់បាននិងការពិត មិនប្រាកដជាស្ថិតនៅក្នុងផ្លូវជាមួយគ្នាគ្រប់ពេលនោះទេ។ ដូចដែលបានលើកឡើងខ្លះៗពីផលវិបាកនៃការបែកបាក់គ្រួសារដល់សាមីបុគ្គល គ្រួសារ កូនៗ និង សង្គម ក្នុងផ្នែកទី៤ខាងលើ នៅក្នុងចំណុចនេះ អ្នកស្រាវជ្រាវមានបំណងចូលរួមជាទស្សនទានខ្លះៗដើម្បីជាទុនក្នុងការបង្ការ ឬ បញ្ចៀសនូវវិបត្តិគ្រួសារក្នុងចំណោមក្រុមគ្រួសារនានានៅកម្ពុជា។ ដើម្បីជៀសវាងការបែកបាក់គ្រួសារ(ការលែងលះ) ឬ ដើម្បីជៀសវាងការត្រដររស់នៅទ្រាំនឹងការឈឺចាប់ លេបក្រួសលេបថ្ម ក្នុងសភាពមិនចុះសម្រុងគ្នា ភាគីទាំងសងខាង[៧] ឬ គូស្វាមីភរិយាអាចពិចារណាទៅលើអនុសាសន៍មួយចំនួនដូចខាងក្រោម៖

- *ស្វែងយល់ពីជីវិតគូឱ្យបានច្បាស់លាស់៖* ពាក្យស្លោកខ្មែរយើងនិយាយថា *"គិតហើយចាំគូរ"* ដែលសំដៅដល់ការពិចារណាឱ្យហ្មត់ចត់ច្បាស់លាស់មុននឹងសម្រេចចិត្តធ្វើអ្វីមួយ។ សម្រាប់ភាគីដែលនឹងសម្រេចចិត្តរស់នៅជាមួយគ្នា គប្បីសិក្សាស្វែងយល់អំពីជីវិតគូ អាចធ្វើការឆ្លុះបញ្ចាំងអំពីសង្គម ឬ ពិភាក្សាជាមួយអ្នកជំនាញ ឬចាស់ទុំពីផលដំណើរជីវិតគូឱ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តរៀបការ។ ការស្វែងយល់ពីជីវិតគូ អាចឱ្យភាគីទាំងពីរមានយល់ពីបញ្ហាជីវិត និងមានការត្រៀមខ្លួនខ្ពស់ក្នុងការដោះស្រាយឧបសគ្គជីវិត បញ្ហាដែលអាចនឹងកើតមានក្រោយរៀបអាពាហ៍ពិពាហ៍ជាដើម។
- *ស្វែងយល់ពីដៃគូខ្លួនមុនសម្រេចចិត្តរៀបការ៖* បន្ថែមពីការស្វែងយល់ពីជីវិតគូ ភាគីទាំងសងខាងគួរសិក្សាពីគ្នាទៅវិញទៅមកឱ្យបានច្បាស់លាស់សិនមុននឹងសម្រេចចិត្តរៀបការ។ តាមទស្សនៈ "ឆ្នាំងណាគម្របហ្នឹង" បុរសនិងស្ត្រីត្រូវតែរើសដៃគូរប្រចាំជីវិតរបស់ខ្លួនឱ្យបានត្រឹមត្រូវតាមចំណូលចិត្ត ស្របនឹងអត្តចរិត គុណភាពជីវិត រសនិយម ការនិយមរបស់ខ្លួន ទើបភាពចុះសម្រុងក្នុងគ្រួសារអាចកើតមានបានខ្ពស់។ សាមី

[៧] ក្នុងន័យនេះ អ្នកស្រាវជ្រាវចង់សំដៅដល់ភាគីទាំងពីដែលសម្រេចចិត្តថានឹងរៀបការជាមួយគ្នា។

ខ្លួនត្រូវដឹងឱ្យបានច្បាស់លាស់ថា ខ្លួនឯងជាមនុស្សប្រភេទណា ហើយត្រូវជ្រើសរើសដៃគូប្រភេទណាជាមុនសិន បើទោះបីជាមិនបានគ្រប់ជ្រុងជ្រោយ ក៏បានឆ្លងកាត់ការវិភាគ និងសិក្សាពីបុគ្គលដែលខ្លួនសម្រេចចិត្តនឹងផ្ញើវាសនាជីវិតជាមួយនាពេលអនាគត។

- *ចុះសំបុត្រអាពាហ៍ពិពាហ៍ឱ្យបានត្រឹមត្រូវ៖* ក្រោយឬមុនរៀបអាពាហ៍ពិពាហ៍គូស្វាមីភរិយាគប្បីចុះសំបុត្រអាពាហ៍ពិពាហ៍ ឱ្យបានស្របច្បាប់ ព្រោះសំបុត្រអាពាហ៍ពិពាហ៍ក៏អាចជាចំណងមួយដ៏រឹងមាំក្នុងការការពារដៃគូជីវិតពីការលែងលះគ្នាបានផងដែរ ជាពិសេសបំផុតពេលដែលពួកគេមានកូន។ សម្រាប់ប្ដីប្រពន្ធដែលរស់នៅមិនចុះសម្រុងគ្នា ការអត់មានកូន អត់សំបុត្រអាពាហ៍ពិពាហ៍ គឺជាឱកាសមួយជំរុញដល់ការលែងលះឬបែកបាក់គ្រួសារ។
- *ម្ចាប់អារម្មណ៍ យោគយល់ និង អធ្យាស្រ័យ៖* គ្រួសារណាក៏មានបញ្ហាដែរ បើទោះបីមិនធំក៏តិចតួចអាស្រ័យលើស្ថានភាពនៃបញ្ហា ការចេះយោគយល់ ឬ ចេះអធ្យាស្រ័យឱ្យគ្នាទៅវិញទៅមក។ សម្រាប់សង្គមបច្ចុប្បន្នបុរសនិងស្ត្រីគួរស្វែងយល់ពីទស្សនៈយេនឌ័រ ត្រូវផ្ដល់តម្លៃឱ្យគ្នាទៅវិញទៅមក ពិភាក្សាគ្នាដោយស្ងប់អារម្មណ៍និងមានអធ្យាស្រ័យខ្ពស់ ទើបបញ្ហាគ្រួសារមិនធ្លាក់ទៅក្នុងស្ថានភាពកាន់តែអាក្រក់។ គេតែងនិយាយថា "បើភ្លើងឆេះហើយកុំយកសាំងទៅចាក់ពីលើ" ដូចនេះ ប្រសិនបើភាគីម្ខាងក្ដៅ ម្ខាងទៀតត្រូវព្យាយាមធ្វើខ្លួនជាទឹក ព្យាយាមសម្ងប់អារម្មណ៍ ទុកបញ្ហាចោលមួយឡែកសិន បន្ទាប់មកចាំពិភាក្សាគ្នាពេលចិត្តត្រជាក់រៀងៗខ្លួន។

## ឯកសារយោង


ប៉ែន, បូណា. (២០១៤). តើកំណើននៃការលែងលះប្ដីប្រពន្ធជារឿងល្អឬអាក្រក់សម្រាប់សង្គមខ្មែរ? វិទ្យុបារាំង FRI ដកស្រង់ចេញពីគេហទំព័រ៖ https://www.rfi.fr/km/cambodia-cambodian-divorce

រដ្ឋសភា. (១៩៨៩). ច្បាប់ស្ដីពីអាពាហ៍ពិពាហ៍និងគ្រួសារឆ្នាំ១៩៨៩

រដ្ឋសភា. (២០០៦). ច្បាប់ស្ដីពីឯកពន្ធភាព ឆ្នាំ២០០៦

រដ្ឋសភា. (២០០៧). ក្រមរដ្ឋប្បវេណី២០០៧

រដ្ឋសភា. (២០១១). ច្បាប់ស្ដីពីការអនុវត្តក្រមរដ្ឋប្បវេណី ២០១១ មាត្រា៦០

រឹម, ភារី. (២០២០). យុវជនខ្មែរមួយចំនួន រៀបការលឿន លែងលះគ្នាក៏លឿន. *សារព័ត៌មានថ្មីថ្មី.* ដកស្រង់ចេញពីគេហទំព័រ៖ https://thmeythmey.com/?page=detail&id=88908

ABC CAMBODIA NEWS. (២០២៣). រើសទៅប្ដីវាំង ប្រពន្ធដើម & ប្រពន្ធចុង បងយកមួយណា. ខ្លឹមសារយកចេញពី៖ https://www.youtube.com/watch?v=VzNeUAxsRw0

Akanishi, Yoshifumi. (២០០៦). បញ្ហានានាជុំវិញការលែងលះ(សេចក្តីពន្យល់ត្រួសៗអំពីច្បាប់ជប៉ុន). ឯកសារទាញយកចេញពីគេហទំព័រ៖ https://www.jica.go.jp/Resource/project/english/cambodia/014/materials/c8h0vm00009678s9-att/1406_06.pdf

BTV. ២០១៧). ចំណងអាពាហ៍ពិពាហ៍និងការលែងលះ. ខ្លឹមសារយកចេញពី https://www.youtube.com/watch?v=Ic7XAhWbzAY

Judy, Howell. (២០២១). ការបែកបាក់គ្រួសារ៖ មូលហេតុផលវិបាកដំណោះស្រាយ. ដកស្រង់ចេញពីគេហទំព័រ៖ https://km.warbletoncouncil.org/desintegracion-familiar-causas-consecuencias-soluciones-7634

KHMERLOAD. (២០២១). ក្តៅៗ ទីបំផុត ពូម៉ៅ សម្រេចចិត្តសាងក្តួស ព្រោះមូលហេតុនេះ។ ដកស្រង់ចេញពីគេហទំព័រ៖ https://www.khmerload.com/article/163362



**ឈុន ផារ៉េង**

**កន្លែងការងារ៖**
រាជបណ្ឌិត្យសភាកម្ពុជា

**កម្រិតសិក្សា៖**
បរិញ្ញាបត្រជាន់ខ្ពស់ទស្សនវិទ្យា
(រាជបណ្ឌិត្យសភាកម្ពុជា)

**ចំណូលចិត្តស្រាវជ្រាវ៖**
- ទស្សនវិជ្ជាសង្គមនិងនយោបាយ



**ប៉ាន់ វុត្ថា**

**កន្លែងការងារ៖**
រាជបណ្ឌិត្យសភាកម្ពុជា

**កម្រិតសិក្សា៖**
បណ្ឌិតទស្សនវិទ្យា
(រាជបណ្ឌិត្យសភាកម្ពុជា)

**ចំណូលចិត្តស្រាវជ្រាវ៖**
- ទស្សនវិជ្ជាសង្គមនិងនយោបាយ



**ហ៊ឹម ញាណារិទ្ធ**

**កន្លែងការងារ៖**
រាជបណ្ឌិត្យសភាកម្ពុជា

**កម្រិតសិក្សា៖**
បណ្ឌិតទស្សនវិទ្យា
(រាជបណ្ឌិត្យសភាកម្ពុជា)

**ចំណូលចិត្តស្រាវជ្រាវ៖**
- ទស្សនវិជ្ជាសង្គមនិងនយោបាយ



**ភ្លាន់ ផុល**

**កន្លែងការងារ៖**
រាជបណ្ឌិត្យសភាកម្ពុជា

**កម្រិតសិក្សា៖**
បណ្ឌិតទស្សនវិទ្យា
(រាជបណ្ឌិត្យសភាកម្ពុជា)

**ចំណូលចិត្តស្រាវជ្រាវ៖**
- ទស្សនវិជ្ជាសង្គមនិងនយោបាយ

កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

Cambodian Journal of Humanities and Social Sciences

Website: https://cjhss-journal.com/

# ការសិក្សាខ្នាតតូចអំពីទស្សនៈអតិថិជនកម្ពុជាទៅលើការទិញនិងសេវាកម្មទិញ-លក់ផលិតផលតាមអនឡាញ

# A Small-scale Study of Cambodian Customer's Perception towards Online Shopping and Service Quality

**មឿង ចំរើន[១] , លី តុង[២]**

[១] លេខាធិការដ្ឋានរបស់ក្រុមប្រឹក្សាបណ្ឌិតសភាចារ្យនៃរាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ chamroeun.rac@gmail.com

[២] វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, រាជបណ្ឌិត្យសភាកម្ពុជា
អ៊ីមែល៖ lytongcambodia2013@gmail.com

បានទទួល៖ ០១ តុលា ២០២៣; ទទួលបោះពុម្ព៖ ១៨ វិច្ឆិកា ២០២៣; បោះពុម្ព៖ ៣១ ធ្នូ ២០២៣

**ទំនាក់ទំនង៖** chamroeun.rac@gmail.com

**អាគតដ្ឋាន៖** មឿង ចំរើន និង លី តុង. (២០២៣). ការសិក្សាខ្នាតតូចអំពីទស្សនៈអតិថិជនកម្ពុជាទៅលើការទិញនិងសេវាកម្មទិញ-លក់ផលិតផលតាមអនឡាញ. *កាលិកបត្រស្រាវជ្រាវមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម, ២*(២), ៥៦-៧៤.

## សង្ខិត្តន័យ

ការសិក្សាអំពីទស្សនៈរបស់អតិថិជនកម្ពុជាទៅលើអាជីវកម្ម និងសេវាកម្មទិញ-លក់ទំនិញតាមអនឡាញនេះមានការចូលរួមពីក្រុមគោលដៅស្រាវជ្រាវចំនួន ២៣១នាក់។ ការសិក្សាប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ និងប្រមូលទិន្នន័យដោយប្រើវិធីស្ទង់មតិតាមអនឡាញ។ សំណាកស្រាវជ្រាវបង្កើតឡើងតាមវិធីជ្រើសរើសសំណាកតៗគ្នានិងវិធីចូលរួមដោយស្ម័គ្រចិត្ត ដោយក្រុមគោលដៅស្រាវជ្រាវជាអតិថិជនមានបទពិសោធទិញនិងកំពុងបន្តទិញទំនិញតាមអនឡាញ។ ទស្សនៈទៅលើសេវាកម្មទិញ-លក់ទំនិញតាមអនឡាញផ្តោតទៅលើទិដ្ឋភាពចំនួនប្រាំគឺ ការរចនាមុខងារ និង ភាពងាយស្រួលប្រើប្រាស់នៃថ្នាលទិញទំនិញ-លក់ទំនិញតាមអនឡាញ, ការធានារក្សានូវឯកជនភាពនិងសុវត្ថិភាពព័ត៌មានរបស់អតិថិជន, ការរៀបចំដឹកជញ្ជូនផលិតផលឱ្យអតិថិជនតាមពេលកំណត់, ការ

ដោះស្រាយបញ្ហាជូនអតិថិជននិងភាពស្មោះត្រង់ និងការយកចិត្តទុកដាក់និងជួយអតិថិជនក្នុងការជ្រើសរើសទំនិញ។ លទ្ធផលបង្ហាញថាសម្លៀកបំពាក់ សម្ភារៈគេហដ្ឋាន អាហារនិងភេសជ្ជៈ និងផលិតផលសម្រាប់ថែសម្ផស្សនិងគ្រឿងសម្អាងទទួលបានការបញ្ជាទិញច្រើនជាងគេ។ វិធីឬរបៀបក្នុងការទូទាត់ថ្លៃទំនិញអនឡាញដែលពេញនិយមជាងគេមានពីរគឺ ការទូទាត់តាមកម្មវិធីធនាគារលើទូរសព្ទ ឬ KHQR Code និងការទូទាត់ពេលទំនិញមកដល់ដៃ។ លទ្ធផលក៏បានបង្ហាញផងដែរថា ជាទូទៅអតិថិជនមានទស្សនៈវិជ្ជមានទៅលើទិដ្ឋភាពទាំងប្រាំនៃសេវាកម្មទិញ-លក់ទំនិញតាមអនឡាញជាពិសេសទៅលើចំណុចនៃការរៀបចំគេហទំព័រឬថ្នាលលក់ទំនិញតាមអនឡាញ និង គុណភាពនៃការរៀបចំ ដឹកជញ្ជូនទំនិញឱ្យអតិថិជន។ ទិដ្ឋភាពដែលទទួលបានការពេញចិត្តតិចជាងគេគឺពាក់ព័ន្ធនឹងដំណោះស្រាយបញ្ហាជូនអតិថិជនដោយភាពស្មោះត្រង់។ ដើម្បីបង្កើនភាពជោគជ័យក្នុងអាជីវកម្មអនឡាញ ម្ចាស់អាជីវកម្មអនឡាញគួរពិចារណាលើអនុសាសន៍ពាក់ព័ន្ធនឹងកត្តាសុវត្ថិភាពប្រតិបត្តិការតាមអនឡាញ, ភាពទាក់ទាញនៃថ្នាលអាជីវកម្មអនឡាញ, ការបង្ហាញព័ត៌មានផលិតផល, ដំណោះស្រាយចំពោះអតិថិជន, គោលការណ៍បង្វិលត្រឡប់ទំនិញឬសំណងថ្លៃទំនិញ និងភាពបត់បែននៃការធ្វើទីផ្សារ។

**ពាក្យគន្លឹះ:** ទស្សនៈអតិថិជន, ការទិញ-លក់ទំនិញតាមអនឡាញ, សេវាកម្ម, កម្ពុជា

**ABSTRACT**

The study on Cambodian consumers' views on online business and services quality involved 231 research participants. The study employed quantitative research methods and the data were collected using online survey method. The sample was formed using snowballing and volunteering participation where the participants were Cambodian customers who have been using online shopping service. Five aspects of online shopping namely online platform design, functionality and ease of use, privacy and security of customer information, product delivery arrangements, post-purchase customer's problem-solving, and buyer's helpfulness to customer in product recommendation were focused. The results showed that clothing, home appliances, food and beverages, and beauty and cosmetics products received the most orders using online shopping service. Two most common payment for online shopping were mobile banking or KHQR Code payment and payment on delivery (POD). The result also revealed that the customers generally had a positive view toward the five aspects of online shopping service, especially on the aspect of website or online shopping platform design and the quality of product preparation and delivery. The least satisfying aspect was the honestly of buyers deal with the customer's post-purchase issues. The study recommended that online business's owners should focused on improving online shopping security, user's friendly online platform, product description, post-purchase solution, return and refund, and flexible marketing strategies.

**KEYWORDS:** customer's perception, online shopping, service, Cambodia

# ១. សេចក្តីផ្តើម

## ១.១. ទិដ្ឋភាពទូទៅ

ការរីកចម្រើនផ្នែកបច្ចេកវិទ្យានិងអ៊ីនធឺណិតបានជះឥទ្ធិពលយ៉ាងខ្លាំងមកលើការរស់នៅរបស់ប្រជាជនលើពិភពលោក ដោយដំណើរការសង្គមស្ទើរគ្រប់វិស័យបានកែប្រែពីទម្រង់មានលក្ខណៈប្រពៃណី មកជាដំណើរការដោយប្រើ

ប្រាស់បច្ចេកវិទ្យា សម្ភារៈទំនើបៗ ជាដើម។ ក្នុងនោះ គេសង្កេតឃើញថាសកម្មភាពនៃការទិញ-លក់ឬសកម្មភាពអាជីវកម្មដែលជាដំណើរការសង្គមចាំបាច់បំផុតមួយមានការកែប្រែពីការទិញ-លក់បែបប្រពៃណីមកជាការជួញដូរពីចម្ងាយដោយអតិថិជនមិនចាំបាច់ឈរទល់មុខគ្នាផ្ទាល់ដើម្បីចរចារឬផ្លោះប្តូរទំនិញនោះឡើយ។ ប្រជាជននៅជ្រុងម្ខាងនៃពិភពលោកអាចធ្វើការបញ្ជាទិញទំនិញដែលខ្លួនពេញចិត្តតាមរយៈមធ្យោបាយបច្ចេកវិទ្យាផ្សេងៗនៅលើប្រព័ន្ធអនឡាញបានដោយងាយស្រួលនិងឆាប់រហ័ស (Xu & Quaddus, 2010)។ ការផ្លាស់ប្តូរនេះ បានផ្តល់ឱកាសដល់គ្រប់ៗគ្នា ព្រោះដោយសារបច្ចេកវិទ្យា ក្រុមហ៊ុនលក់ផលិតផល ផលិតករ និងពាណិជ្ជករ ជាដើម អាចដំណើរការអាជីវកម្មរបស់ខ្លួនបានក្នុងលំហអ៊ីនធឺណិត និងបន្តទំនាក់ទំនងជាមួយពាណិជ្ជករនិងអតិថិជនផ្សេងទៀតបានដោយពុំបាច់ខ្វល់ខ្វាយពីនាំងទីតាំងភូមិសាស្ត្រឬរយៈចម្ងាយដូចអាជីវកម្មបែបប្រពៃណីនោះទេ (Alkasassbeh, 2014)។ ផលិតករ និងពាណិជ្ជកម្មនានាបានធ្វើការផ្លាស់ប្តូរទម្លាប់ក្នុងការធ្វើអាជីវកម្មរបស់ខ្លួនដោយប្រើប្រាស់បច្ចេកវិទ្យានិងអភិវឌ្ឍថ្នាលអាជីវកម្មអនឡាញ (online business platform) ដើម្បីបំពេញតម្រូវការថ្មីជាមួយនឹងការផ្លាស់ប្តូរនៃរបត់សង្គម។

នាពេលថ្មីៗនេះ និន្នាការនៃការទិញ-លក់ទំនិញនិងសេវាកម្មតាមអនឡាញនៅកម្ពុជាកំពុងមានភាពពេញនិយមកាន់តែច្រើនឡើងៗ។ យោងតាមការសិក្សារបស់ Statista (2023) ទំហំទីផ្សារតាមអនឡាញនៅកម្ពុជាត្រូវបានព្យាករថានឹងកើនដល់ 1.66 ប៊ីលានដុល្លារនៅឆ្នាំ២០២៣ ហើយនឹងកើនឡើងដល់ 3 ពាន់លានដុល្លារនៅឆ្នាំ២០២៧។ ទំហំទីផ្សារ នេះត្រូវបានប៉ាន់ប្រមាណថានឹងមានកំណើនប្រចាំឆ្នាំជាមធ្យមប្រមាណ 15.95% ក្នុងអំឡុង ពេល៥ ឆ្នាំ ខាងមុខ។ ផលិតផលសម្លៀកបំពាក់ ផលិតផលថែសម្រស់និងសុខភាព ព្រមទាំងសម្ភារៈប្រើប្រាស់ក្នុងគេហដ្ឋាន អាហារ គឺជាទំនិញដែលពេញនិយមនិងមានតម្រូវការខ្ពស់ក្នុងចំណោមអ្នកទិញទំនិញតាមអនឡាញនៅកម្ពុជា ខណៈដែលគ្រឿងសង្ហារឹម ឧបករណ៍ក្មេងលេង ភេសជ្ជៈនិងសេវាកម្មនៅមានតម្រូវការទាប ប៉ុន្តែក្នុងអត្រាកំណើន (Phanet, 2022)។

## ១.២. ឥទ្ធិពលបច្ចេកវិទ្យានិងអាជីវកម្មអនឡាញ

### ១.២.១. បច្ចេកវិទ្យានិងអត្ថប្រយោជន៍សម្រាប់អាជីវកម្មអនឡាញ

បច្ចេកវិទ្យានិងអ៊ីនធឺណិតបានជះឥទ្ធិពលយ៉ាងខ្លាំងទៅលើបែបបទនៃការទិញ-លក់ផលិតផលរវាងអ្នកទិញនិងអ្នកលក់ ដែលទិដ្ឋភាពទាំងនោះបានស្តែងចេញតាមរយៈសកម្មភាពនិងអត្ថប្រយោជន៍សំខាន់ៗមួយចំនួនដែលអ្នកលក់និងអ្នកទិញទទួលបាន។

- *ការទិញ-លក់ផលិតផលតាមអនឡាញ៖* ដោយសារបច្ចេកវិទ្យានិងសេវាអ៊ីនធឺណិត អ្នកលក់អាចបង្កើតនូវថ្នាលលក់ដូរតាមអនឡាញ[៩] (online shopping platform) ដ៏សម្បូរបែប និង អតិថិជនអាចធ្វើការបញ្ជាទិញទំនិញដោយផ្ទាល់ពីផ្ទះរបស់គេបាន ដោយប្រើឧបករណ៍ដូចជាកុំព្យូទ័រ ថេបប្លេត ឬទូរសព្ទដៃ

[៩] ថ្នាលលក់ដូរតាមអនឡាញនេះប្រៀបបានដូចតូបតាំងលក់ផលិតផលបែបឌីជីថល។ ការរៀបចំថ្នាលលក់ដូរតាមអនឡាញនេះអាចលេចចេញជារូបភាពច្រើនទម្រង់ដូចជា គេហទំព័រ កម្មវិធីទូរសព្ទដៃ/ថេបប្លេត កម្មវិធីកុំព្យូទ័រ ទំព័រហ្វេសប៊ុកជាដើម។

- *ងាយស្រួលក្នុងការប្រៀបធៀបតម្លៃ៖* បច្ចេកវិទ្យាជួយដល់អតិថិជនក្នុងការប្រៀបធៀបតម្លៃទំនិញនៅតាមថ្នាលលក់ទំនិញអនឡាញរបស់ក្រុមហ៊ុនឬម្ចាស់អាជីវកម្មផ្សេងៗបានយ៉ាងរហ័សនិងមានប្រសិទ្ធភាពបំផុត។ អតិថិជនអាចចំណេញពេលច្រើនក្នុងការធ្វើដំណើរពីហាងមួយទៅហាងមួយដើម្បីប្រៀបធៀបតម្លៃ
- *របៀបក្នុងការទូទាត់ថ្លៃទំនិញ៖* បច្ចេកវិទ្យាក៏បានផ្លាស់ប្តូរវិធីទូទាត់ថ្លៃទំនិញដោយប្តូរពីការទូទាត់ដោយសាច់ប្រាក់សុទ្ធឬការចូលទៅកាន់ធនាគារដើម្បីផ្ញើប្រាក់ មកជាការទូទាត់ដោយរូបិយបណ្ណឌីជីថល ឬប្រើប្រាស់កម្មវិធីធនាគារចល័តបានភ្លាមៗចេញពីឧបករណ៍អេឡិចត្រូនិកផ្ទាល់ខ្លួន
- *ការផ្សព្វផ្សាយលក់ផលិតផល៖* ប្រព័ន្ធបណ្តាញសង្គមដែលជាផលិតផលដ៏ពេញនិយមនៃសម័យបច្ចេកវិទ្យាបានដើរតួនាទីយ៉ាងសំខាន់ក្នុងការធ្វើទីផ្សារ ផ្សព្វផ្សាយលក់ផលិតផល និងអាចជួយសម្រួលអតិថិជនក្នុងស្វែងរកផលិតផល ឬ ណែនាំបន្ត។ ប្រព័ន្ធបណ្តាញទំនាក់ទំនងសង្គមបានជួយម្ចាស់អាជីវកម្មចំណេញថវិកាយ៉ាងច្រើនពីការផ្សព្វផ្សាយឬធ្វើទីផ្សារផលិតផលទៅកាន់អតិថិជនគោលដៅរបស់ខ្លួន
- *សម្រួលការគ្រប់គ្រងខ្សែសង្វាក់ផ្គត់ផ្គង់៖* បច្ចេកវិទ្យាក៏អាចជួយអ្នកលក់ក្នុងការគ្រប់គ្រងខ្សែច្រវាក់ផ្គត់ផ្គង់ផលិតផលរបស់ខ្លួន ដើម្បីចៀសវាងការរក្សាទុកទំនិញហួសសុពលភាព ការកកស្ទះទំនិញ និងទំនិញមិនជាទីពេញនិយមជាដើម
- *ការកំណត់ទីតាំងនិងអតិថិជនគោលដៅ៖* បច្ចេកវិទ្យាបានជួយអ្នកលក់ផលិតផលអាចធ្វើការតាមដានពីទីតាំងនៃការបញ្ជាទិញផលិផលរបស់ខ្លួន ព្រមទាំងអាចកំណត់នូវអតិថិជនគោលដៅទៅតាមក្រុមអាយុ ទីតាំងរស់នៅជាដើម។

## ១.២.២. បច្ចេកវិទ្យានិងបញ្ហាប្រឈមទៅលើអាជីវកម្មអនឡាញ

ក្រៅអំពីអត្ថប្រយោជន៍សម្រាប់អាជីវកម្មអនឡាញហើយ វាក៏នាំមកនូវបញ្ហាប្រឈមមួយចំនួនផងដែរ បានបង្ហាញនូវបញ្ហាប្រឈមនៃអាជីវកម្មអនឡាញមួយចំនួនដូចខាងក្រោម៖

- *បញ្ហាសុវត្ថិភាព៖* ដោយសារបច្ចេកវិទ្យា ការជ្រៀតជ្រែកតាមបណ្តាញអ៊ីនធឺណិតបានក្លាយជាបញ្ហាប្រឈមដ៏សំខាន់សម្រាប់អាជីវកម្មអនឡាញ។ បញ្ហាដូចជាការលួចទិន្នន័យនិងអត្តសញ្ញាណអតិថិជន ការជ្រៀតជ្រែកប្រតិបត្តិការអាជីវកម្ម សុវត្ថិភាពក្នុងពេលទូទាត់ថ្លៃទំនិញជាដើម សុទ្ធតែជាបញ្ហាក្តៅសម្រាប់អតិថជននិងម្ចាស់អាជីវកម្មអនឡាញ
- *តម្លៃនិងការដឹកជញ្ជូន៖* អាជីវកម្មអនឡាញជាប្រតិបត្តិការពីចម្ងាយ ដូចនេះ អ្នកទិញអាចនឹងត្រូវចំណាយបន្ថែមទៅលើថ្លៃដឹកជញ្ជូន ស្របពេលដែលរយៈពេលដឹកជញ្ជូនក៏ជាបញ្ហាមួយទៀត ហើយពេលខ្លះដោយសារថ្លៃដឹកជញ្ជូនខ្ពស់ពេក រយៈពេលដឹកជញ្ជូនយូរ ក៏បានធ្វើឱ្យអតិថិជនបោះបង់ការបញ្ជាទិញក៏មាន
- *ភាពត្រឹមត្រូវនៃផលិតផល៖* ការទិញទំនិញតាមអនឡាញគឺពឹងផ្អែកទាំងស្រុងទៅលើព័ត៌មានផលិតផលដែលមាននៅលើថ្នាលលក់ទំនិញ ប៉ុន្តែ មានករណីជាច្រើនដែលទំនិញដែលទទួលបានពុំដូចនឹងអ្វីដែលបានបរិយាយក្នុងទំព័រលក់ផលិតផលអនឡាញ

- *បញ្ហាបច្ចេកទេស៖* ជាក់ស្តែងសកម្មភាពទិញ-លក់តាមអនឡាញពឹងផ្អែកទាំងស្រុងទៅលើប្រព័ន្ធអ៊ីនធឺណិត បច្ចេកវិទ្យា ដែលបញ្ហាទាក់ទងនឹងដំណើរការអ៊ីនធឺណិតយឺត គេហទំព័រគាំងឬដើរយឺត សុទ្ធតែអាចប៉ះពាល់ដល់អារម្មណ៍អ្នកប្រើប្រាស់ ដោយសារបញ្ហាពាក់ព័ន្ធនឹងកត្តាទាំងនេះ អាជីវកម្មអនឡាញពិបាកធ្វើប្រតិបត្តិការនៅក្នុងតំបន់ដែលមានបច្ចេកវិទ្យាទាបឬប្រព័ន្ធអ៊ីនធឺណិតខ្សោយ
- *ទំនាក់ទំនងអតិថិជន៖* ទំនាក់ទំនងជាមួយអតិថិជនគឺជាកត្តាជោគជ័យមួយសម្រាប់អាជីវកម្មគ្រប់ប្រភេទ ផ្ទុយពីការទិញ-លក់បែបប្រពៃណី ទំនាក់ទំនងជាមួយអតិថិជនតាមសេវាអាជីវកម្មអនឡាញពុំមានភាពរហ័សឬពិបាកនឹងបំពេញចិត្តអតិថិជនបានខ្លាំងណាស់
- *ផលប៉ះពាល់លើបរិស្ថានដោយការវេចខ្ចប់៖* ការទិញ-លក់ទំនិញតាមអនឡាញគឺទាមទារការដឹកជញ្ជូនដោយធានាបាននូវគុណភាពនិងរក្សាបាននូវភាពដើមទាំងស្រុងរបស់ផលិតផល ដូចនេះ ក្នុងដំណាក់កាលនៃការរៀបចំ វេចខ្ចប់ និង ដឹកជញ្ជូន គេត្រូវការសម្ភារៈវេចខ្ចប់ច្រើនដែលនេះជាមូលហេតុមួយបណ្តាលឱ្យតម្រូវការសម្ភារៈទាំងនេះមានការកើនឡើងខ្ពស់ និង ធ្វើឱ្យប៉ះពាល់ដល់បរិស្ថានទាំងក្នុងដំណាក់កាលផលិតនិងផ្គត់ផ្គង់ក៏ដូចជាពេលចោលសម្ភារៈវេចខ្ចប់ទាំងនេះទៅក្នុងបរិស្ថានវិញពេលទំនិញដល់ដៃអតិថិជន។

## ១.៣. ចំណោទបញ្ហាស្រាវជ្រាវ

តម្រូវការទិញទំនិញតាមអនឡាញនៅកម្ពុជាកំពុងមានប្រជាប្រិយភាពកើនឡើងជាលំដាប់ ហើយគេក៏សង្កេតឃើញអាជីវកម្មប្រភេទនេះមានការកើនឡើងច្រើនផងដែរ។ ប្រាកដណាស់ ពុំមែនគ្រប់គ្នាសុទ្ធតែទទួលបានជោគជ័យនៅក្នុងអាជីវកម្មនោះទេ ហេតុនេះហើយបានជាមានការសិក្សាជាច្រើនទាក់ទងនឹងកត្តាចូលរួមក្នុងភាពជោគជ័យឬបរាជ័យនៃអាជីវកម្មអនឡាញ (Akroush & Al-Debei, 2015; Alagoz & Hekimoglu, 2012; Cai & Jun, 2003; Huang et al., 2019; Jun et al., 2004; Khan et al., 2019; Lee & Lin, 2005; Rita et al., 2019; Tsao & Tseng, 2011; Yang et al., 2004)។ លទ្ធផលនៃការសិក្សាទាំងនោះបានបង្ហាញថាកត្តាដែលចូលរួមក្នុងភាពជោគជ័យលើអាជីវកម្មអនឡាញមានភាពងាយស្រួលនៃការប្រើប្រាស់ (Huang et al., 2019; Jun et al., 2004; Lee & Lin, 2005; Tsao & Tseng, 2011; Yang et al., 2004), ទំនុកចិត្ត(ឧទាហរណ៍៖ ការរៀបចំ និងចែកចាយផលិតផលមានភាពត្រឹមត្រូវតាមការបញ្ជាទិញ និងទាន់ពេលវេលា (Huang et al., 2019; Jun et al., 2004; Lee & Lin, 2005; Yang et al., 2004), វិធានការការពារសុវត្ថិភាពនិងឯកជនភាពរបស់អតិថិជន (Huang et al., 2019; Rita et al., 2019), ការឆ្លើយតបរបស់អ្នកលក់(ឧទាហរណ៍៖ ការផ្តល់ព័ត៌មាន ការដោះស្រាយបញ្ហាជូនអតិថិជនយ៉ាងរហ័ស និងស្មោះត្រង់) (Jun et al., 2004; Lee & Lin, 2005; Yang et al., 2004), និងសេវាកម្មគាំទ្រអតិថិជន (ឧទាហរណ៍៖ ការជួយអតិថិជនជ្រើសរើសនិងទិញផលិតផល)(Huang et al., 2019; Jun et al., 2004)។

ជាក់ស្តែង ការសិក្សាប្រភេទនេះច្រើនធ្វើឡើងនៅបរទេស ដោយឡែកនៅក្នុងប្រទេសកម្ពុជា ការសិក្សាដែលមានលក្ខណៈវិទ្យាសាស្ត្រទៅលើចំណោទបញ្ហាបែបនេះហាក់នៅមានកម្រិតនៅឡើយ ដែលនេះជាមូលដ្ឋានមួយដែលជំរុញនូវការសិក្សានេះឡើង។ ការស្រាវជ្រាវអំពីទស្សនៈអតិថិជនទៅលើការទិញ-លក់និងសេវាទិញ-លក់ទំនិញតាមអនឡាញ

នេះផ្ដោតទៅលើកង្វះខាតនៃចំណេះដឹងបែបវិទ្យាសាស្ត្រក៏ដូចជាកង្វះខាតការស្រាវជ្រាវទៅលើចំណោទបញ្ហាដែលបានលើកឡើងខាងលើ។

### ១.៤. វត្ថុបំណងនិងក្របខណ្ឌគំនិត

ការសិក្សានេះផ្ដោតជាសំខាន់ទៅលើទស្សនៈរបស់អតិថិជននៅកម្ពុជាទាក់ទងនឹងអាជីវកម្មទិញ-លក់ទំនិញតាមអនឡាញ។ ជាមួយនឹងគោលបំណងនេះ ការសិក្សានេះមានវត្ថុបំណងស្រាវជ្រាវចំនួនពីរដូចខាងក្រោម៖

- សិក្សាពីទិដ្ឋភាពទូទៅនៃអាជីវកម្មទិញ-លក់ទំនិញតាមអនឡាញនៅក្នុងប្រទេសកម្ពុជា
- សិក្សាពីទស្សនៈរបស់អតិថិជនទៅលើសេវាកម្មនៃអាជីវកម្មទិញ-លក់ទំនិញតាមអនឡាញនៅកម្ពុជា

ជាមួយនឹងវត្ថុបំណងទាំងពីរនេះ ការសិក្សាផ្ដោតទៅលើទិដ្ឋភាពនៃសេវាកម្មទិញ-លក់ទំនិញអនឡាញចំនួនប្រាំដូចជា ការរចនា មុខងារ និង ភាពងាយស្រួលប្រើប្រាស់នៃថ្នាលទិញទំនិញ-លក់ទំនិញតាមអនឡាញ, ការធានារក្សានូវឯកជនភាពនិងសុវត្ថិភាពព័ត៌មានរបស់អតិថិជន, ការរៀបចំដឹកជញ្ជូនផលិតផលឱ្យអតិថិជនតាមពេលកំណត់, ការដោះស្រាយបញ្ហាជូនអតិថិជននិងភាពស្មោះត្រង់ និង ការយកចិត្តទុកដាក់និងជួយអតិថិជនក្នុងការជ្រើសរើសទំនិញ។

## ២. វិធីសាស្ត្រស្រាវជ្រាវ

### ២.១. សំណាកស្រាវជ្រាវនិងទិន្នន័យ

ការសិក្សាអំពីទស្សនៈរបស់អតិថិជនចំពោះគុណភាពសេវាកម្មទិញ-លក់ទំនិញតាមអនឡាញនេះ ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបបរិមាណវិស័យ ក្នុងនោះសំណាកស្រាវជ្រាវទទួលបានពីវិធីជ្រើសរើសសំណាកមិនចៃដន្យពីរបែប គឺវិធីជ្រើសរើសសំណាកតាមតៗគ្នា (snowball sampling method) និងវិធីចូលរួមដោយស្ម័គ្រចិត្ត (volunteer sampling technique)។ សំណាកស្រាវជ្រាវចាំបាច់ត្រូវបំពេញលក្ខខណ្ឌជាអតិថិជនដែលធ្លាប់មានបទពិសោធទិញទំនិញតាមអនឡាញនិងកំពុងបន្តទិញទំនិញតាមអនឡាញ។

វិធីទី1៖ ការជ្រើសរើសសំណាកតៗគ្នា

ដំបូងអ្នកស្រាវជ្រាវបានស្នើសុំអ្នកស្គាល់គ្នាក្នុងចំណោមមិត្តរួមការងារ មិត្តភក្តិដែលមានបទពិសោធទិញទំនិញតាមអនឡាញនិងបន្តទិញឱ្យជួយបំពេញកម្រងសំណួរស្ទង់មតិតាមតំណ Google Form បន្ទាប់មកស្នើសុំពួកគេឱ្យជួយចែករំលែកបន្តនូវតំណកម្រងសំណួរទៅកាន់មិត្តភក្តិ មិត្តរួមការងារ បងប្អូន ញាតិមិត្តជាបន្តបន្ទាប់ ដែលអ្នកបន្តបន្ទាប់នោះត្រូវផ្ទៀងផ្ទាត់លក្ខខណ្ឌដូចគ្នានេះ។

វិធីទី2៖ ការចូលរួមដោយស្ម័គ្រចិត្ត

បន្ថែមពីវិធីខាងលើ អ្នកស្រាវជ្រាវបានចែករំលែកតំណភ្ជាប់កម្រងសំណួរស្ទង់មតិតាមបណ្ដាញសង្គមហ្វេសប៊ុក ក្រុមតេឡេក្រាម និង ក្រុម Messenger ដើម្បីស្នើសុំសមាជិកក្នុងក្រុមដែលត្រូវនឹងលក្ខខណ្ឌខាងលើជួយបំពេញកម្រងសំណួរនេះតាមការស្ម័គ្រចិត្ត។

ជាលទ្ធផល ការសិក្សានេះប្រមូលផ្តុំដោយសំណាកស្រាវជ្រាវជាអតិថិជនទំនិញអនឡាញចំនួន 231នាក់ ក្នុងនោះ អតិថិជនភេទស្រីមានសមាមាត្រ 55.8%។

### ២.២. ឧបករណ៍ស្រាវជ្រាវ

ឧបករណ៍ស្រាវជ្រាវសម្រាប់ការសិក្សានេះជាកម្រងសំណួរស្ទង់មតិដែលចែកចេញជាបីផ្នែក៖

- ផ្នែកទី1៖ ព័ត៌មានទូទៅរបស់អតិថិជន

  ផ្នែកនេះមានចំនួន4សំណួរទាក់ទងនឹង អាយុ ភេទ មុខរបរ និងទីលំនៅបច្ចុប្បន្នរបស់ក្រុមគោលដៅស្រាវជ្រាវ។
- ផ្នែកទី2៖ ការទិញទំនិញផលិតផលតាមអនឡាញ

  ផ្នែកនេះមានចំនួន4សំណួរទាក់ទងនឹងប្រភេទផលិតផល មធ្យោបាយបញ្ជាទិញ មធ្យោបាយទូទាត់សាច់ប្រាក់ និង ប្រភពទំនិញ ដែលអតិថិជននិយមទិញតាមអនឡាញ។
- ផ្នែកទី3៖ ទស្សនៈអតិថិជនទៅលើសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ

  ផ្នែកនេះមានចំនួន5សំណួរ ដែលសំណួរនីមួយៗក្តោបលើខ្លឹមសារទាក់ទងនឹងគុណភាពសេវាទិញ-លក់ទំនិញតាមអនឡាញ និងវាស់ដោយខ្នាតទិន្នន័យខាងក្រោម៖

  1 = មិនយល់ស្របខ្លាំង, 2 = មិនយល់ស្របគួរសម, 3 = មិនយល់ស្របបន្តិចបន្តួច
  4 = យល់ស្របបន្តិចបន្តួច, 5 = យល់ស្របគួរសម, 6 = យល់ស្របខ្លាំង

កម្រងសំណួរដែលរៀបចំរួចរាល់ត្រូវបានបញ្ចូលទៅក្នុងទម្រង់ Google Form ដើម្បីបង្កើតជាតំណភ្ជាប់ URL សម្រាប់កម្រងសំណួរស្ទង់មតិតាមអនឡាញ។ អ្នកស្រាវជ្រាវប្រើប្រាស់តំណភ្ជាប់របស់ Google Form នេះ ដើម្បីប្រមូលទិន្នន័យតាមអនឡាញពីក្រុមគោលដៅស្រាវជ្រាវ។

### ២.៣. ការវិភាគទិន្នន័យ

ទិន្នន័យដែលប្រមូលបានត្រូវបានរៀបចំវិភាគដោយប្រើវិធីវិភាគស្ថិតិបែបពណ៌នា (descriptive statistics) ក្នុងកម្មវិធីវិភាគទិន្នន័យ Microsoft Excel និង SPSS កំណែ25។ លទ្ធផលវិភាគត្រូវបានបង្ហាញជាតារាងស្ថិតិក្នុងទម្រង់ភាគរយនិងក្រាហ្វិកស្ថិតិដូចជាក្រាបសរសរនិងក្រាបផ្លិតជាដើម។

## ៣. លទ្ធផលស្រាវជ្រាវ

### ៣.១. ព័ត៌មានប្រជាសាស្ត្ររបស់ក្រុមគោលដៅ

ការសិក្សានេះមានការចូលរួមពីអតិថិជនផលិតផលអនឡាញចំនួន 231នាក់ ដែលអ្នកទាំងនោះធ្លាប់ទិញឬប្រើប្រាស់សេវាទិញ-លក់ទំនិញតាមអនឡាញ ហើយក៏កំពុងបន្តប្រើប្រាស់សេវាកម្មនេះក្នុងអំឡុងពេលដែលជួយបំពេញ

កម្រងសំណួរស្ទង់មតិ។ ក្នុងចំណោមក្រុមគោលដៅទាំងអស់ អតិថិជនជានារីមានចំនួន 55.8% និងសមាមាត្របុរសមាន 44.2%។ ក្រុមគោលដៅទាំងនេះមានមុខរបរឬស្ថានភាពការងារជាសិស្សនិងនិស្សិត (41.1%) មន្ត្រីរាជការ (22.1%) បុគ្គលិកកិច្ចសន្យា (29.0%) និង អ្នកដែលមានមុខរបរផ្ទាល់ខ្លួន[២] (7.8%)។ ទន្ទឹមនឹងនេះដែរ ក្រុមគោលដៅរស់នៅក្នុងរាជធានីភ្នំពេញមាន 71.9% និងអ្នករស់នៅតាមបណ្តាខេត្តផ្សេងៗមានចំនួន 28.2%។

## ៣.២. ការទិញទំនិញតាមអនឡាញ

លទ្ធផលស្រាវជ្រាវនៅក្នុងផ្នែកនេះផ្តោតទៅលើទិដ្ឋភាពទូទៅនៃការទិញទំនិញតាមអនឡាញរបស់ក្រុមគោលដៅដែលបានចូលរួមក្នុងការសិក្សា។ នាពេលបច្ចុប្បន្ន ប្រជាជនកម្ពុជាបានដើរតាមនិន្នាការបែបទំនើបដោយចាប់យកការទិញទំនិញនិងប្រើប្រាស់សេវាកម្មតាមអនឡាញកាន់ច្រើនឡើងៗ។ គេសង្កេតឃើញថា ប្រជាជនកម្ពុជាបានបញ្ជាទិញទំនិញជាច្រើនប្រភេទតាមបណ្តាញអនឡាញនេះ ដែលទំនិញទាំងនេះមានដូចជា សម្លៀកបំពាក់ សម្ភារៈប្រើក្នុងគេហដ្ឋាន អាហារនិងភេសជ្ជៈ ផលិតផលថែសម្ផស្សនិងគ្រឿងសម្អាង សំបុត្ររថយន្ត សំបុត្រយន្តហោះ សំបុត្រទស្សនាភាពយន្ត គ្រឿងទេស បន្លែនិងផ្លែឈើ អាហារបំប៉ន ផលិតផលប្រើប្រាស់ក្នុងវិស័យកសិកម្ម គ្រឿងសំណង់ និងថ្នាំពេទ្យជាដើម។ លទ្ធផលស្រាវជ្រាវក្នុងរូបភាពទី1[៣] បង្ហាញថា ក្នុងចំណោមជម្រើសផលិតផលទាំងអស់ សម្លៀកបំពាក់គ្របដណ្តប់ 24.0% និងបើគិតតាមចំនួនអតិថិជនវិញគេសង្កេតឃើញថាមានអតិថិជនរហូតដល់ 81.0% ធ្លាប់បានបញ្ជាទិញសម្លៀកបំពាក់តាមប្រព័ន្ធអនឡាញ។ ផលិតផលសម្ភារៈគេហដ្ឋាន, អាហារនិងភេសជ្ជៈ និង ផលិតផលថែសម្ផស្សនិងគ្រឿងសម្អាងជាប្រភេទផលិតផលពេញនិយមផ្សេងទៀតដែលទទួលបានការបញ្ជាទិញតាមអនឡាញដោយមានភាគរយរៀងគ្នា 17.0%, 14.0% និង 14.0% និងបើគិតតាមចំនួនអតិថិជនវិញមានភាគរយរៀងគ្នា 59.0%, 49.0% និង 46.0%។ ផលិតផលនិងសេវាកម្មផ្សេងទៀតដូចជា សំបុត្ររថយន្តក្រុង រថយន្តតាក់ស៊ី សំបុត្រយន្តហោះ សំបុត្រទស្សនាភាពយន្ត បន្លែនិងផ្លែឈើ ប្រភេទអាហារបំប៉ន ផលិតផលបម្រើក្នុងវិស័យកសិកម្ម សម្ភារសំណង់ និងថ្នាំពេទ្យជាដើម ពុំសូវទទួលបានការបញ្ជាទិញតាមអនឡាញនោះទេ។

---

[២] ក្នុងការសិក្សានេះ របរផ្ទាល់ខ្លួនសំដៅដល់ក្រុមគោលដៅដែលមានមុខរបរឬការងារជារបស់ខ្លួនឯង និងអាស្រ័យលើទិដ្ឋភាពជាក់ស្តែងនៃមុខរបរដែលអាចបង្កើតប្រាក់ចំណូលតាមជំនាញរបស់ខ្លួនដោយមិនទទួលប្រាក់បៀវត្សពីថៅកែឬនិយោជក ឬសំដៅដល់បុគ្គលជាថៅកែឬម្ចាស់អាជីវកម្មផ្ទាល់តែម្តង។

[៣] គួរបញ្ជាក់ថា លទ្ធផលនៅក្នុងរូបភាពនេះទាញចេញពីការវិភាគសំណួរពហុជម្រើស មានន័យថាអតិថិជនម្នាក់អាចជ្រើសរើសផលិតផលបានច្រើនមុខ កាលណាស្ថានភាពជាក់ស្តែងគាត់ធ្លាប់បញ្ជាទិញផលិតផលច្រើនមុខតាមអនឡាញ។ ក្នុងករណីនេះ ភាគរយជម្រើសជាភាគរយនៃផលិតផលនីមួយៗធៀបនឹងជម្រើសសរុប ដោយឡែកភាគរយអតិថិជនជាសមាមាត្រអ្នកដែលជ្រើសរើសជម្រើសនីមួយៗធៀបនឹងចំនួនអតិថិជនសរុប។

រូបភាពទី1

*របាយទិន្នន័យអំពីផលិតផលដែលអតិថិជននៅកម្ពុជានិយមបញ្ជាទិញតាមអនឡាញ*




ពាក់ព័ន្ធនឹងមធ្យោបាយទូទាត់ថ្លៃទំនិញ លទ្ធផលក្នុងរូបភាពទី2បង្ហាញថា អតិថិជនអនឡាញជ្រើសរើសការទូទាត់ថ្លៃទំនិញតាមកម្មវិធីធនាគារចល័តក្នុងទូរសព្ទឬ KHQR Code ច្រើនជាងគេ ដែលសមាមាត្រសម្រាប់ជម្រើសនេះមានរហូតដល់ 39.8% និងតាមពីក្រោយដោយការទូទាត់សាច់ប្រាក់ផ្ទាល់ពេលទំនិញមកដល់(31.4%), ទូទាត់តាមបណ្ណ Visa ឬ Master (17.25%) និង ទូទាត់តាមភ្នាក់ងារផ្ញើប្រាក់ដូចជា វីង ទ្រូម៉ានី និង អ៊ីម៉ានីជាដើម (11.6%)។

រូបភាពទី2

*ទិដ្ឋភាពទូទៅនៃមធ្យោបាយទូទាត់ថ្លៃទំនិញតាមអនឡាញរបស់អតិថិជននៅកម្ពុជា*



រូបភាពទី3បង្ហាញពីទិដ្ឋភាពមធ្យោបាយទូទាត់ថ្លៃទំនិញដដែលនេះ ដោយវិភាគផ្អែកទៅលើកត្តាការងារនិងមុខរបរ កត្តាភេទ និងកត្តាទីតាំងរស់នៅ។ លទ្ធផលបង្ហាញថា អតិថិជនជាមន្ត្រីរាជការនិងសិស្សនិស្សិតហាក់មានទំនោរក្នុងការទូទាត់ផ្ទាល់ពេលទំនិញដល់ដៃ ច្រើនជាងអតិថិជនជាបុគ្គលិកជាប់កិច្ចសន្យាឬអ្នកដែលមានមុខរបរផ្ទាល់ខ្លួន ដោយឡែក ជម្រើសទូទាត់តាមកម្មវិធីធនាគារលើទូរសព្ទឬ KHQR Code ហាក់មានការពេញនិយមក្នុងចំណោមអតិថិជនជាមន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា និងអ្នកមានរបរផ្ទាល់ខ្លួន ច្រើនជាងក្នុងចំណោមសិស្សនិស្សិត។ ផ្អែកលើកត្តាភេទ អតិថិជនភេទស្រីមានទំនោរទូទាត់ផ្ទាល់ពេលទំនិញដល់ដៃនិងតាមកម្មវិធីធនាគារលើទូរសព្ទឬ KHQR Code ខ្ពស់ជាងអតិថិជនជាបុរស ដោយឡែកជម្រើសទូទាត់តាមមធ្យោបាយពីរផ្សេងទៀតហាក់មាននិន្នាការផ្ទុយពីនេះ។ ផ្អែកលើកត្តាទីតាំងរស់នៅ លទ្ធផលបង្ហាញថា មានអតិថិជនរស់នៅរាជធានីភ្នំពេញច្រើនលើសលុប ធៀបនឹងអតិថិជនរស់នៅតាមខេត្ត ដែលបានជ្រើសរើសការទូទាត់ពេលទំនិញមកដល់ ប៉ុន្តែទិដ្ឋភាពផ្ទុយសម្រាប់ជម្រើសទូទាត់តាមកម្មវិធីធនាគារលើទូរសព្ទឬ KHQR Code។

ផ្អែកទៅលើនិន្នាការបង្ហាញក្នុងរូបភាពទី3ខាងក្រោមនេះ គេអាចសន្និដ្ឋានបានថាសេវាទូទាត់តម្លៃទំនិញតាមកម្មវិធីធនាគារលើទូរសព្ទឬ KHQR Code មានការពេញនិយមច្រើនគួរសម និងបានបង្ហាញនូវសញ្ញាណវិជ្ជមានក្នុងការជំរុញឱ្យពាណិជ្ជកម្មតាមប្រព័ន្ធអេឡិចត្រូនិកកាន់តែងាយស្រួល និងមានភាពទូលំទូលាយ។

រូបភាពទី3

*របាយទិន្នន័យអំពីមធ្យោបាយទូទាត់ថ្លៃទំនិញតាមអនឡាញរបស់អតិថិជននៅកម្ពុជាអាស្រ័យតាមកត្តាមុខរបរ ភេទ និងទីតាំងរស់នៅ*




## ៣.៣. ទស្សនៈអតិថិជនទៅលើសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ

លទ្ធផលស្រាវជ្រាវនៅក្នុងផ្នែកនេះផ្តោតទៅលើទស្សនៈរបស់អតិថិជនទៅលើសេវាកម្មទិញ-លក់ផលិតផលតាមអនឡាញ ដោយផ្តោតទៅលើទិដ្ឋភាពចំនួនប្រាំដូចជា ការរចនា មុខងារ និង ភាពងាយស្រួលប្រើប្រាស់នៃថ្នាលទិញ

ទំនិញ-លក់ទំនិញតាមអនឡាញ(SQ1), ការធានារក្សានូវឯកជនភាពនិងសុវត្ថិភាពព័ត៌មានរបស់អតិថិជន(SQ2), ការរៀបចំដឹកជញ្ជូនផលិតផលឱ្យអតិថិជនតាមពេលកំណត់(SQ3), ការដោះស្រាយបញ្ហាជូនអតិថិជននិងភាពស្មោះត្រង់ (SQ4) និង ការយកចិត្តទុកដាក់និងជួយអតិថិជនក្នុងការជ្រើសរើសទំនិញ(SQ5)។ លទ្ធផលបានបង្ហាញថា ជាទូទៅអតិថិជនមានទស្សនៈវិជ្ជមានទៅលើទិដ្ឋភាពទាំងប្រាំនៃសេវាទិញ-លក់ផលិតផលតាមអនឡាញ បើទោះបីជាទស្សនៈទៅលើទិដ្ឋភាពពីរហាក់មានកម្រិតទាបជាងគេក្តី។ លទ្ធផលក្នុងរូបភាពទី4បានបង្ហាញថាមានអតិថិជនច្រើនជាង 88.0% យល់ស្របថា ថ្នាលទិញ-លក់ទំនិញតាមអនឡាញមានការរចនាល្អ ងាយស្រួលប្រើប្រាស់ និង មានប្រសិទ្ធភាពក្នុងការធ្វើប្រតិបត្តិការ។ ជាមួយគ្នានេះ មានអតិថិជនប្រមាណ 74.0% ពេញចិត្តលើការរៀបចំនិងដឹកជញ្ជូនទំនិញតាមការកំណត់ដល់អតិថិជន និង អតិថិជនជាង 69.0% កោតសរសើរចំពោះការយកចិត្តទុកដាក់របស់អ្នកលក់ទៅលើអតិថិជនក្នុងការជ្រើសរើសទំនិញ។ ទិដ្ឋភាពពីរដែលទទួលបានការយល់ស្របទាបជាងគេនោះគឺ សុវត្ថិភាពនិងការរក្សាឯកជនភាពរបស់អតិថិជន និង ការដោះស្រាយបញ្ហាដោយភាពស្មោះត្រង់ ដែលទទួលបានភាគរយវិជ្ជមានរៀងគ្នា 63.5% និង 62%។

រូបភាពទី4

*ទស្សនៈទូទៅរបស់អតិថិជនចំពោះសេវាកម្មទិញ-លក់ផលិតផលតាមអនឡាញក្នុងប្រទេសកម្ពុជា*[៤]




SQ1 ការរចនារបស់គេហទំព័រ កម្មវិធីទូរសព្ទ និងទំព័រហ្វេសប៊ុកជាដើមសម្រាប់ទិញលក់ ទំនិញ តាម អនឡាញ មានភាពទាក់ទាញ ងាយស្រួលប្រើប្រាស់ មានមុខងារច្រើននិងងាយស្រួលឱ្យ អតិថិជនទូទាត់តម្លៃទំនិញ។

SQ2 គេហទំព័រ កម្មវិធីទូរស័ព្ទ និងទំព័រហ្វេសប៊ុកជាដើមសម្រាប់ទិញលក់ទំនិញតាម អនឡាញ មានការរក្សានូវព័ត៌មានផ្ទាល់ខ្លួនបានល្អ។

SQ3 ការរៀបនិងដឹកជញ្ជូនផលិតផលដែលអតិថិជនបានបញ្ជាទិញមានភាពត្រឹមត្រូវតាមការបញ្ជាទិញ និងដឹកជញ្ជូនបានទាន់ពេលវេលាកំណត់។

SQ4 ករណីមានបញ្ហាណាមួយកើតឡើង (ក្នុងការបញ្ជាទិញ ឬទូទាត់តម្លៃទំនិញតាមអនឡាញ ជាដើម) នោះបញ្ហាត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស និងដោយភាពស្មោះត្រង់បំផុត។

SQ5 អ្នកលក់ផលិតផលតាមអនឡាញមានការយកចិត្តទុកដាក់ និងតែងជួយអតិថិជន ក្នុងការជ្រើសរើស និងទិញទំនិញតាមអនឡាញ។

[៤] គួរបញ្ជាក់ថា លទ្ធផលនៃការវិភាគទស្សនៈវិជ្ជមាននិងអវិជ្ជមានក្នុងរូបភាពនេះបានមកពីការគណនាដោយយកមតិយល់ស្រប(បន្តិចបន្តួច, គួរសម និង ខ្លាំង) ទៅជាទស្សនៈវិជ្ជមាន និងមតិមិនយល់ស្រប(បន្តិចបន្តួច, គួរសម និង ខ្លាំង) ទៅជាទស្សនៈអវិជ្ជមានទៅលើទិដ្ឋភាពនីមួយៗនៃសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ។

ការវិភាគលម្អិតទៅលើទស្សនៈរបស់អតិថិជនផ្អែកតាមកត្តា ភេទ ការងារ និង ទីតាំងរស់នៅ បង្ហាញថាសមាមាត្រអតិថិជនរស់នៅក្នុងរាជធានីភ្នំពេញនិងតាមបណ្តាខេត្តហាក់មានភាពខុសគ្នាអាស្រ័យលើទិដ្ឋភាពជាក់ស្តែងនៃសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ (រូបភាពទី5)។ រូបភាពបែបនេះក៏បានបង្ហាញផងដែរចំពោះសមាមាត្រអតិថិជនក្នុងក្រុមផ្សេងៗគ្នានៃកត្តាការងារនិងមុខរបរ ដោយឡែក បើផ្អែកតាមកត្តាភេទវិញ លទ្ធផលបានបង្ហាញថាសមាមាត្រអតិថិជនភេទប្រុសនិងភេទស្រីដែលមានទស្សនៈវិជ្ជមានទៅលើទិដ្ឋភាពទាំងប្រាំនៃសេវាទិញ-លក់ទំនិញតាមអនឡាញ ហាក់មានកម្រិតប្រហាក់ប្រហែលគ្នា។

រូបភាពទី5

*ទស្សនៈរបស់អតិថិជនដែលមាននិន្នាការវិជ្ជមានទៅលើសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ ផ្អែកទៅលើកត្តាការងារនិងមុខរបរ ភេទ និងទីតាំងរស់នៅ*




## ៤. ការពិភាក្សា

ការស្រាវជ្រាវនេះមានវត្ថុបំណងស្វែងយល់អំពីទស្សនៈរបស់អតិថិជនចំពោះការទិញនិងគុណភាពសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ ដោយផ្តោតសំខាន់ទៅលើទិដ្ឋភាពចំនួនប្រាំដូចជា ភាពងាយស្រួលនិងភាពមានសារៈប្រយោជន៍ សុវត្ថិភាពនិងការរក្សាឯកជនភាព ភាពដែលអាចទុកចិត្តបាន ភាពដែលមានការទទួលខុសត្រូវរបស់អ្នកលក់ និងការយកចិត្តទុកដាក់ជាមួយអតិថិជន។ លទ្ធផលបង្ហាញថា សម្លៀកបំពាក់ អាហារនិងភេសជ្ជៈ សម្ភារៈគេហដ្ឋាន និងគ្រឿងថែរក្សាសម្ផស្ស ទទួលបានបញ្ជាទិញច្រើនជាងគេតាមអនឡាញ។ ជាមួយគ្នានេះ ក្នុងការទូទាត់ថ្លៃទំនិញដែលបញ្ជាទិញតាមអនឡាញ អតិថិជនជ្រើសរើសការទូទាត់តាមធនាគារនិងការប្រគល់ប្រាក់នៅពេលទំនិញដល់ដៃ។ ហេតុផលប្រហែលជាដោយសារកត្តាសុវត្ថិភាពឬភាពមិនទុកចិត្ត។ មិនខុសគ្នាដែរ Halaweh (2018) និង Hamed and El-Deeb (2020) ក៏បានរកឃើញដែរថា ការដែលអតិថិជនជ្រើសរើសយកការទូទាត់ថ្លៃទំនិញពេលទំនិញមកដល់ គឺដើម្បីកាត់បន្ថយការក្លែងបន្លំ និងបញ្ហាអ្នកលក់មិនដឹកជញ្ជូនទំនិញឱ្យ។ ដូចនេះការទូទាត់ថ្លៃទំនិញ

ផ្ទាល់ពេលទំនិញមកដល់ដៃអតិថិជន គឺជាជម្រើសមួយក្នុងការបង្កើតសេចក្ដីទុកចិត្តរវាងអ្នកទិញនឹងអ្នកលក់។ លើសពីនេះវាក៏ផ្ដល់នូវភាពងាយស្រួលដល់អ្នកទិញ ហើយអ្នកទិញក៏អាចលុបចោលការបញ្ជាទិញ ឬផ្ញើទំនិញត្រឡប់ទៅអ្នកលក់វិញករណីពួកគេមិនពេញចិត្តនឹងផលិតផល។

ការសិក្សានេះក៏រកឃើញផងដែរថា អតិថិជនមានទស្សនៈវិជ្ជមានទៅលើទិដ្ឋភាពទាំងប្រាំនៃសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ ដែលប្រហែលជាដោយសារតែមានទស្សនៈវិជ្ជមានបែបនេះទើបអាជីវកម្មអនឡាញនៅកម្ពុជាមានការកើនឡើងកាន់តែច្រើនឡើងៗ។ ជាមួយគ្នានេះ ការសិក្សាមួយចំនួនក៏បានបង្ហាញថា ភាពងាយស្រួលនៃការប្រើប្រាស់ និងទំនុកចិត្ត មានឥទ្ធិពលវិជ្ជមានទៅលើការពេញចិត្តរបស់អតិថិជន និងធ្វើឱ្យអតិថិជនទទួលយកការទិញទំនិញតាមអនឡាញ (Alagoz & Hekimoglu, 2012; Benedict & Ko, 2004; Huang et al., 2019; Khan et al., 2019; Yang et al., 2004)។ បើពិនិត្យទៅលើទិដ្ឋភាពសុវត្ថិភាពនិងការរក្សាឯកជនភាពរបស់អតិថិជន ទំនួលខុសត្រូវរបស់អ្នកលក់ និងការយកចិត្តទុកដាក់ជាមួយអតិថិជន ការសិក្សានេះបង្ហាញថាមានអតិថិជនជាង60% ដែលយល់ឃើញថាទិដ្ឋភាពទាំងបីនេះមានភាពល្អប្រសើរនិងមានឥទ្ធិពលលើការពេញចិត្តរបស់ពួកគេ ខណៈដែលអតិថិជនដែលមិនពេញចិត្តមានជាង 30% ប៉ុន្តែក៏ពួកគេនៅបន្តទិញ។ ការណ៍នេះ បង្ហាញថាកត្តាទាំងបីនេះនៅមានភាពខ្វះខាតដែលអ្នកលក់គួរយកចិត្តទុកដាក់ដើម្បីបង្កើនភក្តីភាពរបស់អតិថិជន។ Khan et al. (2019) បានគូសបញ្ជាក់ថា ភាពដែលអាចទុកចិត្តបាន គឺជាកត្តាសំខាន់ក្នុងការជំរុញឱ្យអតិថិជនត្រឡប់មកទិញផលិតផលវិញ។ ទន្ទឹមនេះ កត្តាសុវត្ថិភាព គឺជាកត្តារួមផ្សំដែលរួមចំណែកដល់កត្តាភាពងាយស្រួលនៃការប្រើប្រាស់ ប៉ុន្តែក៏បានបញ្ជាក់ថាកត្តាទាំងនេះគឺសំខាន់បន្ទាប់ពីកត្តាភាពងាយស្រួលនៃការប្រើប្រាស់ថ្នាលទិញទំនិញនិងសេវាកម្មតាមអនឡាញ។ លើសពីនេះ អាជីវកម្មអនឡាញនឹងទទួលបានអត្ថប្រយោជន៍ពី ទំនួលខុសត្រូវរបស់អ្នកលក់ និងការយកចិត្តទុកដាក់ជាមួយអតិថិជន (Huang et al., 2019)។

ជាសរុបរួមទិដ្ឋភាពទាំងប្រាំដែលមានភាពងាយស្រួលនិងភាពមានអត្ថប្រយោជន៍ សុវត្ថិភាពនិងការរក្សាឯកជនភាព ទំនុកចិត្ត ទំនួលខុសត្រូវរបស់អ្នកលក់ និងការយកចិត្តទុកដាក់ជាមួយអតិថិជន គឺសុទ្ធតែជាកត្តាដែលរួមចំណែកដល់ការពេញចិត្តរបស់អតិថិជនក្នុងការទិញទំនិញតាមអនឡាញ ដែលកត្តានីមួយៗមានភាពទាក់ទងគ្នា។ តាមរយៈ Benedict and Ko (2004) ការពេញចិត្តរបស់អតិថិជនចំពោះគុណភាពសេវាកម្មទិញទំនិញតាមអនឡាញគឺរងឥទ្ធិពលទាំងកត្តាខាងក្នុងនិងកត្តាខាងក្រៅ។ កត្តាខាងក្នុងមានដូចជាភាពងាយស្រួលនៃការប្រើប្រាស់ និងភាពមានសារៈប្រយោជន៍ ហើយកត្តាខាងក្រៅមានដូចជា ការយកចិត្តទុកដាក់ជាមួយអតិថិជន គឺសុទ្ធតែជាកត្តាដែលរួមចំណែកដល់ការពេញចិត្តរបស់អតិថិជនក្នុងការទិញទំនិញតាមអនឡាញ ដែលកត្តានីមួយៗមានភាពទាក់ទងគ្នា។ ដូចនេះគុណភាពសេវាកម្មទិញទំនិញនិងសេវាកម្មតាមអនឡាញគឺជាកត្តាសំខាន់ក្នុង ការធ្វើឱ្យអតិថិជនពេញចិត្ត ហើយវាមានទំនាក់ទំនងខ្លាំងនិងវិជ្ជមានជាមួយនឹងការពេញចិត្តរបស់អតិថិជន (Jun et al., 2004)។

# ៥. សន្និដ្ឋាននិងអនុសាសន៍

## ៥.១. សេចក្តីសន្និដ្ឋាន

ការសិក្សាអំពីទស្សនៈរបស់អតិថិជននៅកម្ពុជាទៅលើអាជីវកម្មនិងសេវាកម្មទិញ-លក់ទំនិញតាមអនឡាញនេះ មានវត្ថុបំណងសិក្សាពីការទិញទំនិញតាមអនឡាញរបស់អតិថិជននៅកម្ពុជានិងទស្សនៈរបស់គេទៅលើសេវាទិញ-លក់ទំនិញតាមអនឡាញ។ ការសិក្សានេះមានការចូលរួមពីក្រុមគោលដៅស្រាវជ្រាវចំនួន 231 នាក់ ដែលបានចូលរួមបំពេញកម្រងសំណួរស្ទង់មតិតាមអនឡាញ។ លទ្ធផលបង្ហាញថាផលិតផលប្រភេទសម្លៀកបំពាក់ សម្ភារគេហដ្ឋាន អាហារនិងភេសជ្ជៈ និងផលិតផលសម្រាប់ថែសម្ផស្សនិងគ្រឿងសម្អាងទទួលបានការបញ្ជាទិញច្រើនជាងគេតាមមធ្យោបាយអនឡាញ។ វិធីឬរបៀបទូទាត់ថ្លៃទំនិញតាមអនឡាញដែលពេញនិយមជាងគេមានពីរគឺ ការទូទាត់តាមកម្មវិធីធនាគារចល័តលើទូរសព្ទឬស្កេន KHQR Code និង ការទូទាត់ភ្លាមៗពេលទំនិញមកដល់ដៃ។ លទ្ធផលក៏បានបង្ហាញផងដែរថា ជាទូទៅអតិថិជនមានទស្សនៈវិជ្ជមានទៅលើទិដ្ឋភាពទាំងប្រាំនៃសេវាកម្មទិញ-លក់ទំនិញតាមអនឡាញជាពិសេសទៅលើចំណុចពាក់ព័ន្ធនឹងការរៀបចំគេហទំព័រឬថ្នាលលក់ទំនិញតាមអនឡាញ និង គុណភាពនៃការរៀបចំ ដឹកជញ្ជូនទំនិញឱ្យអតិថិជន។ ទិដ្ឋភាពសេវាកម្មតាមអនឡាញដែលទទួលបានការពេញចិត្តតិចជាងគេគឺការដំណោះស្រាយបញ្ហាជូនអតិថិជនដោយភាពស្មោះត្រង់។

ជារួម លទ្ធផលនៃការសិក្សានេះបង្ហាញថា អតិថិជនដែលបានចូលរួមក្នុងការសិក្សានេះបង្ហាញនូវបទពិសោធន៍ល្អ និងទុកចិត្តលើការទិញទំនិញនិងសេវាកម្មតាមអនញឡាញនៅក្នុងប្រទេសកម្ពុជា។ ក្នុងនោះដែរ គុណភាពថ្នាលទិញទំនិញនិងសេវាកម្មតាមអនឡាញ គឺជាកត្តាសំខាន់ដែលមានឥទ្ធិពលទៅលការពេញចិត្តរបស់អតិថិជន។

## ៥.២. អនុសាសន៍

ក្នុងបរិបទបច្ចេកវិទ្យានេះ គេសង្កេតឃើញថាម្ចាស់អាជីវកម្មមួយចំនួនបានធ្វើប្រតិបត្តិការលក់ផលិតផលរបស់ខ្លួនតាមបែបចម្រុះដោយបញ្ចូលគ្នារវាងការលក់ដូរតាមបែបប្រពៃណីនិងការទិញ-លក់តាមប្រព័ន្ធអនឡាញ ដោយឡែក ម្ចាស់អាជីវកម្មខ្លះបានជ្រើសរើសវិធីទិញ-លក់តាមអនឡាញទាំងស្រុង។ មានកត្តាជាច្រើនដែលចូលរួមជួយជំរុញភាពជោគជ័យនៃអាជីវកម្មទិញ-លក់ទំនិញតាមអនឡាញ ដូចបង្ហាញនៅក្នុងការសិក្សារបស់ Akroush and Al-Debei, (2015); Cai and Jun (2003); Huang et al. (2019); Jun et al. (2004) និង Khan et al. (2019)។ ផ្អែកទៅលើស្ថានភាពជាក់ស្តែងនៃអាជីវកម្មអនឡាញក្នុងប្រទេសកម្ពុជា អ្នកស្រាវជ្រាវបានដាក់ជូនជាអនុសាសន៍មួយចំនួនដូចខាងក្រោមសម្រាប់ម្ចាស់អាជីវកម្ម ក្នុងគោលបំណងពង្រឹងភាពជោគជ័យនៃអាជីវកម្មអនឡាញ៖

- *ពង្រឹងសុវត្ថិភាពថ្នាលទិញ-លក់ទំនិញអនឡាញ៖* ក្នុងសម័យឌីជីថល ការវាយប្រហារឬការជ្រៀតជ្រែកតាមបណ្តាញអ៊ីនធឺណិតមានការកើនឡើងកាន់តែច្រើន ដូចនេះ ម្ចាស់អាជីវកម្មអនឡាញត្រូវបង្កើតប្រព័ន្ធឬថ្នាលទិញ-លក់ទំនិញរបស់ខ្លួនយ៉ាងណាថែរក្សាសុវត្ថិភាពព័ត៌មានឯកជននិងសុវត្ថិភាពក្នុងការទូទាត់ថ្លៃទំនិញរបស់អតិថិជនឱ្យបានខ្ពស់

- *បង្កើតថ្នាលទិញ-លក់ទំនិញដែលងាយស្រួលប្រើប្រាស់៖* ម្ចាស់អាជីវកម្មអនឡាញគួរបង្កើតថ្នាលទិញ-លក់ផលិតផលតាមអនឡាញដោយធ្វើយ៉ាងណាបង្កើតមាតិកាស្វែងរកផលិតផលដែលមានភាពងាយស្រួលប្រើប្រាស់ ជាពិសេសមិនមានតម្រូវការគុណភាពអ៊ីនធឺណិតខ្ពស់ពេកដែលអាចជាឧបសគ្គដល់អតិថិជននៅតាមតំបន់មានសេវាអ៊ីនធឺណិតខ្សោយ។ ការបង្កើតថ្នាលទិញ-លក់នេះ ក៏គួរពិចារណាផងដែរអំពីភាពបត់បែននៃឧបករណ៍អេឡិកត្រូនិកដែលប្រើប្រាស់ដើម្បីស្វែងរកឬបញ្ជាទិញផលិតផល
- *បង្ហាញព័ត៌មានលម្អិតនិងសំខាន់អំពីផលិតផល៖* ជាមួយនឹងថ្នាលទិញ-លក់ផលិតផល ម្ចាស់អាជីវកម្មគួរបង្ហាញនូវព័ត៌មានពិតនិងសំខាន់ៗអំពីផលិតផលដូចជាព័ត៌មានទាក់ទងនឹងទំហំ មុខងារ គុណភាព តម្លៃ វត្ថុធាតុផលិត ជាដើម។ ព័ត៌មានលម្អិតអំពីផលិតផលរួមចំណែកយ៉ាងខ្លាំងដល់ការពិចារណាទិញឬមិនទិញការពេញចិត្តរបស់អតិថិជន ហើយក៏អាចធ្វើឱ្យអតិថិជនទិញម្ដងហើយម្ដងទៀតបាន
- *ឆ្លើយតបនិងដោះស្រាយបញ្ហាអតិថិជនឱ្យបានល្អ៖* ចំណុចនេះជាបញ្ហាចម្បងមួយដោយសារតែសកម្មភាពគ្រប់បែបយ៉ាងដំណើរការពីចម្ងាយ ដូចនេះការឆ្លើយតបទៅអតិថិជនបានឆាប់រហ័ស ការទទួលដោះស្រាយបញ្ហាដល់អតិថិជនបានទាន់ពេលវេលាអាចបង្កើតនូវអារម្មណ៍វិជ្ជមានដល់អតិថិជនបាន។ ម្ចាស់អាជីវកម្មគួររៀបចំនូវយន្តការដោះស្រាយបញ្ហាអតិថិជនឱ្យបានសម្បូរបែបតាមមធ្យោបាយដូចជាការជជែកផ្ទាល់ ផ្ញើសារតាមអ៊ីមែល តាមទូរសព្ទ ឬ តាមបណ្ដាញសង្គមដែលអាចទាក់ទងបាន
- *បង្កើតនូវគោលការណ៍សំណងនិងវេលុយត្រឡប់៖* ម្ចាស់អាជីវកម្មអនឡាញគួររៀបចំនូវគោលការណ៍លក្ខខណ្ឌនៃការបង្វិលទំនិញត្រឡប់ ការសងថ្លៃទំនិញ ជាដើមឱ្យបានច្បាស់លាស់ និងគួរភ្ជាប់ខ្លឹមសារនេះរាល់ពេលដែលអតិថិជនដាក់បញ្ជាទិញទំនិញពីថ្នាលលក់ទំនិញ ឬពីហាងឌីជីថលរបស់ខ្លួន។ យន្តការច្បាស់លាស់សម្រាប់ការសងត្រឡប់ឬការបង្វិលទំនិញត្រឡប់នេះ ចូលរួមចំណែកយ៉ាងខ្លាំងដល់ទំនុកចិត្តអតិថិជនមកលើម្ចាស់អាជីវកម្មដោយផ្ទាល់
- *បង្កើនភាពទាក់ទាញក្នុងការលក់ផលិតផល៖* ការផ្សព្វផ្សាយអំពីផលិតផលគឺជាកត្តាស្លាប់រស់មួយក្នុងចំណោមកត្តាផ្សេងទៀតសម្រាប់អាជីវកម្មលក់ដូរទំនិញ។ ការផ្សព្វផ្សាយលក់ដោយយន្តការបញ្ចុះតម្លៃ មិនគិតថ្លៃដឹកជញ្ជូន ទិញថែម ថែមគូប៉ុងជាដើម សុទ្ធតែជាយុទ្ធសាស្ត្រទីផ្សារដែលមានការពេញនិយមខ្លាំងសម្រាប់អាជីវកម្មអនឡាញ។

## ៥.៣. គំនិតស្រាវជ្រាវបន្ត

លទ្ធផលនៃការសិក្សានេះបង្ហាញឱ្យឃើញពីជ្រុងមួយនៃអាជីវកម្មអនឡាញនៅកម្ពុជា ក៏ប៉ុន្តែ បើទោះជាលទ្ធផលនេះហាក់បង្ហាញនូវទំនោរវិជ្ជមានក្ដី ប៉ុន្តែវិសាលភាពនៃការសិក្សាមានកំណត់ និងសំណាកស្រាវជ្រាវក៏មានទំហំតូច។ ជាការរំពឹងទុក ការស្រាវជ្រាវអនាគតគួរផ្ដោតលើចំណុចមួយចំនួនដូចខាងក្រោម៖

- ពង្រីកវិសាលភាពសំណាកស្រាវជ្រាវឱ្យបានធំជាងនេះ និង ចម្រុះទិដ្ឋភាពដូចជា ទស្សនៈរបស់អ្នកជំនាញ អ្នករៀបចំគោលនយោបាយ និងម្ចាស់អាជីវកម្មផងដែរ ឬ បញ្ចូលសំណាកស្រាវជ្រាវពីតំបន់ភូមិសាស្ត្រចម្រុះឱ្យបានទូលាយ។

- ប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវបែបចម្រុះនិងប្រើម៉ូដែលស្ថិតិដើម្បីសិក្សាឱ្យបានស៊ីជម្រៅទៅលើទំនាក់ទំនងរវាងអថេរផ្សេងៗក្នុងទិដ្ឋភាពទាក់ទងនឹងអាជីវកម្មទិញ-លក់ទំនិញអនឡាញ។

## ឯកសារយោង


Alkasassbeh, W. A. K. (2014). Factors affecting consumers' attitudes toward online shopping in the city of Tabuk. European Journal of Business and Management, 6(18), 213-222.

Akroush, M. N., & Al-Debei, M. M. (2015). An integrated model of factors affecting consumer attitudes towards online shopping. *Business Process Management Journal*, *21*(6), 1353-1376.

Alagoz, S. M., & Hekimoglu, H. (2012). A study on tam: analysis of customer attitudes in online food ordering system. *Procedia-Social and Behavioral Sciences*, *62*, 1138-1143.

Benedict, G., & Ko, d. R. (2004). What drives consumers to shop online? A literature review. *International Journal of Service Industry Management*, *15*(1), 102-121.

Cai, S., & Jun, M. (2003). Internet users' perceptions of online service quality: a comparison of online buyers and information searchers. *Managing Service Quality: An International Journal*, *13*(6), 504-519.

Halaweh, M. (2018). Cash on delivery (COD) as an alternative payment method for e-commerce transactions: Analysis and implications. International Journal of Sociotechnology and Knowledge Development (IJSKD), 10(4), 1-12.

Hamed, S., & El-Deeb, S. (2020). Cash on delivery as a determinant of e-commerce growth in emerging markets. Journal of Global Marketing, 33(4), 242-265.

Huang, Z., Luo, Y., & Wang, D. (2019). Online customer service quality of online shopping: evidence from Dangdang. com. *Cluster Computing*, *22*(Suppl 6), 15285-15293.

Jun, M., Yang, Z., & Kim, D. (2004). Customers' perceptions of online retailing service quality and their satisfaction. *International Journal of Quality & Reliability Management*, *21*(8), 817-840.

Khan, M. A., Zubair, S. S., & Malik, M. (2019). An assessment of e-service quality, e-satisfaction and e-loyalty: Case of online shopping in Pakistan. *South Asian Journal of Business Studies*, *8*(3), 283-302.

Lee, G. G., & Lin, H. F. (2005). Customer perceptions of e-service quality in online shopping. *International journal of retail & distribution management*, *33*(2), 161-176.

Phanet, H., (2022, July 3).Cambodian e-commerce surges nearly a fifth in 2021. The Phnom Penh Post.https://www.phnompenhpost.com/business/cambodian-e-commerce-surges-nearly-fifth-2021

Rita, P., Oliveira, T., & Farisa, A. (2019). The impact of e-service quality and customer satisfaction on customer behavior in online shopping. *Heliyon*, *5*(10).

Statista (2023). Digital Commerce – Cambodia. https://www.statista.com/outlook/dmo/fintech/digital-payments/digital-commerce/cambodia

Tsao, W.-C., & Tseng, Y.-L. (2011). The impact of electronic-service quality on online shopping behaviour. *Total Quality Management & Business Excellence*, *22*(9), 1007-1024.

Xu, J., & Quaddus, M. (2010). E-business in the 21st Century: Realities, Challenges and Outlook (Vol. 2). World Scientific.

Yang, Z., Jun, M., & Peterson, R. T. (2004). Measuring customer perceived online service quality. *International Journal of Operations & Production Management*, *24*(11), 1149-1174. https://doi.org/10.1108/01443570410563278



**មឿង ចំរើន**

**កន្លែងការងារ៖**

- រាជបណ្ឌិត្យសភាកម្ពុជា

**បរិញ្ញាបត្រជាន់ខ្ពស់៖**

- ពាណិជ្ជសាស្ត្រ (សាកលវិទ្យាល័យជាតិបាត់ដំបង)

**ចំណូលចិត្តស្រាវជ្រាវ៖**

- ទីផ្សារ
- ទេសចរណ៍
- សេដ្ឋកិច្ចសង្គម



**លី តុង**

**កន្លែងការងារ៖**

- រាជបណ្ឌិត្យសភាកម្ពុជា

**បរិញ្ញាបត្រជាន់ខ្ពស់៖**

- អប់រំគណិតវិទ្យា
- រដ្ឋបាលអប់រំ
- គណិតវិទ្យា

**ចំណូលចិត្តស្រាវជ្រាវ៖**

- ចលករសិក្សារបស់សិស្ស
- ការវិភាគកំហុសក្នុងការរៀនគណិតវិទ្យា
- វិទ្យាសាស្ត្រទិន្នន័យ

## ឧបសម្ព័ន្ធ៖ កម្រងសំណួរស្រាវជ្រាវ

## ការសិក្សាខ្នាតតូចអំពីទស្សនៈអតិថិជនកម្ពុជាទៅលើគុណភាពនៃសេវាកម្មទិញ-លក់ទំនិញតាមឡាញ

### ផ្នែកទី ១៖ ព័ត៌មានផ្ទាល់ខ្លួន

Q1- ភេទ៖ ☐ ស្រី ☐ ប្រុស

Q2- អាយុ (សូមបំពេញ)៖ .............

Q3-មុខរបរ៖ ☐ សិស្ស/និស្សិត ☐ មន្ត្រីរាជការ ☐ បុគ្គលិកកិច្ចសន្យា ☐ ផ្សេងៗ...........

Q4-ទីលំនៅបច្ចុប្បន្ន៖ ☐ ភ្នំពេញ ☐ នៅតាមខេត្ត

### ផ្នែកទី២៖ ការទិញទំនិញផលិតផលតាមអនឡាញ

Q5- តើអ្នកធ្លាប់ទិញផលិតផល ប្រភេទណាខ្លះ តាមអនឡាញ?

☐ សំលៀកបំពាក់ ☐ គ្រឿងទេស ☐ ឧបករណ៍អេឡិចត្រូនិច ☐ អាហារ/ ភេសជ្ជៈ

☐ ផ្លែឈើ/បន្លែ ☐ សំបុត្រកុន ☐ សំបុត្រឡាន/ សំបុត្រយន្តហោះ ☐ ផ្សេងៗ...

Q6- តើអ្នកបញ្ជាទិញផលិតផលទាំងនោះតាមមធ្យោបាយអនឡាញណាច្រើនជាងគេ?

☐ App បញ្ជាទិញ ☐ គេហទំព័រ (Website) ☐ ហ្វេសបុក (Facebook) ☐ ផ្សេងៗ...........

Q7- តើកន្លងមក អ្នកធ្លាប់ទិញទំនិញពីប្រភពណាច្រើនជាងគេ?

☐ ហាងផ្សេងៗក្នុងស្រុក ☐ ក្រៅប្រទេស

Q8- តើមធ្យោបាយទូទាត់ទំនិញណាដែលអ្នកប្រើច្រើនជាងគេ?

☐ បង់ប្រាក់ពេលទំនិញមកដល់ ☐ បង់តាមក្រេឌីតកាត (Visa card, Master Card..)

☐ បង់តាមធនាគារ/ស្កេន QR Code (KHQR) របស់ធនាគារ ☐ ផ្សេងៗ...........

### ផ្នែកទី៣៖ ទស្សនៈអតិថិជនចំពោះសេវាកម្មទិញ-លក់ទំនិញតាមអនឡាញ

Q9- ប្រើខ្នាតរង្វាស់ការយល់ឃើញខាងក្រោម សូមបញ្ចេញទស្សនៈរបស់អ្នកទាក់ទងនឹងប្រយោគនីមួយៗខាងក្រោម

1 = មិនយល់ស្របខ្លាំង, 2= មិនយល់ស្របគួរសម, 3= មិនយល់ស្របបន្តិចបន្តួច

4 = យល់ស្របបន្តិចបន្តួច, 5 = យល់ស្របគួរសម, 6 = យល់ស្របខ្លាំង

| កូដ | ទស្សនៈរបស់អតិថិជន | 1 | 2 | 3 | 4 | 5 | 6 |
|---|---|---|---|---|---|---|---|
| SQ1 | ការរចនារបស់គេហទំព័រ កម្មវិធីទូរស័ព្ទ និងទំព័រហ្វេសប៊ុកជាដើមសម្រាប់ទិញលក់ទំនិញ តាម អនឡាញ មានភាពទាក់ទាញ ងាយស្រួលប្រើប្រាស់ មានមុខងារច្រើន និងងាយស្រួលឱ្យ អតិថិជនទូទាត់តម្លៃទំនិញ។ | ☐ | ☐ | ☐ | ☐ | ☐ | ☐ |

| | | | | | | | |
|---|---|---|---|---|---|---|---|
| | Online shopping platforms (e.g., website, app, Facebook…) are well-designed, attractive, multi-functional, easy to use and complete the purchase transaction quickly. | | | | | | |
| SQ2 | គេហទំព័រ កម្មវិធីទូរស័ព្ទ និងទំព័រហ្វេសប៊ុកជាដើមសម្រាប់ទិញលក់ទំនិញតាម អនឡាញ មានការរក្សានូវព័ត៌មានផ្ទាល់ខ្លួនបានល្អ។<br>Online shopping platforms (e.g., website, app, Facebook…) are designed with high privacy protection. | ☐ | ☐ | ☐ | ☐ | ☐ | ☐ |
| SQ3 | ការរៀបនិងដឹកជញ្ជូនផលិតផលដែលអតិថិជនបានកុម្ម៉ង់ទិញមានភាពត្រឹមត្រូវតាមការបញ្ជាទិញ និងដឹកជញ្ជូនបានទាន់ពេលវេលាកំណត់។<br>The preparation and delivery of the products is accurate to order and on time. | ☐ | ☐ | ☐ | ☐ | ☐ | ☐ |
| SQ4 | ករណីមានបញ្ហាណាមួយកើតឡើង (ក្នុងការបញ្ជាទិញ ឬទូទាត់តម្លៃទំនិញតាមអនឡាញ ជាដើម) នោះបញ្ហាត្រូវបានដោះស្រាយយ៉ាងឆាប់រហ័ស និងដោយភាពស្មោះត្រង់បំផុត។<br>In case there is problem occurred (e.g., putting the order, credit transaction…), it is solved quickly and honestly. | ☐ | ☐ | ☐ | ☐ | ☐ | ☐ |
| SQ5 | អ្នកលក់ផលិតផលតាមអនឡាញមានការយកចិត្តទុកដាក់ និងតែងជួយអតិថិជនក្នុងការ ជ្រើសរើស និងទិញទំនិញតាមអនឡាញ។<br>The online sellers/retailors are helpful and willing to help customers in choosing and purchasing products. | ☐ | ☐ | ☐ | ☐ | ☐ | ☐ |



ISBN: 978-99963-94-32-4

9 789996 394324 >

**បោះពុម្ពដោយ៖** វិទ្យាស្ថានមនុស្សសាស្ត្រនិងវិទ្យាសាស្ត្រសង្គម

ISBN: 978-99963-94-32-4

រក្សាសិទ្ធិ@២០២៣